ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ

# The situation of implementing the Child Friendly School program framework at the Primary School level in Tbong Khmum province

ដោយ

**ម៉ុល មួយគា**

**MOL MUOYKEA**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**
**ឯកទេស ៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២៣**

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារ មេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ

# The situation of implementing the Child Friendly School program framework at the Primary School level in Tbong Khmum province

ដោយ

**ម៉ុល មួយគា**

**MOL MUOYKEA**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០
ឯកទេស ៖ គ្រប់គ្រងអប់រំ
ឆ្នាំសិក្សា ២០២១-២០២៣

| | | |
|---|---|---|
| គ្រូណែនាំគោល | ៖ | បណ្ឌិត អ៊ឹម គឿន |
| គ្រូណែនាំរង | ៖ | បណ្ឌិត នី រដ្ឋា |

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទ **ម៉ុល មួយគា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១០ ឯកទេស**គ្រប់គ្រងអប់រំ** នៃវិទ្យាស្ថានជាតិអប់រំ។

សូមធ្វើការអះអាងថា ខ្លឹមសារក្នុងនិក្ខេបបទស្តីពី «**ស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ** » គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំពិតប្រាកដ ដោយមិនបានក្លែងបន្លំ ឬពាក់ព័ន្ធជាមួយនឹងនិក្ខេបបទអ្នកដទៃទេ ក្នុងការស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីទទួលបានសញ្ញាបត្រ។ ទិន្នន័យ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ ដែលបានលើកឡើងនៅក្នុងនិក្ខេបបទនេះ គឺជាទិន្នន័យ និងលទ្ធផលថ្មី ហើយមិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងនិក្ខេបបទរបស់គេឡើយ។

ខ្ញុំបាទសូមសន្យាថា និក្ខេបបទនេះមិនមានការក្លែងបន្លំ និងមិនមានការលួចចម្លងពីនិស្សិត ឬស្នាដៃអ្នកដទៃឡើយ។ ក្នុងករណីដែលវិទ្យាស្ថានជាតិអប់រំពិនិត្យឃើញថា មានករណីខាងលើកើតឡើងពិតប្រាកដមែន ខ្ញុំបាទសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃចន្ទ ១៣ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣

ហត្ថលេខា

**ម៉ុល មួយគា**

# លិខិតបញ្ជាក់

**ឈ្មោះ ៖** **បណ្ឌិត អ៊ឹម គឿន** ជាគ្រូណែនាំគោល

**ឈ្មោះ ៖** **បណ្ឌិត នី រដ្ឋា** ជាគ្រូណែនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ម៉ុល មួយគា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ នៃវិទ្យាស្ថានជាតិអប់រំ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ លើប្រធានបទ «**ស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ**»ពិតប្រាកដមែន។

ថ្ងៃចន្ទ ១៣ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣

ហត្ថលេខា



**បណ្ឌិត អ៊ឹម គឿន**
អ្នកស្រាវជ្រាវ និងគ្រូដឹកនាំថ្នាក់ក្រោយឧត្តមសិក្សា
នៃវិទ្យាស្ថានជាតិអប់រំ

**បណ្ឌិត នី រដ្ឋា**
ប្រធានការិយាល័យសិក្សា
នៃវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:**[illegible]**អយក.**ខថន

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | ណាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ស៊ិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នួវ វ៉ាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈុក ច័ន្ទឆាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហ៊ិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ** ៤៥០១ **អយក.ខ្សក**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទ **ម៉ុល មួយគា** សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មការគ្រប់គ្រង ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកលោកស្រី សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុត មកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះលោកគ្រូ **បណ្ឌិត អ៊ឹម គឿន** សាស្ត្រាចារ្យដឹកនាំសរសេរនិក្ខេបបទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការត្រួតពិនិត្យវាយតម្លៃ ជួយណែនាំ ផ្តល់មតិយោបល់ ដឹកនាំកិច្ចប្រជុំពិភាក្សា និងជំរុញលើកទឹកចិត្តដល់រូបខ្ញុំបាទក្នុងការសរសេរនិក្ខេបបទស្តីពី «**ស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ**» រហូតបានបញ្ចប់ដោយជោគជ័យ។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់លោកគ្រូ **បណ្ឌិត នី រដ្ឋា** សាស្ត្រាចារ្យដឹកនាំរង ដែលតែងតែផ្តល់នូវកម្លាំងចិត្ត ចំណេះដឹង ចែករំលែកបទពិសោធន៍ និងជួយកែតម្រូវ ហើយធ្វើឱ្យរូបខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងសាលាបឋមសិក្សា មានលោកនាយក នាយករង និងលោកគ្រូ អ្នកគ្រូ ដែលបានអនុញ្ញាត និងចូលរួមសហការធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ និងគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះលោកឪពុក **មឿង ម៉ុល** អ្នកម្តាយ **អឿ ទឿន** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ទទួលខុសត្រូវ និងទំនុកបំរុងដល់រូបកូនឱ្យបានទទួលការសិក្សារៀនសូត្រ រហូតរូបកូនមានថ្ងៃនេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរ និងសូមប្រសិទ្ធពរជ័យ ជូនអ្នកមានគុណទាំងពីរ ឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ នាយក/នាយិកា លោកគ្រូ អ្នកគ្រូ និងមិត្តរួមជំនាន់ទាំងអស់ សូមសមប្រកប ជួមប្រទះនូវព្រះពុទ្ធពរទាំង ៤ ប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ការអភិវឌ្ឍកម្មវិធីសាលាកុមារមេត្រី គឺជាកត្តាគន្លឹះក្នុងការប្រែក្លាយគ្រឹះស្ថានបឋមសិក្សាសាធារណៈក្នុងប្រទេសកម្ពុជាឱ្យរីកចម្រើន ក្នុងទិសដៅឆ្ពោះទៅសម្រេចចក្ខុវិស័យនៃយុទ្ធសាស្ត្រវិស័យអប់រំ និងបង្កើនប្រសិទ្ធភាព គុណភាព នៃការអប់រំនៅបឋមសិក្សាប្រកបដោយសមធម៌ និងបរិយាបន្ន។ ដោយឡែកខេត្តត្បូងឃ្មុំក៏មិនខុសពីរាជធានីខេត្តផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជាដែរ គឺបានអនុវត្តកម្មវិធីសាលាកុមារមេត្រី ចាប់តាំងពីក្រសួងអប់រំបានដាក់ចេញនូវគោលនយោបាយពីឆ្នាំ២០០៨។ ក្នុងន័យនេះ ដើម្បីស្វែងយល់ពីស្ថានភាពអនុវត្តរបស់កម្មវិធីសាលាកុមារមេត្រីនេះ អ្នកស្រាវជ្រាវបានធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ ភ្ជាប់នឹងគោលបំណងសំខាន់ៗពីរ (១) សិក្សាពីស្ថានភាពអនុវត្តកម្មវិធីសាលាកុមារមេត្រីក្នុងស្ថានភាពបែបណា និង(២) ឈ្វេងយល់ពីបញ្ហាប្រឈមដែលជួបប្រទះកំឡុងពេលអនុវត្ត។ ក្នុងការសិក្សានេះ ក៏បានបង្ហាញពីដំណោះស្រាយដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលកើតមានក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សាផងដែរ។

ដើម្បីធានាបានលទ្ធផលនៃការស្រាវជ្រាវនេះ ឲ្យមានលក្ខណៈវិទ្យាសាស្ត្រ អ្នកសិក្សាស្រាវជ្រាវបានប្រើវិធីសាស្ត្រចម្រុះ តាមបែបបរិមាណវិស័យ និងគុណវិស័យ។ ការប្រមូលទិន្នន័យបែបបរិមាណវិស័យ ត្រូវបានកំណត់យកគ្រូបង្រៀនចំនួន ១៥១នាក់ ជ្រើសរើសចេញពីសាលាបឋមសិក្សាក្នុងស្រុកទាំងបី នៃខេត្តត្បូងឃ្មុំ និងវិភាគទិន្នន័យតាមកម្មវិធីស្ថិតិ (SPSS)។ ការប្រមូលទិន្នន័យបែបគុណវិស័យ ត្រូវបានជ្រើសយកសំណាកចំនួន ១២សំណាក ចំនួនពីរក្រុមផ្សេងគ្នា មានមន្ត្រីគ្រប់គ្រងកម្មវិធី និងគណៈគ្រប់គ្រងសាលារៀន ដើម្បីធ្វើបទសម្ភាសន៍ និងចងក្រងទិន្នន័យសម្ភាសន៍មកធ្វើការវិភាគ និងសំយោគ (Coding)។

ជាលទ្ធផល ការសិក្សាស្រាវជ្រាវនេះបានបង្ហាញអំពីស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សាក្នុងខេត្តត្បូងឃ្មុំ ស្ថិតក្នុងស្ថានភាពល្អបង្គួរ បើធៀបទៅនឹងស្តង់ដាកម្មវិធី។ ក្នុងចំណោមសមាសភាគទាំង ៦ របស់កម្មវិធីសាលាកុមារមេត្រី មានស្ថានភាពអនុវត្តខុសៗគ្នា ទៅតាមលក្ខខណ្ឌនៃសូចនាករនីមួយៗ។ សូចនាករដែលសាលារៀនធ្វើបានភាគច្រើន គឺពាក់ព័ន្ធការងាររដ្ឋបាលទូទៅ និងការគ្រប់គ្រងសាលារៀនតាមបែបកុមារមេត្រី។ ដោយឡែកបញ្ហាប្រឈមដែលសាលារៀនជួបប្រទះ និងអនុវត្តមិន

ទាន់មានប្រសិទ្ធភាព មានពីរចំណុចធំៗគឺ (១) ការងារបច្ចេកទេសបង្រៀននិងរៀន និង(២) ផ្នែកបរិស្ថានសិក្សា និងសម្ភារបូបន្ថែសម្រាប់គាំទ្រដំណើរការបង្រៀន និងរៀន។

ទន្ទឹមនឹងលទ្ធផល និងបញ្ហាប្រឈម ការសិក្សាក៏បានរកឃើញពីដំណោះស្រាយ និងសំណូមពរមួយចំនួនផងដែរ។ ដំណោះស្រាយជារួមផ្តោតលើភាគីពីរគឺៈ សាលារៀន និងក្រសួងអប់រំ ព្រមទាំងមន្ទីរអប់រំខេត្ត។ (១) ចំពោះភាគីសាលារៀន ត្រូវយកចិត្តទុកដាក់ ពង្រឹងលើការងារគ្រប់គ្រង ដឹកនាំ ការងារបរិស្ថាន បំណិនជីវិត យកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការសិក្សារបស់សិស្សឱ្យមានគុណភាព លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពជាប្រចាំ និងបង្កើនទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធឱ្យកាន់តែជិតស្និទ។ ភាគី (២) ក្រសួងអប់រំ និងមន្ទីរអប់រំខេត្ត ត្រូវពិនិត្យលើលក្ខខណ្ឌកម្មវិធីឡើងវិញ ផ្តល់ធនធានថវិកា និងសម្ភារបន្ថែមដើម្បីគាំទ្រដល់ការអនុវត្ត ព្រោះសូចនាករមួយចំនួននៅតែមិនអាចអនុវត្តបាន និងមិនមានប្រសិទ្ធភាព។

ជារួមការសិក្សាស្រាវជ្រាវនេះបានរកឃើញពីស្ថានភាពអនុវត្តកម្មវិធីកុមារមេត្រី ក្នុងខេត្តត្បូងឃ្មុំ និងបញ្ហាប្រឈមដែលជួបប្រទះ ព្រមទាំងបានផ្តល់នូវដំណោះស្រាយ ក៏ដូចជាសំណូមពរមួយចំនួនសម្រាប់ការអនុវត្តឱ្យកាន់តែមានស្តង់ដាខ្ពស់។

## Abstract

The development of child-friendly school programs is a key factor in transforming public primary schools in Cambodia in the direction of achieving the vision of education strategy and improving the quality of primary education with equity and environment. Separately, Tbong Khmum province is not different from other provincial capitals in the Kingdom of Cambodia, has implemented a child-friendly school program since the Ministry of Education launched a policy in 2008. In this regard, in order to understand the implementation status of this child-friendly school program, the researchers conducted a study on the implementation status of the child-friendly school program framework at the primary level in Tbong Khmum province with two main objectives (1) to study the implementation status of the program. Child-friendly schools in what situation and (2) understand the challenges encountered during implementation. The study also presents solutions to the challenges of implementing a child-friendly school program at the primary level.

To ensure that the results of this research are scientific, the researchers used a variety of methods, both quantitative and qualitative. Quantitative data collection was determined from 151 teachers selected from the three local primary schools in Tbong Khmum province and analyzed by SPSS. Qualitative data collection was selected from 12 samples from two different groups, with program managers and school management for interviews and compilation of interview data for analysis and coding.

As a result, this study shows that the implementation status of the child-friendly school program framework at the primary level in Tbong Khmum province is relatively good compared to the program standard. Of the six components of the Child Friendly School program, the implementation status varies according to the conditions of each indicator. Most of the indicators that the school has achieved are related to general administration and child-friendly school management. In particular, the challenges that schools face and do not implement effectively have two main points: (1) teaching and learning techniques and (2) the learning environment and physical materials to support the teaching and learning process.

Along with the results and challenges, the study also found some solutions and suggestions. The overall solution focuses on two parties: the school and the Ministry of

Education, as well as the provincial education department. (1) The school side must pay attention to strengthen the work of management, leadership, environment, life skills, pay attention to the effectiveness of students' learning quality, improve the development of capacity on a regular basis and increase communication with stakeholders. Close. Party (2) The Ministry of Education and the Provincial Department of Education must review the program conditions, provide additional financial resources and materials to support the implementation, as some indicators are still not applicable and ineffective.

Overall, this study found the implementation status of the Child Friendly Program in Tbong Khmum Province and the challenges encountered, as well as provided solutions as well as some suggestions for higher standard implementation.

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ..................... i

លិខិតបញ្ជាក់ ..................... ii

លិខិតឧទ្ទេសនាម ..................... iii

សេចក្តីថ្លែងអំណរគុណ ..................... iv

មូលន័យសង្ខេប ..................... viii

Abstract ..................... x

មាតិកា ..................... xii

បញ្ជីតារាង និងរូបភាព ..................... xv

បញ្ជីអក្សរកាត់ និងពាក្យបច្ចេកទេស ..................... xvi

ជំពូក១ ..................... ១

សេចក្តីផ្តើម ..................... ១

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ..................... ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ..................... ៥

១.៣ គោលបំណងស្រាវជ្រាវ ..................... ៦

១.៤ សំណួរស្រាវជ្រាវ ..................... ៦

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ..................... ៦

១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ..................... ៧

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..................... ៨

ជំពូក២ ..................... ១១

ការរំលឹកទ្រឹស្តី ..................... ១១

២.១ និយមន័យនៃពាក្យគន្លឹះ ..................... ១១

២.២ ក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី ..................... ១២

២.២.១ សមាសភាគទី១៖ ជានាកុមារទាំងអស់បានចូលរៀន ..................... ១៥

២.២.២ សមាសភាគទី២៖ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន ........ ១៧
២.២.៣.សមាសភាគទី៣៖ សុខភាព សុវត្ថិភាព និងការការពារកុមារ ........ ១៩
២.២.៤.សមាសភាគទី៤៖ ការឆ្លើយតបទៅនឹងយេនឌ័រ ........ ២១
២.២.៥.សមាសភាគទី៥៖ ការចូលរួមរបស់កុមារ មាតាបិតា និងសហគមន៍ ........ ២២
២.២.៦.សមាសភាគទី៦៖ ការគាំទ្រពីប្រព័ន្ធអប់រំ (ការដឹកនាំ និងគ្រប់គ្រង) ........ ២៥
**២.៣ សារៈប្រយោជន៍នៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី** ........ ២៨
**ជំពូក៣** ........ ៣២
**វិធីសាស្រ្តស្រាវជ្រាវ** ........ ៣២
**៣.១ ការជ្រើសរើសវិធីសាស្រ្តស្រាវជ្រាវ** ........ ៣២
**៣.២ វិធីសាស្ត្រជ្រើសរើសសំណាក** ........ ៣៣
៣.២.១ ការជ្រើសរើសសំណាកបរិមាណវិស័យ ........ ៣៤
៣.២.២ ការជ្រើសរើសសំណាកគុណវិស័យ ........ ៣៥
**៣.៣ ប្រភពទិន្នន័យ** ........ ៣៦
**៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ** ........ ៣៦
៣.៤.១ វិធីសាស្ត្របម្រូលទិន្នន័យតាមរយៈកម្រងសំណួរ ........ ៣៦
៣.៤.២ វិធីសាស្ត្រប្រមូលទិន្នន័យតាមរយៈការសម្ភាសន៍ផ្ទាល់ ........ ៣៧
**៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ** ........ ៣៨
៣.៥.១ ការវិភាគកម្រងសំណួរ ........ ៣៨
៣.៥.២ ការវិភាគសម្ភាសន៏ផ្ទាល់ ........ ៤១
**៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ** ........ ៤១
**ជំពូក៤** ........ ៤៤
**លទ្ធផល និងការពិភាក្សា** ........ ៤៤
**៤.១ លទ្ធផលបរិមាណវិស័យ** ........ ៤៥

៤.១.១ ព័ត៌មានទូទៅនៃភាគសំណាកដែលប្រមូលបាន ......................................................... ៤៥
៤.១.២ កម្រិតអនុវត្តលើសមាសភាគទី១ ......................................................................... ៤៩
៤.១.៣ កម្រិតអនុវត្តសមាសភាគទី២ ............................................................................. ៥៣
៤.១.៤ កម្រិតអនុវត្តលើសមាសភាគទី៣ ......................................................................... ៦០
៤.១.៥ កម្រិតអនុវត្តលើសមាសភាគទី៤ .......................................................................... ៦៦
៤.១.៦ ស្ថានភាពអនុវត្តលើសមាសភាគទី៥ ...................................................................... ៦៩
៤.១.៧ ស្ថានភាពអនុវត្តលើសមាសភាគទី៦ ....................................................................... ៧៤
៤.១.៨ សរុបលទ្ធផលរួមលើស្ថានភាពអនុវត្តសមាសភាគទាំង ៦ ............................................ ៧៧
**៤.២ លទ្ធផលគុណវិស័យ** ............................................................................................... ៧៨
**៤.៣ បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រី** ................................................... ៨០
៤.៣.១ ទស្សនៈប្រឈមរបស់មន្ត្រីគ្រប់គ្រងលើការអនុវត្តកម្មវិធីសាលាកុមារមេត្រី ........................ ៨០
៤.៣.២ ទស្សនៈប្រឈមរបស់គណៈគ្រប់សាលារៀនលើកម្មវិធីសាលាកុមារមេត្រី ........................... ៨៣
**៤.៤ ការពិភាក្សា** ........................................................................................................... ៨៥
**៤.៥ យោបល់របស់អ្នកឆ្លើយតប ទៅលើបញ្ហាប្រឈម** ......................................................... ៩០
**ជំពូក៥** ...................................................................................................................... ៩៣
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ................................................................................. ៩៣
**៥.១ សេចក្តីសន្និដ្ឋាន** ..................................................................................................... ៩៣
**៥.២ សំណូមពរ** ............................................................................................................... ៩៤
**៥.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត** ............................................................... ៩៧
**ឯកសារយោង** ........................................................................................................... ៩៨

# បញ្ជីតារាង និងរូបភាព


រូបភាព ៤.១.១.១ ចំនួនអ្នកឆ្លើយតបគិតតាមភេទ ..........................................................................................៤៥

រូបភាព ៤.១.១.២ ចំនួនអ្នកឆ្លើយតបគិតតាមអាយុ.......................................................................................៤៦

រូបភាព ៤.១.១.៣ ចំនួនអ្នកឆ្លើយតបគិតតាមកម្រិតវប្បធម៌............................................................................ ៤៧

រូបភាព ៤.១.១.៤ ចំនួនអ្នកឆ្លើយតបគិតតាមបទពិសោធន៍ការងារ....................................................................៤៨

តារាង១ កម្រិតអនុវត្តលើការធានាកុមារចូលរៀន .........................................................................................៥០

តារាង២ ការងារបច្ចេកទេសបង្រៀន និងរៀន ............................................................................................ ៥៣

តារាង៣ សម្ភារគាំទ្រកិច្ចដំណើរការសិក្សារៀនសូត្រ.......................................................................................៥៦

តារាង៤ ផ្តោតលើការផ្តល់សេវា និងការអភិវឌ្ឍសមត្ថភាព............................................................................ ៥៧

តារាង៥ សុខភាពសិក្សា ...........................................................................................................................៦១

តារាង៦ សុវត្ថិភាព និងការការពារកុមារ ..................................................................................................... ៦៣

តារាង៧ ការឆ្លើយតបនឹងយេនឌ័រ............................................................................................................. ៦៧

តារាង៨ ការចូលរួមពីភាគីពាក់ព័ន្ធ ............................................................................................................ ៧០

តារាង៩ ការគ្រប់គ្រង ដឹកនាំ ................................................................................................................... ៧៤

តារាង១០ កម្រិតអនុវត្តលើសមាសភាគទាំង ៦ ...........................................................................................៧៧

តារាង១១ លទ្ធផលគុណវិស័យ.................................................................................................................. ៧៨

តារាង១២ ទស្សនៈប្រឈមលើការអនុវត្តកម្មវិធីសាលាកុមារមេត្រី ................................................................ ៨៣

# បញ្ជីអក្សរកាត់ និងពាក្យបច្ចេកទេស

- CFS : កម្មវិធីសាលាកុមារមេត្រី
- DTMT : ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក
- UNICEF : មូលនិធិសង្គ្រោះកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ ( យូនីសេហ្វ )
- KAPE : អង្គការសកម្មភាពអប់រំ នៅកម្ពុជា ( ខេប )
- NCP : គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ
- M : តម្លៃមធ្យមពិន្ទុ
- SD : គម្លាតស្តង់ដា
- ALPHA : តម្លៃអាល់ហ្វា
- SPSS : កម្មវិធីវិភាគទិន្នន័យ
- EMIS : ប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានសាលារៀន
- CODING : ការប្រមូល ចងក្រងគំនិត និងសំយោគគំនិត
- #D : លេខកូដកិច្ចសម្ភាសន៍គណៈគ្រប់គ្រងសាលា
- #Stuff : លេខកូដកិច្ចសម្ភាសន៍ជាមួយមន្ត្រីមន្ទីរ អយក និងការិយាល័យ អយក

# ជំពូក១

# សេចក្តីផ្តើម

# ជំពូក១

# សេចក្តីផ្តើម

ជំពូកនេះ បានបកស្រាយពីសេចក្តីផ្តើមនៃការសិក្សាស្រាវជ្រាវ។ ជំពូកនេះបានពន្យល់បកស្រាយពី លំនាំបញ្ហានៃការស្រាវជ្រាវ បញ្ហាស្រាវជ្រាវ គោលបំណង សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការអប់រំនៅកម្ពុជា បានឆ្លងកាត់នូវបរិបទសង្គម និងរបបនយោបាយជាច្រើនសម័យកាល ដែលក្នុង នោះមានទាំងសម័យកាលរីកចម្រើន និងសម័យកាលដែលប្រព័ន្ធអប់រំស្ទើរតែធ្លាក់ដល់ចំណុចសូន្យ។ កាលពី សម័យដើម ការអប់រំនៅកម្ពុជាបានជ្រកកោននៅក្នុងគ្រឹះស្ថានព្រះពុទ្ធសាសនា ដែលមានវត្តអារាមជាកន្លែង សិក្សារៀនសូត្រ និងមានព្រះសង្ឃ ឬអាចារ្យជាអ្នកបង្រៀន (ត្រឹម ងា ១៩៧៣)។ ក្រោយមកទៀតឆ្លងចូល ដល់សម័យសង្គមរាស្ត្រនិយម យើងឃើញថាការអប់រំនៅកម្ពុជាបានហាក់ឡើងមួយកម្រិត ដោយកម្មវិធីសិក្សា ផ្អែកលើគុណភាពនៃការសិក្សាជាចម្បង ដែលមាននិស្សិតមួយចំនួន អាចបន្តការសិក្សានៅក្រៅប្រទេសទៀត ផង។ ថ្វីត្បិតប្រព័ន្ធអប់រំសម័យនោះមានភាពរីកចម្រើន ក៏ប៉ុន្តែ អត្រាសិស្ស និស្សិត ដែលបានចូលរៀន និង បញ្ចប់ការសិក្សា មានចំនួនតិច ជាពិសេសពុំមានសាលារៀន ដែលធ្វើឱ្យការផ្តល់សេវាអប់រំនៅមូលដ្ឋានមាន ភាពលំបាក ហើយតំបន់ខ្លះជាតំបន់ដាច់ស្រយាលទៀត ហាក់មិនទទួលបានការអប់រំទាល់តែសោះ។ ក្រោយ មកដល់ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ កម្ពុជាបានធ្លាក់ចូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលពេលនោះ ប្រព័ន្ធអប់រំរបស់រដ្ឋទាំងមូលត្រូវបិទ សាលារៀនត្រូវបានបំផ្លិចបំផ្លាញ និងបានទាញឱ្យវិស័យអប់រំធ្លាក់ចុះដល់ ចំណុចសូន្យ។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ពីបាតដៃទទេ កម្ពុជាបានចាប់ផ្តើមដំណើរការប្រព័ន្ធអប់រំ ឡើងវិញ តាមរយៈការរៀបចំសាលារៀន និងទីកន្លែងសម្រាប់សិស្សានុសិស្ស បានបន្តការសិក្សារៀនសូត្រ តាមលទ្ធភាពដែលអាចធ្វើបាន។ នាពេលនោះយើងគ្មានលទ្ធភាពនឹកកសាងសាលារៀនថ្មី និងផ្តល់ប្រាក់ខែ ឱ្យគ្រូបង្រៀន ឬបើកវគ្គបណ្តុះបណ្តាលគ្រូតាមបែបបទគរុកោសល្យអ្វីទេ គឺការសិក្សារៀនសូត្រដោយប្រើយុទ្ធ

សាស្ត្រ «អ្នកចេះច្រើន បង្រៀនអ្នកចេះតិច អ្នកចេះតិច បង្រៀនអ្នកមិនចេះសោះ» (ស៊ិន សំណាង ១៩៩៩)។ រហូតមកដល់សម័យព្រះរាជាណាចក្រកម្ពុជា ក្រោមការរៀបចំយុទ្ធសាស្ត្រដឹកនាំរបស់ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានកំណត់វិស័យអប់រំជាវិស័យអាទិភាពមួយ ក្នុងចំណោវិស័យសំខាន់ៗផ្សេងទៀត ទើបប្រព័ន្ធអប់រំទាំងមូលមានភាពរឹងប៉ឹង និងអាចអភិវឌ្ឍខ្លួនរីកចម្រើនបន្តិចម្តងៗ រហូតមកដល់ពេលបច្ចុប្បន្ននេះ។

ក្នុងន័យនេះ ពីមួយឆ្នាំទៅមួយឆ្នាំ ក្រសួងអប់រំ យុវជន និងកីឡា ដែលជាសេនាធិការផ្ទាល់ទទួលបន្ទុកការងារអប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស របស់ប្រមុខរាជរដ្ឋាភិបាល បានដាក់ចេញនូវផែនការ និងយុទ្ធសាស្ត្រនានា ធ្វើយ៉ាងណាដើម្បីបន្តស្តារ និងអភិវឌ្ឍវិស័យមួយនេះ ឱ្យមានភាពរីកចម្រើនសំដៅបង្កើនទាំងបរិមាណ និងគុណភាពនៃធនធានមនុស្សដែលទទួលបាន។ ក្នុងចំណោមផែនការ និងយុទ្ធសាស្ត្រនានា ដែលក្រសួងអប់រំបានសិក្សាដកបទពិសោធន៍នៃការអប់រំទាំងនៅក្នុងប្រទេស និងដកយកបទពិសោធន៍នៃការអប់រំរបស់ប្រទេសអភិវឌ្ឍមួយចំនួន ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តនូវកម្មវិធីមួយឈ្មោះថា កម្មវិធីសាលាកុមារមេត្រី សម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈទាំងអស់នៅទូទាំងប្រទេស ដែលផ្តោតលើចំណុចមូលដ្ឋានគ្រឹះនៃការអប់រំជាកត្តាចម្បង។

សាលាកុមារមេត្រី ជាសាលារៀនដែលជួយគាំទ្រនូវលទ្ធផលសិក្សារបស់សិស្សដោយផ្អែកលើសិទ្ធិកុមារជាមូលដ្ឋាន។ សាលាកុមារមេត្រីសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ មានមាតាបិតា អាណាព្យាបាលសិស្ស និងផ្តល់តម្លៃខ្ពស់ដល់ការងារអប់រំ ដោយខិតខំប្រឹងប្រែងរួមចំណែកក្នុងការស្វែងរកកុមារឱ្យចូលរៀនគ្រប់ៗគ្នា និងបង្កើតបរិស្ថានសិក្សាដ៏កក់ក្តៅ សំដៅឱ្យកុមារទាំងនោះបានចូលរៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព ស្របតម្រូវការជាក់ស្តែងរបស់ពួកគេ (ក្រសួងអយក ២០០៧)។

សាលាកុមារមេត្រី គឺជាក្របខ័ណ្ឌទូលំទូលាយមួយដែលមានគ្រប់ផ្នែកនៃការងារទាំងអស់របស់សាលារៀន រួមមានការគ្រប់គ្រងសាលារៀន សុខភាព និងសុវត្ថិភាព យេនឌ័រ និងទំនាក់ទំនងសាលារៀន និងសហគមន៍ និងការគាំទ្ររបស់ប្រព័ន្ធអប់រំ (ក្រសួងអយក ២០០៧)។

សាលាកុមារមេត្រីជាអន្តរាគមន៍ចម្បងមួយ នៅក្នុងគោលនយោបាយជាអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ២០០៨)។ សាលាកុមារមេត្រីត្រូវបានអនុវត្តសាកល្បងនៅតាមខេត្តគោលដៅមួយចំនួន ដោយដៃគូអភិវឌ្ឍន៍ចាប់ពីឆ្នាំ២០០២។ នៅឆ្នាំ២០០៤ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាបានចុះធ្វើទស្សនកិច្ចសិក្សា និងវាយតម្លៃការអនុវត្តកម្មវិធីសាលា កុមារមេត្រីរបស់ដៃគូអភិវឌ្ឍន៍ ហើយបន្ទាប់មកក៏សម្រេចបង្កើតឱ្យមានគោលនយោបាយថ្នាក់ជាតិ សម្រាប់ការអនុវត្តសាលា កុមារមេត្រីនៅបឋមសិក្សានៅឆ្នាំ២០០៥ (ក្រសួងអយក ២០១៩)។ ជាលទ្ធផល ក្របខ័ណ្ឌសាលាកុមារមេត្រីមួយត្រូវបានបង្កើតឡើងក្រោម កិច្ចសហប្រតិបត្តិការជាមួយអង្គការ UNICEF អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE) និងអង្គការសង្គ្រោះកុមារ ន័រវេ ដើម្បីជាជំនួយក្នុងកសាងឯកសារ និងការអនុវត្តសកម្មភាពសាលាកុមារមេត្រីនៅតាមសាលារៀន។

ក្របខ័ណ្ឌនេះផ្តោតទៅលើសមាសភាគចំនួនប្រាំមួយដូចខាងក្រោម៖

១. ការចូលរៀនប្រកបដោយសមធម៌

២. ប្រសិទ្ធភាពនៃការបង្រៀន និងរៀន

៣. សុខភាព សុវត្ថិភាព និងការការពារកុមារ

៤. ការឆ្លើយតបទៅនឹងយេនឌ័រ

៥. ការចូលរួមរបស់កុមារ មាតាបិតា និងសហគមន៍

៦. ការគាំទ្រពីប្រព័ន្ធអប់រំ (ការដឹកនាំ និងគ្រប់គ្រង)។

គោលនយោបាយសាលាកុមារមេត្រីនេះ ត្រូវពង្រីកទៅដល់ការអប់រំកម្រិតមូលដ្ឋាននៅឆ្នាំ២០១៣ ដោយបង្កើត ឱ្យមានក្រុម DTMT (ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក) ចំនួនបីក្រុមគឺ៖ ក្រុមទី១ ទទួលបន្ទុកការពិនិត្យតាមដាន និងវាយតម្លៃសាលារៀននៅអប់រំកម្រិតមូលដ្ឋាន ក្រុមទី២ ទទួលបន្ទុកការបង្រៀន និងរៀននៅបឋមសិក្សា និងក្រុមទី៣ ទទួលបន្ទុកការបង្រៀន និងរៀននៅមធ្យមសិក្សា។ តួនាទី សំខាន់មួយទៀតរបស់ DTMT គឺការកសាងសមត្ថភាពដល់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសហគមន៍ រួមទាំង

គណៈកម្មការទ្រទ្រង់សាលារៀន និងអាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យពួកគេអាចចូលរួមពេញលេញក្នុងការលើកកម្ពស់គុណភាព និងសកម្មភាពអប់រំទាំងឡាយ ដែលមាននៅក្នុងមូលដ្ឋានរបស់ពួកគេ (ក្រសួងអយក ២០០៧)។

នៅឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការ UNICEF រៀបចំការវាយតម្លៃការអនុវត្តសាលា កុមារមេត្រីក្នុងរយៈពេលដប់ឆ្នាំចុងក្រោយដោយក្រុមវាយតម្លៃដែលជាភាគីទីបី។ ការវាយតម្លៃនេះបានចង្អុលបង្ហាញនូវ មេរៀនជាបទពិសោធដូចខាងក្រោម៖

- បញ្ជីពិនិត្យតាមដាន និងវាយតម្លៃ មានសារៈប្រយោជន៍ក្នុងការលើកកម្ពស់ការអនុវត្តសាលាកុមារមេត្រី គុណភាពអប់រំ និងលទ្ធផលសិក្សារបស់សិស្ស។
- ការពង្រីកគោលនយោបាយសាលាកុមារមេត្រី តម្រូវឱ្យមានផែនការជាប្រព័ន្ធពីដំបូង និង មានធនធានគ្រប់គ្រាន់ ក្នុងការអនុវត្ត។
- រៀបចំការពិនិត្យតាមដាន និងវាយតម្លៃ ព្រមទាំងយន្តការឱ្យបានច្បាស់លាស់នៅក្នុងបរិបទអធិការកិច្ចបែបធានា គុណភាព (អធិការផ្ទៃក្នុង-DTMT និងអធិការផ្ទៃក្រៅ-អធិការមន្ទីរ)។
- ការលើកកម្ពស់ប្រសិទ្ធភាពខាងក្នុងសាលារៀនមិនគ្រប់គ្រាន់ទេ វាទាមទារឱ្យមានការចូលរួម ពីភាគីពាក់ព័ន្ធ នៅក្នុងមូលដ្ឋាន ដើម្បីធានានិរន្តរភាពនៃការអនុវត្តសាលាកុមារមេត្រី។ សកម្មភាព ទាំងនោះមានដូចជា៖ តាមដាន វត្តមានគ្រូ និងសិស្ស ជំរុញសិស្សបោះបង់ការសិក្សាឱ្យចូលរៀនវិញ រៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិនៅក្នុង សាលា ដើម្បីធ្វើឱ្យសាលារៀនមានការទាក់ទាញ ជាដើម។

ក្នុងទិសដៅឆ្ពោះទៅសម្រេចផែនការអប់រំជាតិ និងលើកកម្ពស់គុណភាពអប់រំនៅកម្ពុជាឱ្យកាន់តែមានបរិមាណ និងគុណភាព និងសម្រេចផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ ជាពិសេសដើម្បីឆ្លើយតបទៅនឹងការអនុវត្តសិទ្ធិកុមារ ការអភិវឌ្ឍកម្មវិធីសាលាកុមារមេត្រី គឺជាកត្តាគន្លឹះក្នុងយុទ្ធសាស្ត្របណ្តុះបណ្តាលអ្នក

អប់រំ ឱ្យមានសម្ថភាព និងផ្តល់ដល់កុមារនូវការអប់រំប្រកបដោយសមធម៌ និងគុណភាព (ក្រសួងអយក ២០១៩)។

ឈរលើទស្សនៈទាំងនេះ ក្នុងនាមអ្នកស្រាវជ្រាវមួយរូប ពិតជាចង់ដឹង និងស្វែងយល់ ថាតើការអនុវត្តកម្មវិធីសាលាកុមារមេត្រី នៅតាមសាលាបឋមសិក្សាទទួលបានលទ្ធផលបែបណា និងមានផលជះអ្វីខ្លះទៅលើសាលារៀន មានគណៈគ្រប់គ្រង គ្រូបង្រៀន សិស្សានុសិស្សជាដើម។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងតាមកំណើនអត្រាចូលរៀនខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំរកគន្លឹះជាច្រើនដើម្បីបង្កើនប្រសិទ្ធភាពបង្រៀន និងរៀន ពិសេសបង្កើនអត្រាឡើងថ្នាក់ កាត់បន្ថយអត្រាបោះបង់ តាមរយៈការបង្រៀនបំប៉ន កម្មវិធីបំប៉នថ្ងៃព្រហស្បតិ៍ ជាដើម (ក្រសួងអយក ២០១៩)។ ប៉ុន្តែវិធានការណ៍ទាំងនោះមិនគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាបានឡើយ។ ហេតុនេះដើម្បីឱ្យស្របតាមនិន្នាការអប់រំពិភពលោកបច្ចុប្បន្ន ដែលបាញ់ឆ្ពោះទៅលើការអនុវត្ត សិទ្ធិកុមារ ជាមូលដ្ឋាន និងពេញលេញដែលធានាដល់ការចូលរៀនរបស់កុមារគ្រប់ប្រភេទប្រកបដោយសមធម៌ និងគ្មានការរើសអើង ក្រសួងអប់រំបានយកចិត្តទុកដាក់បង្កើតកម្មវិធីសាលាកុមារមេត្រីនេះឡើង។ ស្របពេលដែលក្រសួងបានដាក់ចេញកម្មវិធីនេះ យើងឃើញថាគ្រឹះស្ថានសិក្សាសាធារណៈទាំងអស់បានអនុវត្តក្នុងកិច្ចដំណើរការសាលារៀនរបស់ខ្លួនដោយបានលទ្ធផលល្អប្រសើរ រីឯសាលារៀនមួយចំនួនភាគច្រើនហាក់មិនបានអនុវត្តស្របតាមគោលការណ៍ណែនាំនៅឡើយទេ (សន្និបាទអប់រំ ២០១៩)។ សាលារៀនភាពច្រើននៅតែបន្តសកម្មភាពតាមបែបប្រពៃណីទាំងការគ្រប់គ្រងដឹកនាំ និងការងារបង្រៀន និងរៀនជាពិសេសពុំបានយកចិត្តទុកដាក់លើធាតុស្នូលសំខាន់ៗទាំង៦ នៃកម្មវិធីសាលាកុមារមេត្រីទៀតផង។ ការកែទម្រង់វិស័យអប់រំ គឺជាការកែទម្រង់សាលារៀន និងថ្នាក់រៀនឱ្យមានភាពទាន់សម័យជាងមុន (ហង់ ជួនណារ៉ុន ២០២០)។

ដោយមើលឃើញគម្លាតវិសមភាពនៃការអនុវត្តក្របខ័ណ្ឌគោលនយោបាយនេះ រវាងសាលារៀននៅតំបន់ប្រជុំជន និងសាលារៀននៅតំបន់ដាច់ស្រយ៉ាល ទើបក្នុងនាមអ្នកស្រាវជ្រាវមួយរូប នឹងធ្វើការសិក្សាឱ្យ

កាន់តែស៊ីជម្រៅបន្ថែមទៀតថាតើ សាលារៀនដែលមិនអាចអនុវត្តកម្មវិធីសាលាកុមារមេត្រី ឱ្យមានប្រសិទ្ធភាពបាន បណ្តាលមកពីមូលហេតុអ្វីខ្លះ?

## ១.៣ គោលបំណងស្រាវជ្រាវ

ការសិក្សានេះ មានគោលបំណងសិក្សា និងស្វែងយល់ពីចំណុចសំខាន់ៗមួយចំនួន រួមមាន៖

(១) ស្វែងយល់ពីការយល់ដឹងរបស់នាយក នាយិកា លើក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី

(២) រកឱ្យឃើញពីកម្រិតលទ្ធផល នៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី នៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ

(៣) រកឱ្យឃើញបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីទទួលបាននូវលទ្ធផលនៃការស្រាវជ្រាវមួយដែលមានភាពច្បាស់លាស់ សុក្រឹត ឆ្លុះបញ្ចាំងពីបរិបទការងារ និងអាចយកជាផ្លូវការបាន ខ្ញុំបានប្រើប្រាស់សំណួរស្រាវជ្រាវចំនួនពីរ គឺ៖

(១) តើគណៈគ្រប់គ្រងសាលាមានការយល់ដឹងកម្រិតណាលើក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី?

(២) តើការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី នៅកម្រិតបឋមសិក្សាមានលក្ខណៈបែបណាខ្លះ?

(៣) តើមានបញ្ហាប្រឈមអ្វីខ្លះលើការអនុវត្តកម្មវិធីសាលាកុមារមេត្រី ចំពោះគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ ខ្ញុំនឹងបែងចែកវាជាបីផ្នែកសំខាន់ៗគឺ ទីមួយខ្ញុំនឹងរកឲ្យឃើញថា ការគ្រប់គ្រង និងអនុវត្តន៍កម្មវិធីសាលាកុមារមេត្រីមានលក្ខណៈបែបណា។ ទីពីរ វិភាគលើលទ្ធផលដែលទទួលបានពីការស្រាវជ្រាវ ខ្ញុំនឹងធ្វើការបកស្រាយ ក្នុងន័យបំពេញបន្ថែម លើខ្លឹមសារនៃការអនុវត្តដែលបានដាក់ចេញសម្រាប់នាយកសាលា សម្រាប់លោកគ្រូ អ្នកគ្រូ មាតាបិតាអាណាព្យាបាលសិស្ស និងសិស្សានុសិស្សផ្ទាល់ ដោយផ្តោលលើមជ្ឈដ្ឋានសិក្សានីមួយៗ។ម្យ៉ាងវិញទៀត ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលបានពី

ការស្រាវជ្រាវនេះ នឹងផ្តល់នូវអនុសាសន៍ណែនាំនឹងជួយបំពេញបន្ថែម រាល់កង្វះខាត លើការងារគ្រប់គ្រងសាលារៀនតាមបែបកុមារមេត្រី សមភាព និងសមធម៌នៃការទទួលសេវាអប់រំ បរិស្ថានសិក្សា ជាពិសេសការធានាបាននូវប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស ជូនដល់លោកនាយក/នាយិកា ក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រីទាំងអស់ស្របស្តង់ដារនៃកម្មវិធី។ ទីបី ខ្ញុំនឹងរកឱ្យឃើញពីភាពអសកម្មដែលមិនអាចអនុវត្តបានសម្រាប់កម្មវិធីមួយនេះ ហើយថាតើត្រូវរកដំណោះស្រាយដោយរបៀបណា។ ហេតុផលបីនេះហើយ ទើបខ្ញុំសម្រេចជ្រើសរើសយកសាលានៅ ក្នុងខេត្តត្បូងឃ្មុំ មកសិក្សាជាសាលាសំណាកដើម្បីស្វែករកលទ្ធផល។

ផលចំណេញដែលទទួលបានសំខាន់បំផុតគឺ ដឹងពីតម្រូវការជាក់ស្តែងរបស់កុមារក្នុងតំបន់ចំណុះសាលារៀន ដែលផ្តល់ព័ត៌មានដល់យើងជាអ្នកស្រាវជ្រាវ ហើយ ផ្តល់លទ្ធផលនៃការស្រាវជ្រាវជូនដល់លោកនាយក/នាយិកាសម្រាប់កែលម្អការគ្រប់គ្រងដឹងនាំ អនុវត្តន៍កម្មវិធីសាលាកុមារមេត្រីប្រកបដោយស្តង់ដារជាងមុន ជាពិសេសបានបញ្ជ្រាបកាន់តែទូលំទូលាយ ដល់សហគមន៍ និងមាតាបិតា អាណាព្យាបាលសិស្ស ដើម្បីឱ្យពួកគាត់បានយល់ និងជួយគាំទ្រសមកម្មភាពអប់រំនៅមូលដ្ឋានប្រកបដោយទំនុកចិត្ត ជំនឿចិត្ត និងការទទួលខុសត្រូវជាមួយសាលារៀន។ លើសពីនេះកុមារខ្លួនឯងផ្ទាល់ក៏កាន់តែដឹង និងឈ្វេងយល់ពីកាតព្វកិច្ច និងការទទួលបាននូវសិទ្ធសេរីភាព សមភាពយេនឌ័រ ឱកាស និងការគាំពារផ្សេងទៀតចំពោះពួកគេផ្ទាល់។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ សិក្សាស្វែងយល់ពីស្ថានភាព នៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី និងធ្វើឡើងតែនៅក្នុងសាលាកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំតែប៉ុណ្ណោះ ដូច្នេះចំពោះលទ្ធផលនៃការស្រាវជ្រាវ គឺពុំបានឆ្លុះបញ្ចាំងពីនានាភាពនៃក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅទូទាំងប្រទេសឡើយ។ ការសិក្សានេះ នៅមានកម្រិតដែលការសិក្សាបន្ថែមអាចធ្វើឲ្យកាន់ប្រសើរមួយចំនួនដូចជា វិធីសាស្ត្រស្រាវជ្រាវ និងការពន្យល់បកស្រាយលទ្ធផលស្រាវជ្រាវ ចំនួនសំណាកដែលបានប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ នេះ

នៅមានកម្រិត និងសម្រាប់ការវិភាគ។ ចំណែកការពន្យល់បកស្រាយលទ្ធផលស្រាវជ្រាវ ក៏នៅពុំទាន់បានស៊ីជម្រៅ និងក្បោះក្បាយលម្អិតផងដែរ។

សម្រាប់កង្វះខាតលើខ្លឹមសារ ឬការស្រាវជ្រាវពុំមានលក្ខណៈពេញលេញ ស្របតាមអ្វីដែលអ្នកសិក្សាចង់បាន ក្នុងនាមអ្នកស្រាវជ្រាវ សូមលើកទឹកចិត្តឱ្យមានការសិក្សាស្រាវជ្រាវបន្តទៀត ដើម្បីបំពេញបន្ថែមលើចំណុចខ្វះខាត និងធ្វើបច្ចុប្បន្នភាពលើខ្លឹមសារឱ្យស្របតាមមជ្ឈដ្ឋានសិក្សា និងបរិបទសង្គមជាក់ស្តែង។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សានេះ ត្រូវបានបែងចែកជា៥ជំពូក។ ជំពូក១ បង្ហាញពីសេចក្តីផ្តើម រួមមាន លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។ ជំពូក២ ពន្យល់បកស្រាយពីរំលឹកទ្រឹស្តីដោយការបង្ហាញពីនិយមន័យពាក្យគន្លឹះ និយាយពីទ្រឹស្តីជាច្រើនជុំវិញការដឹកនាំ ស្តង់ដានាយក និងទ្រឹស្តីឧត្តមភាពបុគ្គលផ្សេងៗទៀត។ជំពូក៣ បង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ រួមមានការជ្រើសរើសវិធីសាស្ត្រ ការជ្រើសរើសសំណាក ប្រភពទិន្នន័យ វិធីប្រមូលទិន្នន័យ វិធីសាស្ត្រវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។ជំពូក ៤ នឹងពន្យល់បកស្រាយពីលទ្ធផលស្រាវជ្រាវ (ស្ថានភាពនៃការអនុវត្តន៍ក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ) និងការវិភាគទិន្នន័យដើម្បីរកទិន្នន័យដើម្បីរកលទ្ធផលស្រាវជ្រាវ (ស្ថានភាពនៃការអនុត្តន៍កម្មវិធី បញ្ហាប្រឈម និងដំណោះស្រាយរបស់គណៈគ្រប់គ្រងសាលារៀន) និងការពិភាក្សាលើលទ្ធផលស្រាវជ្រាវនិងការពិភាក្សាជាលទ្ធផលស្រាវជ្រាវ។ជំពូកទី៥ នឹងបង្ហាញពីសេចក្តីសន្និដ្ឋាន និងអនុសាសន៍អំពី ការអនុត្តន៍កម្មវិធីសាលាកុមារមេត្រីបានល្អ និងមានប្រសិទ្ធភាពរបស់គណៈគ្រប់គ្រងសាលារៀនបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ។

# ជំពូក២

# ការរំលូតកូនស្ត្រី

# ជំពូក២

# ការរំលឹកទ្រឹស្តី

ជំពូកនេះ និងពន្យល់បកស្រាយពីនិយមន័យពាក្យគន្លឹះ និងចំណុចគន្លឹះមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវ។ ជំពូកនេះ ក៏នឹងបង្ហាញអំពីសូចនាករនានា ដែលសាលារៀនត្រូវអនុវត្តសម្រាប់កិច្ចគាំទ្រដល់កម្មវិធីសាលាកុមារត្រី និងចំណុចពាក់ព័ន្ធមួយចំនួនទៀត លើការងារគ្រប់គ្រងដឹកនាំសាលារៀនតាមបែបសាលាកុមារមេត្រី។

## ២.១ និយមន័យនៃពាក្យគន្លឹះ

ការសិក្សានេះ បានលើកឡើងពីនិយមន័យនៃពាក្យគន្លឹះចំនួនពីរ រួមមាន «ស្ថានភាព» «ក្របខ័ណ្ឌ» និង «កម្មវិធីសាលាកុមារមេត្រី»។ ពាក្យគន្លឹះទាំងនេះ ត្រូវបានបកស្រាយដូចខាងក្រោម៖

### ២.១.១ ស្ថានភាព

ស្ថានភាព (នាមសព្ទ): បែបបទ, កិច្ចដំណើរការ, ដំណើរការដែលប្រព្រឹត្តទៅ

(ជួន ណាត ១៩៦៧)

ស្ថានភាពសំដៅលើសំណុំនៃកាលៈទេសៈ ករណី ឬបែបបទរបៀបរបបនៃការធ្វើសកម្មភាពអ្វីមួយមានលក្ខណៈច្បាស់លាស់ តឹងតែង ហ្មត់ចត់ ឬធូររលុង តាមកិច្ចការជាក់ស្តែង (ក្រសួងអយក ២០០៩)។

### ២.១.២ ក្របខ័ណ្ឌ

ក្របខ័ណ្ឌសំដៅដល់ឯកសារផែនការដែលកំណត់សំណុំស្តង់ដានៃកម្មវិធី ឬការសិក្សានៃភូមិសិក្សានានា ព្រមទាំងផ្តល់នូវបរិបទក្នុងការកំណត់សូចនាករ ឬមាតិកា ដែលត្រូវអនុវត្ត ព្រមទាំងផ្តល់នូវលក្ខខណ្ឌនៃការវាយតម្លៃផងដែរ (រាជរដ្ឋាភិបាល ២០១៩)។

នៅក្នុងន័យការសិក្សាស្រាវជ្រាវ ក្របខ័ណ្ឌមានន័យថា បណ្តុំនៃទ្រឹស្តី ឬរចនាសម្ព័ន្ធនៃគំនិតដែលលើកយកមកអនុវត្តដោយមានភស្តុតាងរឹងមាំនៃស្តង់ដារសិក្សាស្រាវជ្រាវ។

### ២.១.៣ កម្មវិធីសាលាកុមារមេត្រី (CFS)

កម្មវិធីសាលាកុមារមេត្រី គឺជាកម្មវិធីមួយដែលដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡា ដោយផ្តោតការយកចិត្តទុកដាក់លើកុមារជាចម្បង ។ សាលាកុមារមេត្រី គឺជាសាលារៀនដែលទទួលស្គាល់គាំទ្រនូវលទ្ធផលសិក្សារបស់សិស្សដោយផ្អែកលើសិទ្ធិកុមារជាមូលដ្ឋាន ។ កម្មវិធីសាលាកុមារមេត្រីនេះ បានរំលេចចេញនូវសមាសភាពទាំង ៦ ចំណុច សម្រាប់ឱ្យគណៈគ្រប់គ្រងតាមសាលារៀនយកទៅអនុវត្តន៍ និងគាំទ្រដល់សិទ្ធកុមារជាមូលដ្ឋាន ដោយផ្តល់នូវបរិស្ថានសិក្សាជាទីស្រឡាញ់ចូលចិត្តរបស់កុមារគ្រប់ៗរូប (ក្រសួងអយក ២០០៧) ។ លើសពីនេះ សាលាកុមារមេត្រី មានគោលការណ៍សហការយ៉ាងជិតស្និតជាមួយអ្នកពាក់ព័ន្ធទាំងអស់រួមមានមាតាបិតា អាណាព្យាបាលសិស្ស អាជ្ញាធរដែនដី អង្គការនានា សម្បុរសជនទាំងអស់ និងក្រសួងអប់រំទាំងមូល ដើម្បីជួយគាំទ្រ ដល់កិច្ចដំណើរការឱ្យមានប្រសិទ្ធភាព និងគុណភាព ។ បរិស្ថានសិក្សាសាលាកុមារមេត្រី បង្ហាញនូវលក្ខណៈសមធម៌ សមភាព សេរីភាព សាមគ្គីភាព គ្មានអំពើហិង្សា រួមទាំងសុខភាពរាងកាយ បញ្ញា និងផ្លូវចិត្តដែលជាកិច្ចជានាក្នុងការអភិវឌ្ឍកុមារឱ្យមានសមត្ថភាពប្រកបដោយចំណេះដឹង បំណិន ឥរិយាបទ តម្លៃ និងសីលធម៌ល្អដើម្បីឱ្យពួកគេចេះរួមរស់នៅជាមួយគ្នាក្នុងភាពសុខដុមរមនា (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ២០០៨)។

## ២.២ ក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី

ការរៀននៅក្នុងបរិយាកាសរីករាយ គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពចម្បងនៅក្នុងសាលារៀន ជាពិសេសសម្រាប់ថ្នាក់បឋមសិក្សា ហើយការអប់រំ គឺជាការលើកទឹកចិត្តសិស្សឱ្យស្រឡាញ់ការរៀនសូត្រសម្រាប់ជាប្រយោជន៍របស់ខ្លួន ជាជាងផ្តោតលើចំណេះដឹងបែបវិទ្យាសាស្ត្រតែមួយមុខ(Barrow & Woods, 2006)។ ម៉្យាងទៀត សាលាបឋមសិក្សាមានគោលបំណងគឺធ្វើឱ្យសិស្សានុសិស្សរីករាយនឹងការរៀនសូត្រដើម្បីផលប្រយោជន៍របស់ពួកគេ ដែលសាលា និងអ្នកអប់រំត្រូវតែបង្កើតបរិយាកាសរីករាយ។

ការសិក្សាស្រាវជ្រាវ បានបង្ហាញថាបរិយាកាសសិក្សាគឺជាអថេរដ៏សំខាន់មួយ ដែលជាទូទៅជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស ធ្វើឱ្យសិស្សកាន់តែមានការលើកទឹកចិត្ត ដែលនាំឱ្យបង្កើនលទ្ធផលសិក្សារបស់ពួកគេ (Aldridge & Fraser, 2011)។ លើសពីនេះទៀតការសិក្សាមានគោលបំណងឈានទៅរកការអប់រំ

ប្រកបដោយគុណភាព ភាពរីករាយ ដែលមិនរើសអើងសិស្សក្នុងផ្នែកសាសនា ពូជសាសន៍ភេទ ពណ៌ស្បែក និងភាសា។ គុណភាពនៃការអប់រំ គឺជាការអប់រំដែលដំណើរការសម្រាប់កុមារគ្រប់រូប និងអនុញ្ញាតឱ្យកុមារទាំងអស់ទទួលបានសក្តានុពលពេញលេញតាមសមត្ថភាពរបស់ពួកគេ។ គុណភាព ការអប់រំនេះទាក់ទងទៅនឹងគុណភាពនៃការបង្រៀន និងការរៀនដែលអាចសម្រេចបានតាមរយៈសាលារៀន និងភាពវិជ្ជមាន នៃការគាំទ្រពីប្រព័ន្ធអប់រំទាំងមូល និងភាគីពាក់ព័ន្ធដទៃទៀត (UNICEF, 2012)។

បណ្តាប្រទេសភាគច្រើនលើសកលលោក គាំទ្រការអប់រំសម្រាប់ទាំងអស់គ្នា និងលុបបំបាត់ការរើសអើងរវាងក្មេងប្រុស និងក្មេងស្រី ការរើសអើងជាតិសាសន៍ ការគំរាមកំហែង និងអំពើហិង្សាដោយពាក្យសម្តី និងមិនមែនពាក្យសម្តី(UNICEF, 2018)។ ដើម្បីដោះស្រាយបញ្ហានេះ គំរូសកម្មភាពនៃកម្មវិធីសាលាកុមារមេត្រី (Child Friendly School) ដែលអង្គការយូនីសេហ្វ (UNICEF) បានតស៊ូមតិ និងលើកកម្ពស់ការអប់រំប្រកបដោយគុណភាពបានក្លាយជាឧបករណ៍សំខាន់ សម្រាប់សាលារៀនអនុវត្ត ជាពិសេសសម្រាប់កុមារបឋមសិក្សា។ សាលារៀនត្រូវបានទាមទារដើម្បីអនុវត្តបរិស្ថានសិក្សា ដែលបង្កភាពងាយស្រួលសម្រាប់កុមារ។ គោលបំណងសំខាន់នៃការអប់រំនៅបឋមសិក្សាតម្រូវឱ្យមិនត្រឹមតែដាក់កុមារទាំងអស់ចូលរៀនប៉ុណ្ណោះទេ ប៉ុន្តែត្រូវធានាថាសាលាទាំងអស់ធ្វើការដើម្បីផលប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារគ្រប់ៗរូប មានន័យថាការផ្តល់សាលារៀនដែលមានសុវត្ថិភាព និងការពារកុមារពីការកេងប្រវ័ញ្ចគ្រប់រូបភាព។ សាលាតម្រូវឱ្យមានបុគ្គលិកគ្រប់គ្រាន់ មានគ្រូដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ អគារសិក្សាមានបំពាក់ដោយធនធានគ្រប់គ្រាន់ និងត្រូវបានផ្តល់ឱ្យជាមួយនឹងលក្ខខណ្ឌសមរម្យសម្រាប់ការរៀនសូត្រគឺជាអាទិភាពកំពូល (UNICEF, 2018)។

តាមរបាយការណ៍របស់អង្គការយូនីសេហ្វ (UNICEF, 2021) បានបង្ហាញថា មានប្រទេសចំនួន ៥៦ ដែលបានយកកម្មវិធីសាលាកុមារមេត្រីទៅអនុវត្តសាកល្បងនៅក្នុងប្រព័ន្ធអប់រំរបស់គេ តាំងពីឆ្នាំ ២០០៧ មកម្លេះ ក៏ប៉ុន្តែការអនុវត្តបានលទ្ធផលកម្រិតណានោះ គឺអាស្រ័យទៅលើបរិបទនៃប្រទេសនីមួយៗ។ ភាពខុសគ្នាលើស្ថានភាពនៃការអនុវត្ត គឺបណ្តាលមកពីកត្តាប្រព័ន្ធអប់រំ វប្បធម៌ប្រពៃណីខុសគ្នា

កត្តាធនធានមនុស្សនៅក្នុងតំបន់ ចំណេះដឹង និងទស្សនៈយល់ឃើញរបស់ប្រជាជន និងកត្តាសំខាន់ៗផ្សេងទៀត។ លក្ខណៈនៃកម្មវិធីសាលាកុមារមេត្រី ផ្លាស់ប្តូរទៅតាមកម្រិតសេដ្ឋកិច្ចសង្គមរបស់សាលាសិស្ស ភេទ និងកម្រិតថ្នាក់ (Fitriani, 2021)។ ងាកមកប្រទេសឥណ្ឌូនេស៊ី បានចាប់ផ្តើមអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅឆ្នាំ ២០១៥ ដោយបានកំណត់យក គោលការណ៍របស់កម្មវិធីសាលាកុមារមេត្រី ដែលផ្តោតលើលក្ខណៈ និងជាតុផ្សំ សំខាន់ៗចំនួនប្រាំមួយ មានដូចជា៖ គរុកោសល្យនៃការបង្រៀន សុខភាពសិក្សា ការលើកកម្ពស់យេនឌ័រ ការចូលរួមសហគមន៍ ការអប់រំបរិយាប័ន្ន និងការការពារកុមារ (Fitriani, 2021)។

ស្របនឹងបរិបទសកល កម្ពុជាក៏មិនខុសពីប្រទេសដទៃទៀតដែរ នៅក្នុងឆ្នាំ២០០២ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយអង្គការយូនីសេហ្វ (UNICEF) អង្គការន័រវេស្ស៊ សង្គ្រោះកម្ពុជា (SCN) និងអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) បានពង្រីកកម្មវិធីសាលាកុមារមេត្រីទៅដល់សាលារៀនគោលដៅជាច្រើន នៅតាមបណ្តាខេត្តមួយចំនួន។ ហើយក្រោយមកនៅឆ្នាំ ២០០៥ ក្រសួងអប់រំ ក៏បានដាក់ចេញនូវក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីចំនួន ៦ចំណុច សម្រាប់ឱ្យសាលារៀនអនុវត្តសាកល្បង ក្នុងក្របខ័ណ្ឌទូទាំងប្រទេស (ក្រសួងអយក ២០០៨)។

ពីមួយឆ្នាំទៅមួយឆ្នាំ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីសាលាកុមារមេត្រី ក្នុងសាលាបឋមសិក្សារដ្ឋទាំងអស់ តាមរយៈការវាយតម្លៃកម្រិតនៃការអនុវត្ត មានកម្រិតមធ្យម និងកម្រិតអភិវឌ្ឍ។ ក្នុងចំណោចគ្រឹះស្ថានបឋមសិក្សាសាធារណៈប្រមាណជាង ៥ ពាន់សាលា បាននឹងកំពុងអនុវត្តកម្មវិធីនេះ និងមានសាលាប្រមាណជាង ម្ភៃភាគរយ (២០%) ប៉ុណ្ណោះដែលបានអនុវត្តកម្មវិធីសាលាកុមារមេត្រីបានកម្រិតល្អប្រសើរ ក្នុងកម្រិតកម្រិតអភិវឌ្ឍ (ក្រសួងអយក ២០២២)។ ក្នុងការអនុវត្តកម្មវិធីនេះ ក្រសួងអប់រំ សហការជាមួយអង្គការយូនីសេហ្វ បានខិតខំបំប៉នសមត្ថភាព ស្តីពីវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ការការពារកុមារ ការអប់រំបែបវិជ្ជមាន ដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ឱ្យយល់ដឹងពីខ្លឹមសារ ដើម្បីធានាបានការអនុវត្តប្រកបដោយគុណភាព។

សន្និបាតអប់រំឆ្នាំ ២០២១-២០២២ ដែលចេញផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា បានចង្អុលបង្ហាញថា កម្មវិធីសាលាកុមារមេត្រីបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិស្ថានសិក្សាស្អាត និងមានសុវត្ថិភាពស្របតាមស្តង់ដាសាលារៀនបឋមសិក្សា។ កម្មវិធីសាលាកុមារមេត្រីនេះ ក៏បានជួយកាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សា តាមរយៈការជួយជ្រោមជ្រែង និងផ្តល់នូវបរិស្ថានគាំទ្រដល់កាសិក្សារបស់កុមារ។ ផ្អែកលើលទ្ធផលដែលបានអនុវត្តនាពេលកន្លងមក ក្រសួងអាចវាយតម្លៃបានថា ការអនុវត្តកម្មវិធីសាលាកុមារមេត្រីផ្អែកលើសមាសភាគទាំង ៦ នេះ ទទួលបានលទ្ធផលក្នុងកម្រិតមធ្យម និងអភិវឌ្ឍន៍ (ក្រសួងអយក ២០២២)។

## ២.២.១ សមាសភាគទី១៖ ជានាកុមារទាំងអស់បានចូលរៀន

កុមារទាំងអស់បានចូលរៀន សំដៅដល់ការយកចិត្តទុកដាក់របស់អ្នកពាក់ព័ន្ធក្នុងការស្វែងរក និងជំរុញកុមារគ្រប់រូប ឱ្យទទួលបានការអប់រំប្រកបដោយសមធម៌ (ក្រសួងអយក ២០១៩)។ កុមារដល់វ័យ និងក្នុងវ័យសិក្សាទាំងអស់បានចូលរៀន និងទទួលបានការ អប់រំប្រកបដោយគុណភាពយ៉ាងហោចណាស់ត្រឹមកម្រិតមូលដ្ឋានដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិន សម្បទា និងចរិយាសម្បទា ប្រកបដោយការទទួលខុសត្រូវសំដៅរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ។ យោងតាមច្បាប់រដ្ឋធម្មនុញ្ញ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់ពីការយកចិត្តទុកដាក់លើការគាំពារ និងការអប់រំរបស់កុមារ។ នៅត្រង់មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា «រដ្ឋធានាថារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំ សិទ្ធិទទួលបានការគាំពារក្នុងស្ថានភាពមានវិបត្តិ ឬសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម ឬកាមគុណលើកុមារ(ក្រសួងអយក ២០១០)។ ក្នុងន័យនេះ រដ្ឋគាំពារ ប្រឆាំងនឹងសកម្មភាពទាំងឡាយណា ដែលរារាំងដល់ដំណើរការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខុមាលភាពរបស់កុមារ។

ដើម្បីឆ្លើយតបទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ជាពិសេសគោលនយោបាយអប់រំ និងសម្រេចបាននូវផែនការយុទ្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានបឋមសិក្សាត្រូវធានាដល់ការប្រមូលកុមារចូលរៀន

ប្រកបដោយសមធម៌ និងត្រូវរៀបចំ គ្រប់គ្រងទិន្នន័យព័ត៌មានសិស្ស ដែលមាននៅក្នុងសហគមន៍ជុំវិញសាលា ឱ្យបានយល់ច្បាស់ពីស្ថានភាពរបស់កុមារគ្រប់អាយុចូលរៀន ស្ថានភាពតំបន់ភូមិសាស្ត្រដែលកុមាររស់នៅ ជាពិសេសស្ថានភាពគ្រួសាររបស់កុមារផ្ទាល់ ដែលសិក្សាពីមុខរបរចិញ្ចឹមជីវិតរបស់មាតាបិតា អាណាព្យាបាល កម្រិតជីវភាពរបស់ពួកគាត់ ស្ថានភាពហិង្សា ការអប់រំនៅតាមផ្ទះជាដើម។ នៅមុនការចូលរៀនរៀងរាល់ឆ្នាំ សាលារៀន ត្រូវផ្សព្វផ្សាយពីការប្រមូលកុមារគ្រប់អាយុត្រូវចូលរៀនឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ជាពិសេសសំដៅដល់កុមាររស់នៅតំបន់ដាច់ស្រយាល ឬពិបាកក្នុងការទទួលបានព័ត៌មាន។ នាយកសាលាក៏អាចសហការជាមួយអាជ្ញាធរភូមិឃុំ ក្នុងការធ្វើផែនទីខ្នងផ្ទះ ដើម្បីប្រាដកថាមិនមានកុមារគ្រប់អាយុចូលរៀន ដែលស្ថិននៅក្រៅសាលា។ ការធ្វើបែបនេះអាចជួយឱ្យសាលារៀបចំសកម្មភាពជាច្រើនក្នុងគោលការណ៍ណែនាំទាំងនេះ ដើម្បីធានាថាពួកគេបានចុះឈ្មោះ និងបន្តរៀនយ៉ាងហោចណាស់ចប់ការអប់រំកម្រិតមូលដ្ឋាន (ក្រសួងអយក ២០០៩)។

ការចូលរៀនត្រូវបានចាត់ទុកជាសិទ្ធិកុមារជាសារវន្ត ហើយដើម្បីធ្វើយ៉ាងណាឱ្យសាលារៀនជួយដល់កម្ពុជាសម្រេចបាន គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងឆាកអន្តរជាតិ សាលារៀនគួរចូលរួមជាមួយសហគមន៍ ធានាឱ្យកុមារគ្រប់រូបបានចូលរៀន និងបញ្ចប់យ៉ាងហោចណាស់ការអប់រំមូលដ្ឋានដោយជោគជ័យ (រាជរដ្ឋាភិបាល ២០១៩)។ ដូច្នេះ សាលាត្រូវធ្វើការវិភាគលម្អិតដើម្បីធានាថា សកម្មភាពក្នុងផែនការប្រតិបត្តិ ប្រចាំឆ្នាំលើកឡើងពីឧបសគ្គរាំងមិនឱ្យកុមារចុះឈ្មោះចូលរៀន និងបន្តការសិក្សា ព្រោះការចុះឈ្មោះចូលរៀន និងការរក្សាឱ្យកុមារបន្តការសិក្សា ត្រូវបានចាត់ទុកជាអាទិភាពខ្ពស់បំផុត (ក្រសួងអយក ២០០៩)។

សាលារៀនទាំងអស់ ត្រូវធានាថាសិស្ស ដែលចុះឈ្មោះ ចូលរៀនរាល់ឆ្នាំបំពេញបាន ឬលើសពីចំណុចដៅកំណត់ទុក ក្នុងផែនការកម្រិតសាលារៀន ស្រុក និងខេត្ត។ មានសកម្មភាព សំខាន់ៗជាច្រើនដែលជួយឱ្យសិស្សទាំងអស់បាន ចុះឈ្មោះ ចូលរៀន ដូចជា យុទ្ធនាការប្រមូលកុមារចូលរៀន ការគូស ផែនទីខ្នងផ្ទះ និងប្រព័ន្ធរំឭកជាមុន ដើម្បីទប់ស្កាត់ការបោះបង់ ការសិក្សា។ គណៈគ្រប់គ្រងសាលារៀនអាចរៀបចំ

សកម្មភាព ដោយមានការចូលរួមពីកុមារ មាតាបិតា អាណាព្យាបាលសិស្ស ព្រះសង្ឃ និងអ្នកដឹកនាំសាសនា ក្នុងមូលដ្ឋានផ្សេងទៀត។ នៅតាមតំបន់ដែលមានគ្រួសារច្រើន (ភូមិធំ) មន្ត្រីអប់រំអាចធ្វើការសហការជាមួយ អាជ្ញាធរមូលដ្ឋាន គណៈកម្មការទ្រទ្រង់សាលារៀន ដើម្បីធ្វើយុទ្ធនាការដង្ហែជាក្បួន កាលបរិច្ឆេទចុះឈ្មោះ ចូលរៀន និងផ្សព្វផ្សាយពីសារប្រយោជន៍នៃការចូលរៀន និងការសិក្សារៀនសូត្ររបស់ពួកគេ។ ការទទួលសិស្សត្រូវរៀបចំទៅតាមថ្នាក់ កម្រិតអាយុ ហើយកុមារទាំងអស់រួមទាំងកុមារពិការ និងកុមារជនជាតិភាគតិច អាច ចុះឈ្មោះចូលរៀនដោយឥតគិតថ្លៃ ដើម្បីលើកទឹកចិត្តឱ្យមាតាបិតា នាំកូនមកចុះឈ្មោះចូលរៀន។ ក្នុងតំបន់ជនជាតិភាគតិច ត្រូវធ្វើការប្រកាសព័ត៌មានជាភាសារបស់ពួកគេ និងជាភាសាខ្មែរ(ក្រសួងអយក ២០០៨)។

ជារួមមកសាលារៀនទាំងអស់គួរមានទិន្នន័យត្រឹមត្រូវស្តីពីកុមារគ្រប់អាយុសិក្សា ក្នុងតំបន់ប្រមូលគោលដៅរបស់ខ្លួនក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ (ប្រព័ន្ធ EMIS)។ ទិន្នន័យប្រមូលបានគួររួមបញ្ចូលអត្រាចុះឈ្មោះចូលរៀនសរុប អត្រាត្រួតថ្នាក់ អត្រាបោះបង់ការសិក្សា និងចំនួនកុមារក្រៅសាលា ដូចជា កុមារពិការ និងកុមារជួបការលំបាកដែលអាចរារាំងពួកគេមិនឱ្យចូលរៀន ដើម្បីធានាថា កុមារគ្រប់រូបអាចចូលរៀនបាន។ ទិន្ន័យត្រូវបានប្រមូល ផ្ទៀងផ្ទាត់ វិភាគ និងសង្ខេបលើការប្រកាសព័ត៌មានរបស់សាលារៀន និងត្រូវបានផ្សព្វផ្សាយច្បាស់ដល់អ្នក ពាក់ព័ន្ធក្នុងមូលដ្ឋានទាំងអស់ និងប្រើប្រាស់ដោយនាយកសាលា និងអ្នកពាក់ព័ន្ធទាំងអស់ដើម្បីកំណត់អាទិភាពសម្រាប់ផែនការ អភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំ និងជួយឱ្យសាលាសម្រេចបានចំណុចដៅនៃការចុះឈ្មោះចូលរៀន។ ក្រៅពីនេះ សាលាគួរសហការជាមួយភូមិ និងឃុំដើម្បីធានាការប្រមូលទិន្នន័យស្តីពីកុមារដែលអាចនៅក្រៅសាលា។

### ២.២.២ សមាសភាគទី២៖ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន

ការសិក្សាប្រកបដោយប្រសិទ្ធភាពជាសកម្មភាពបង្រៀន និងរៀនដែលសិស្សចូលរួមយ៉ាងសកម្មការរៀនសូត្រតាមសកម្ម ភាពប្លែកៗ រួមទាំងក្នុងថ្នាក់រៀន ក្រៅថ្នាក់រៀន និងសហគមន៍ ឬក្នុងរូបភាពជាការងារគម្រោង។ លើសពីនេះទៅទៀត វាជាការរៀនសូត ដែលធ្វើឱ្យសិស្សអាចអភិវឌ្ឍបំណិនប្រាស្រ័យទាក់ទង ការ

គិតពិចារណា ការសម្រេចចិត្ត និងការដោះស្រាយបញ្ហាតាមរយៈការងារ ជាក្រុម (ក្រសួងអយក ២០១៩)។ គណៈគ្រប់គ្រងសាលារៀន អង្គការដៃគូទ្រទ្រង់របស់សាលារៀន ការធ្វើអធិការកិច្ចរបស់ថ្នាក់ក្រសួង មន្ទីរ ឬការិយាល័យស្រុកខណ្ឌ អាជ្ញាធរដែនដី ព្រមទាំងអ្នកពាក់ព័ន្ធជាច្រើនទៀតក្នុងការអនុវត្តសកម្មភាពស្វ័យវាយតម្លៃសាលារៀន ដើម្បីដឹងពីចំណុចខ្លាំង និងចំណុចដែលត្រូវកែលំអរ រួចធ្វើផែនការអភិវឌ្ឍសាលាទាំងអស់គ្នា ដើម្បីជាប្រយោជន៍ដល់លទ្ធផលសិក្សារបស់សិស្ស (ក្រសួងអយក ២០១៧)។

ដើម្បីធ្វើឱ្យការរៀនសូត្រគួរឱ្យចាប់អារម្មណ៍ និងមាន ប្រសិទ្ធភាពសម្រាប់សិស្ស គ្រូត្រូវមានធនធានគ្រប់គ្រាន់ សម្ភារផ្សេងៗ និងទីកន្លែងសម្រាប់ឱ្យសិស្សរៀនសូត្រ។ ចំណុចនេះ នឹងធ្វើឱ្យការរៀនសូត្រកាន់តែសប្បាយ និងធានាថា សិស្សមាន ឱកាសរៀនសូត្រដោយប្រើប្រាស់យុទ្ធវិធីចម្រុះ និងប្រើប្រាស់ ភាពច្នៃប្រឌិត និងបំណិនត្រិះរិះរបស់ខ្លួន ព្រមទាំងអភិវឌ្ឍបំណិន របស់ខ្លួនតាមរយៈទម្លាប់សិក្សាប្រចាំថ្ងៃ និងសកម្មភាពក្រុម។ ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ជារឿងចាំបាច់ដែលត្រូវតែពង្រឹង ដូចជាការធ្វើកិច្ចតែងការបង្រៀន ការគ្រប់គ្រងថ្នាក់រៀន ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់មន្ត្រីអប់រំ និងការស្វែងរកវិធីសាស្ត្របង្រៀនថ្មីៗ មកបង្រៀនសិស្ស (ក្រសួងអយក ២០១៩)។

លើសពីនេះ ដើម្បីធានាការអប់រំមានប្រសិទ្ធភាព ត្រូវគិតលើលទ្ធផលទុកជាមុន មានន័យថាគ្រូត្រូវតែមានកិច្ចតែងការបង្រៀនជាចាំបាច់។ ក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន គួរត្រូវបានយកមកអនុវត្តឱ្យបានជាប់លាប់ និងការទទួលខុសត្រូវខ្ពស់។ ក្រៅពីនេះ បរិស្ថានសិក្សាក្នុងថ្នាក់ គួរធានាថាមានគ្រឿងសង្ហារិម និងបរិក្ខារវិទ្យាសាស្ត្រសំខាន់ៗក្នុងថ្នាក់ ដែលសមស្របនឹងអាយុ និងកម្ពស់ របស់សិស្ស និងមិនបង្កមុខសញ្ញាគ្រោះថ្នាក់ដល់សិស្ស សម្រាប់អនុវត្ត និងធ្វើពិសោធន៍ជាដើម។ ជាងនេះទៅទៀត កម្មវិធីសិក្សាគួរមានបំណិនជីវិតសំខាន់ៗ ដែលជាបំណិនកុមារត្រូវការចាំបាច់ក្នុងជីវិតប្រចាំថ្ងៃ សម្រាប់ការរស់នៅទាំងប្រចាំថ្ងៃ និងទៅថ្ងៃខាងមុខ ដើម្បីចូលរួម ពេញលេញក្នុងសង្គម និងបំពេញតួនាទីជាច្រើនក្នុងកន្លែងការងារ ផ្ទះ និងសហគមន៍។

ដើម្បីធានាគុណភាពអប់រំអោយកាន់តែល្អប្រសើរឡើង ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់វិស័យអប់រំជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ និងជាពិសេសគឺការធ្វើវិមជ្ឈការលើគណនេយ្យភាពសាលារៀន (ក្រសួងអយក ២០១៨)។ ការពង្រឹងលើការងារគ្រប់គ្រងសាលារៀនប្រកបដោយគណនេយ្យភាព និងតម្លាភាព ពិតជាមានសារៈសំខាន់ដល់ការពង្រឹងគុណភាពផ្ទៃក្នុងរបស់អង្គភាពផ្ទាល់ ជាពិសេសវាជាចំណែកមួយយ៉ាងសំខាន់ និងចំបាច់ដល់ការពង្រឹងប្រព័ន្ធអប់រំនៅកម្ពុជាទាំងមូល (ណារ៉ុន ឆ្នាំ២០២១)។

ការអប់រំពិសេស ជាកម្មវិធីអប់រំដែលផ្តោតការយកចិត្តទុកដាក់ទៅលើ យន្តការត្រួតពិនិត្យសុខភាពសិស្ស (សិស្សត្រូវការ ជំនួយពិសេស) ការអនុវត្តកម្មវិធីអប់រំបរិយាបន្នដោយយកចិត្តទុកដាក់ លើកុមារពិការសកម្មភាពជួយសិស្សរៀនយឺត កម្មវិធី ពន្លឿនការសិក្សា។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តអនុសញ្ញាស្តីពិសិទ្ធិជនពិការ ដើម្បីធានាថាជនមានពិការភាពក៏ដូចជាមនុស្សជាតិទាំងអស់ត្រូវទទួលបានសិទ្ធិដូចគ្នា រួមមានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ និងសិទ្ធិវប្បធម៌ ដោយគ្មានការរើសអើង (ក្រសួងអយក ២០១៨)។

### ២.២.៣.សមាសភាគទី៣៖ សុខភាព សុវត្ថិភាព និងការការពារកុមារ

សុខភាព សុវត្ថិភាព និងការការពារកុមារ ជាការយកចិត្តទុកដាក់គាំទ្រការពារពីគ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យកុមារមានការអភិវឌ្ឍ កាយសម្បទា សតិ បញ្ញា ស្មារតី និងក្តីស្រឡាញ់ ប្រកបដោយជាសុខភាព។ សុខភាពរបស់អ្នកសិក្សា គឺជាកត្តាដ៏សំខាន់មួយដែលរួមចំណែកដល់ការធានាបាននូវការសិក្សាប្រកបដោយគុណភាព និងបង្កើនអត្រាបញ្ចប់ការសិក្សា។ ក្រឡេកមកមើលរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាវិញ ក៏បានយល់ច្បាស់អំពីសារៈសំខាន់ និងផលប៉ះពាល់នៃសុខភាពសិក្សាលើការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ច ហើយដើម្បីសម្រេចចក្ខុវិស័យនេះ ក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ កម្ពុជាត្រូវការចាំបាច់នូវធនធានដែលមានគុណភាព ផលិតភាពការងារខ្ពស់ ដែលសំដៅដល់មនុស្សដែលមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងសុខភាពរឹងមាំ (រាជរដ្ឋាភិបាល ២០១៩)។

ដើម្បីលើកកម្ពស់សុខភាពសិក្សា ត្រូវគិតលើបរិស្ថានរៀនស្អាតស្អាត និងមានអនាម័យទាំងខាងក្នុង និងខាងក្រៅថ្នាក់ជួយឱ្យសិស្សមានសុខភាពល្អ ដែលធ្វើឱ្យការ សិក្សាកាន់តែមានប្រសិទ្ធភាព និងកាត់បន្ថយអវត្តមានសិស្ស។ ថ្នាក់រៀនត្រូវមានពន្លឺ និងខ្យល់អាកាសគ្រប់គ្រាន់ដើម្បីសម្រួលដល់ការបង្រៀន និងរៀនរបស់គ្រូ និងសិស្ស ទ្វារ និងបង្អួចត្រូវបើកចំហរ ហើយក្នុងករណីដែល ថ្នាក់រៀនគ្មានពន្លឺ និងខ្យល់អាកាសគ្រប់គ្រាន់ ត្រូវកាប់មែកឈើគងលើដំបូងលអគារចេញ ឬដាក់អំពូល ឬកង្ហារទៅតាមការចាំបាច់។%សាលារៀនបឋមសិក្សា ដែលបានឆ្លើយតបលក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាត និងអនាម័យតាមសលារៀនមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសាលារៀនមួយចំនួនសម្រេចបាននៅកម្រិតក្បែស្តង់ដារនៃកម្មវិធី និងសាលារៀនភាគច្រើនក៏បានអនុវត្តស្របតាមស្តង់ដារនៃកម្មវិធីសាលាកុមារមេត្រី (ក្រសួងអយក ២០២២)។

នាយកសាលាត្រូវរៀបចំកិច្ចប្រជុំ និងមានការរៀបចំជាមួយអាជីវករស្តីពីប្រភេទចំណីអាហារ/ភេសជ្ជៈដែលត្រូវបានអនុញ្ញាត ឬមិនត្រូវបានអនុញ្ញាតឱ្យលក់ក្នុងបរិវេណសាលា។ ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងយ៉ាងតឹងរ៉ឹងដើម្បីធានាថា សិស្ស មានសុខភាពល្អ និងសុវត្ថិភាព។ ក្នុងករណីមានការងាករេពើកិច្ចព្រមព្រៀង/ការណែនាំ នាយកសាលាមានសិទ្ធិធ្វើការណែនាំ បន្ថែម ឬហាមឃាត់មិនឱ្យលក់តែម្តង។ ដូច្នេះ សាលាគួរបង្កើតគណៈកម្មការសុខភាពសិក្សាដែលរួមមានគ្រូទទួលបន្ទុក និង សមាជិកក្រុមប្រឹក្សាកុមារ និង រៀបចំកិច្ចប្រជុំដើម្បីណែនាំពីចំណីអាហារភេសជ្ជៈដែលប៉ះពាល់ដល់សុខភាព និងចំណាប់អារម្មណ៍ និងឥរិយាបថរបស់កុមារ និងរៀបចំផែនការផ្សព្វផ្សាយច្បាស់លាស់ដល់សិស្ស អាជីវករ និងគ្រូទាំងអស់ (ក្រសួងអយក ២០១៩)។

អំពើហិង្សាលើកុមារបង្កផលប៉ះពាល់ដល់ការអភិវឌ្ឍរបស់កុមារពេញមួយជីវិត ទាំងផ្លូវកាយ និងផ្លូវអារម្មណ៍។ ក្រៅពីផលប៉ះពាល់រយៈពេលវែង ក៏កុមារទទួលរងដូចជា របួសរាងកាយ និងការប៉ះទង្គិចផ្លូវចិត្ត ហើយការទទួលរងអំពើហិង្សានៅវ័យកុមារ គឺជាកត្តាដែលបង្កជាបញ្ហាអាកប្បកិរិយា និង ផ្លូវចិត្តនៅពេលពេញវ័យ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល បានប្តេជ្ញាចិត្តក្នុងការទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាលើកុមារ បានធ្វើឱ្យមានការរៀបចំផែនការជាតិស្តីពីការអភិវឌ្ឍកុមារ ២០១៦-២០១៨ ផែនការសកម្មភាពជាតិ ស្តីពីការលុប

បំបាត់អំពើហិង្សាលើកុមារនៅកម្ពុជា (រាជរដ្ឋាភិបាល ២០១៦)។ បន្ថែមជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ផងដែរដែលផ្តោតលើ សេវាគាំពារកុមារ ក្នុងប្រព័ន្ធអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល ប្រព័ន្ធសុខុមាលភាពកុមារ ប្រព័ន្ធសុខាភិបាល និងប្រព័ន្ធយុត្តិធម៌(រដ្ឋាភិបាល ២០២០)។ ក្រៅពីនេះ ក្រសួងអប់រំ បានប្តេជ្ញាដាក់បញ្ចូលការចិញ្ចឹមកូនបែបវិជ្ជមាន និងអនុវត្តច្បាប់ស្តីពីការអប់រំដើម្បីធានាថា មន្ត្រីអប់រំគ្រប់កម្រិត អនុលោមតាមក្រមប្រតិបត្តិគ្រូបង្រៀន ពង្រឹងការដាក់ទណ្ឌកម្មលើបទល្មើសព្រហ្មទណ្ឌ និងការបំពានលើក្រមប្រតិបត្តិគ្រូបង្រៀន ជាអំពើហិង្សាផ្លូវភេទ។ ក្រសួងអប់រំ បានលើកកម្ពស់យុទ្ធវិធីបង្រៀន និងរៀនអហិង្សា និងបានរៀបចំយន្តការកុមារមេត្រី ជាពិសេសសម្រាប់កុមារីសម្រាប់ការរាយការណ៍ និងបញ្ជូនបណ្តឹងពាក់ព័ន្ធការរំលោភបំពានកុមារក្នុងសាលារៀនទាំងអស់។ ប្រើត្បិតក្រសួងអប់រំ ក៏ដូចជារាជរដ្ឋាភិបាល បានយកចិត្តទុកដាក់លើបញ្ហាទាំងអស់នោះយ៉ាងណាក្តី ក៏ប៉ុន្តែសាលារៀនមួយចំនួនហាក់មិនបានអនុវត្តតាមខ្លឹមសារប្រតិបត្តិនោះឡើយ ជាពិសេសផ្នែកសុខភាពសិក្សា ដោយនៅតាមគ្រឹះស្ថានបឋមសិក្សានៅមានកន្លែងលក់ដូរចំណីអាហារដែលក្រសួងបានហាមឃាត់ ហើយអាណាព្យាបាលមួយចំនួនក៏ពុំទាន់បានយល់ដឹងពីសុវត្ថិភាពចំណអាហារនៅឡើយ។

#### ២.២.៤.សមាសភាគទី៤៖ ការឆ្លើយតបទៅនឹងយេនឌ័រ

ការឆ្លើយតបទៅនឹងយេនឌ័រ គឺជាការផ្តល់ការអប់រំប្រកបដោយសមភាព និងសមធម៌ រវាងក្មេងប្រុស និងក្មេងស្រី ។ យោងតាមច្បាប់កម្ពុជា កុមារគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ ប្រកដោយសមភាព សមធម៌ និងមានគុណភាព (ក្រសួងអយក ២០១៩)។ គណៈគ្រប់គ្រងសាលារៀនត្រូវធានាថា សាលាគោរពសិទ្ធិនេះសម្រាប់កុមារគ្រប់រូប ដោយមិនគិតថាមាន ក្រ ប្រុស ឬស្រីឡើយ។ មិនត្រូវផាត់ចេញកុមារណាម្នាក់ចេញពីមេរៀន ឬសកម្មភាពបន្ថែមក្នុងសាលាដោយសារតែស្ថានភាពសេដ្ឋកិច្ច ឬភេទរបស់ពួកគេឡើយ។

គ្រូគួរផ្តល់បរិយាកាសដែលពង្រឹងកិច្ចសហការ ការរៀនជាគូ និងជាក្រុម ដែលអាចឱ្យសិស្សស្រី និងសិស្សប្រុសធ្វើកិច្ចការជាមួយគ្នា។ ផ្តោតលើរបៀបដែលឱ្យសិស្សស្រី និងសិស្សប្រុសបំពេញកិច្ចការដោយផ្តោតការយកចិត្តទុកដាក់លើការដាក់ឱ្យ សិស្សស្រី និងសិស្សប្រុសអង្គុយចូលគ្នា។ ក្រៅពីនេះ គួរធានាថា

សកម្មភាពក្រៅថ្នាក់ទាំងអស់ពាក់ព័ន្ធទាំងក្រុមសិស្សស្រី និងសិស្សប្រុស។ ក្នុងពេលធ្វើបទបង្ហាញ ត្រូវជានាឱ្យសិស្សស្រី និងសិស្សប្រុសមានឱកាសស្មើគ្នាក្នុងការបង្ហាញគំនិតក្នុងថ្នាក់។ លើសពីនេះ នាយកសាលា និងគណៈកម្មការទ្រទ្រង់សាលារៀន និងគ្រូគួរធានាថា ពួកគេពិចារណាពីយេនឌ័រ និងបញ្ចៀស ផ្នត់គំនិតស្ដីពីតួនាទីខុសៗគ្នា ដោយធ្វើយ៉ាងណាឱ្យសិស្សស្រី និងសិស្សប្រុសត្រូវបានរួមបញ្ចូលក្នុងសកម្មភាពទាំងអស់។

សាលាគួរធានាថាមានទាំងស្ត្រី និងបុរសក្នុងក្រុមប្រឹក្សា និងគណៈកម្មការនានា ដូចជា គណៈកម្មការទ្រទ្រង់សាលារៀន។ យ៉ាងហោចណាស់គួរមានសមាសភាពស្ត្រីយ៉ាងតិច ៥០% ហើយនៅពេលមានតំណាងជាបុរស ឬតំណាងជាស្ត្រីកាន់តែច្រើន ត្រូវចាត់វិធានការធានារបាយយេនឌ័រស្មើគ្នា ដើម្បីបង្កើតជាគំរូតួនាទីវិជ្ជមានក្នុងតួនាទីដឹកនាំទាំងសម្រាប់កុមារី និងកុមារា។ ជាពិសេស សាលារៀនគួររៀបចំឱ្យមានតំណាងជាស្ត្រី និងបុរសក្នុងគណៈកម្មការ ឬក្រុមប្រឹក្សានានា។

### ២.២.៥.សមាសភាគទី៥៖ ការចូលរួមរបស់កុមារ មាតាបិតា និងសហគមន៍

ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍គឺជាការទំនាក់ទំនងសហការយ៉ាងសកម្មចុះសម្រុងគ្នាជាមួយសាលារៀន។ ជាផ្តល់ជម្រើស និងបង្ហាញពីសកម្មភាពដែលកុមារ គ្រួសារ និងសហគមន៍អាចចូលរួមដើម្បីលើកកម្ពស់ទំនាក់ទំនងរវាង សាលារៀន គ្រួសារ និងសហគមន៍ ដើម្បីធ្វើឱ្យសាលារៀនក្លាយជាមជ្ឈមណ្ឌលអភិវឌ្ឍមួយរបស់សហគមន៍។

**ការចូលរួមរបស់កុមារ**

ក្រុមប្រឹក្សាកុមារក្នុងសាលា និងបែងចែកជាក្រុមសម្រាប់ថ្នាក់នីមួយៗ សមាជិកក្រុមប្រឹក្សាកុមារគួរមកពីថ្នាក់ទី៤-៦ នៅកម្រិតបឋមសិក្សា។ គួរមានចំនួនកុមារី និងកុមារាស្មើគ្នាក្នុងក្រុមប្រឹក្សាកុមារ ដែលយ៉ាងហោចណាស់ត្រូវមានកុមារី៥០% និងមានទាំងសមាសភាពកុមារី និងកុមារាក្នុងអនុសាខានីមួយៗរបស់ក្រុមប្រឹក្សាកុមារ។ សិស្សគួរបោះឆ្នោតរើសតំណាងថ្នាក់ និងប្រធានក្រុមប្រឹក្សាកុមារនិងជ្រើសរើសអនុប្រធាន ២ នាក់ ពីក្នុងចំណោមសមាជិកក្រុម ប្រឹក្សាកុមារ។ ប្រសិនបើប្រធានគឺជាកុមារា យ៉ាងហោចណាស់ត្រូវមានអនុប្រធានម្នាក់ជាកុមារី។ ក្រុមប្រឹក្សាកុមារគួររៀនរៀបចំ និង គ្រោងកិច្ចប្រជុំដើម្បីពិភាក្សាពីសកម្មភាព និងប្រជុំ

រាល់ខែជាមួយនាយកសាលា (ក្រសួងអយក ២០០៧)។ កុមារអាចចូលរួមយ៉ាងសកម្មមិនមែនតែក្នុងសកម្មភាពរៀនប៉ុណ្ណោះទេ លើសពិនេះ កុមារអាចចូលរួមចំណែកក្នុងសកម្មភាពជួយអភិវឌ្ឍសាលារៀនបានយ៉ាងល្អទៀតផង។ សកម្មភាពដែលកុមារអាចជួយបាន ដូចជាការចូលរួមធ្វើផែនការអភិវឌ្ឍសាលារយៈពេល ៥ឆ្នាំ ការជួយផ្សព្វផ្សាយគៀងគរថវិកាអភិវឌ្ឍសាលារៀន ការបង្រៀនជាក្រុម (មិត្តជួយមិត្ត) និងសកម្មភាពផ្សេងៗជាច្រើនទៀត (KAPE, 2015)។

**ការចូលរួមរបស់មាតាបិតា**

មាតាបិតាមានតួនាទីសំខាន់បំផុតក្នុងការតាមដាន និងលើកទឹកចិត្តកូនឱ្យសិក្សា ដើម្បីឱ្យពួកគ ផ្តល់ពេលវេលាសមស្របឱ្យកូនសិក្សា និងដឹងពីពេលដែលកូនធ្វើបានល្អ និងពេលដែលកូនត្រូវការជំនួយបន្ថែម។ ការផ្តល់ព័ត៌មានបច្ចុប្បន្នភាពជាប្រចាំដល់មាតាបិតាជួយពួកគាត់ចាប់អារម្មណ៍លើការអប់រំរបស់កូន និងជានាថា ពួកគេដឹងថា តើកូនរបស់ខ្លួនចូលរៀនទៀងទាត់ ឬទេ តាមរយៈសៀវភៅតាមដានការសិក្សា ឬសៀវភៅទំនាក់ទំនងអាណាព្យាបាល។

មានតាបិតាមានតួនាទីសំខាន់ផងដែរ នៅក្នុងការជួយជ្រោមជ្រែងសាលារៀនឱ្យមានការរីកចម្រើនតាមរយៈការបង្កើតសមាគមមាតាបិតាអាណាព្យាបាលសិស្ស ក្នុងការស្វែករកប្រភពថវិកា និងផ្តល់មតិយោបល់កែលម្អសាលារៀនឱ្យកាន់តែប្រសើរឡើង។

**សហគមន៍**

ដើម្បីលើកកម្ពស់គុណភាពអប់រំសម្រាប់កុមារ អង្គការ UNICEF ក៏បានបង្កើតកម្មវិធីវិធីវិធីសិក្សាកុមាមេត្រី(CFS)នេះឡើង។ កម្មវិធីនេះអាចចាត់ទុកជាកញ្ចប់ដំណោះស្រាយ និងជាឧបករណ៍គ្រប់ជ្រុងជ្រោយមួយសម្រាប់ជាជំនួយដល់ការបង្រឹងគុណភាពអប់រំ។ ហេតុនេះ ការបង្កើតកម្មវិធីកុមារមេត្រីឡើង គឺក្នុងគោលបំណងជម្រុញសាលារៀន និងប្រព័ន្ធអប់រំអោយមានភាពរីកចម្រើន ឆ្ពោះទៅរកស្តង់ដារ គុណភាពបង្ហាញអំពីកត្តាទាំងឡាយដែលជះឥទ្ធិពលលើសុខមាលភាព និងសិទ្ធិកុមារដែលជាអ្នកសិក្សានិងជាអ្នកទទួលផលជាចម្បងពីការបង្រៀន។ ស្តង់ដារគុណភាព គឺត្រូវបង្ករលក្ខណៈដល់កុមារទាំងអស់អាចចូលរៀន

បន្តការសិក្សាពីកម្រិតថ្នាក់មួយទៅកម្រិតថ្នាក់មួយទៀត និងបញ្ចប់ភូមិសិក្សាតាមកាលកំណត់។ ទន្ទឹងនឹងនោះគឺ ផ្តល់បទពិសោធន៍អប់រំល្អៗដល់សិស្សានុសិស្ស ដែលអាចជំនះភាពលំបាក និងសម្រេចទៅតាមសក្តានុពលរបស់គេ។ ចំណងទំនាក់ទំនងរវាងសាលាកុមារមេត្រី និងសហគមន៍របស់ខ្លួនពិតជាមានសារៈសំខាន់ខ្លាំងណាស់។

ជាទូទៅសាលាកុមារមេត្រី និងបរិយាកាសសិក្សាត្រូវស្ថិតក្រោមការពិនិត្យតាមដាន និងវាយតម្លៃ ហើយលទ្ធផលដែលបានមក គឺលទ្ធផលចាំបាច់សម្រាប់ក្រសួងធ្វើការវាយតម្លៃប្រសិទ្ធភាព និងភាពស័ក្តសិទ្ធិ ដើម្បីជួយសម្រេចបានវត្ថុបំណង(គោលនយោបាយ សាលាកុមារមេត្រី)។ ដូច្នេះជោគជ័យរបស់សាលាកុមាមេត្រីអាចវាស់វែងបានតាមរយៈសមត្ថភាពក្នុងការជួយគាំទ្រដល់វត្ថុបំណង និងគោលដៅដែលបានកំណត់។ ចំណុចដៅជាក់លាក់និងសូចនាការសម្រាប់វាស់វែងប្រសិទ្ធភាព ភាពស័ក្តសិទ្ធិ និងសមធម៌របស់កម្មវិធីកុមារមេត្រី គឺជាការងារសំខាន់ក្នុងការវាយតម្លៃផលសម្រេចនៃកម្មវិធី និងអាចបង្ហាញថាកម្មវិធីកំពុងផ្តល់ការអប់រំប្រកបគុណភាពសម្រាប់កុមារទាំងអស់។

តាមរយៈការពិនិត្យតាមដាន និងវាយតម្លៃលើផែនការកែលម្អសាលារៀន និងកម្មវិធីសាលាកុមារមេត្រី គ្រូបង្រៀនម្នាក់ៗ សាលារៀន និងសហគមន៍ អាចកំណត់បានពីចំណុចខ្លាំង និងចំនុចខ្សោយ ព្រមទាំងចំណុចដែលត្រូវកែលម្អដែលកើតមានឡើងក្នុងមូលដ្ឋានរបស់ខ្លួន។

គ្រប់សាលាទាំងអស់គួរបង្កើតគណៈកម្មការទ្រទ្រង់សាលារៀន ដែលមានសមាជិកទាំងប្រុស និងស្រី តាមរយៈ ការបោះឆ្នោតជ្រើសរើសចេញពីសហគមន៍។ បច្ចុប្បន្នគណៈកម្មការនេះ បានប្រែក្លាយទៅជាគណៈកម្មការគ្រប់គ្រងសាលារៀន ដែលមានតួនាទីគ្រប់គ្រងកិច្ចប្រតិបត្តិការសាលារៀន និងជួយឱ្យសាលារៀនអនុវត្តប្រកបដោយគណនេយ្យភាព និងតម្លាភាព។ គណៈកម្មការនេះគួរជួយជំរុញឱ្យមាតាបិតា និងសហគមន៍ចូលរួមក្នុងសាលា ដូចជា ការផ្តល់ជំនួយហិរញ្ញវត្ថុ និងវត្ថុ ដើម្បីធ្វើយ៉ាងណាឱ្យសាលាអភិវឌ្ឍ និងផ្តល់ការអប់រំមានគុណភាពដល់កុមារគ្រប់រូបក្នុងតំបន់គ្របដណ្តប់របស់សាលា (ក្រសួងអយក ២០១៩)។

សាលាគួរបង្កើតឱកាសសម្រាប់មាតាបិតា និងសហគមន៍ដើម្បីមានទាក់ទងគ្រប់សកម្មភាពក្នុងសាលាដោយប្រមូលគំនិត របស់ពួកគាត់ដាក់បញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ និងប្រាកដថាពួកគាត់មានឱកាសគ្រប់គ្រាន់ក្នុងការពិនិត្យតាមដាន និង ជួយគាំពារដល់សកម្មភាពរបស់សាលាក្នុងឆ្នាំសិក្សា នីមួយៗ ដោយមានកម្មវិធីសម្រាប់ឱ្យមាតាបិតាចុះទៅសាលា និងចែករំលែកបទពិសោធន៍យ៉ាងតិចម្តងឆ្នាំ ដើម្បីពិភាក្សា និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការសិក្សារបស់សិស្ស។

នាយកសាលា គួររៀបចំប្រជុំរវាងមាតាបិតា/អាណាព្យាបាល និងសាលា ៣ដង ក្នុងមួយឆ្នាំ នៅដើមបវេសនកាល ឆមាសទី១ និងឆមាសទី២។ ការប្រជុំនេះគួររៀបចំឡើងដោយមានពិធីផ្តល់រង្វាន់ដល់សិស្សឆ្នើមប្រចាំឆមាស ដើម្បីឱ្យពួកគាត់បានដឹងពីកិច្ច ខិតខំប្រឹងប្រែងរបស់នាយកសាលា និងគ្រូ។ ទន្ទឹមនឹងនេះមាតាបិតាដែលមានកូនរៀនពូកែអាចចែករំលែកបទពិសោធន៍ស្តីពីការ អប់រំកូនរបស់ខ្លួន (ក្រសួងអយក ២០០៧)។

### ២.២.៦.សមាសភាគទី៦៖ ការគាំទ្រពីប្រព័ន្ធអប់រំ (ការដឹកនាំ និងគ្រប់គ្រង)

ការគាំទ្រពីប្រព័ន្ធអប់រំ ជាចំណុចសំខាន់ក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រីឱ្យកាន់តែមានប្រសិទ្ធភាព គុណភាព និងធានានិរន្តរភាពក្នុងការអនុវត្តប្រកបដោយទំនុកចិត្ត។

ការគ្រប់គ្រង និងដឹកនាំ ជាកត្តាគន្លឹះក្នុងការអនុវត្តសាលាកុមារមេត្រីទទួលបានជោគជ័យ។ នាយកសាលាដើរតួនាទីជាអ្នកគ្រប់គ្រងផង និងជាអ្នកដឹកនាំផង។ មានន័យថានាយកសាលាត្រូវស្គាល់ពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងច្បាស់លាស់ ក្នុងនាមជាអ្នកគ្រប់គ្រង និងស្គាល់ពីសុខទុក្ខ តម្រូវការ និងបំណងប្រាថ្នារបស់បុគ្គលិកច្បាស់លាស់ក្នុងនាមជាអ្នកដឹកនាំ (ក្រសួងអយក ២០១៩)។ នៅពេលដែលនាយកសាលាមានសមត្ថភាពបំណិន និងឥរិយាបថច្បាស់លាស់ក្នុងការគ្រប់គ្រង និងដឹកនាំ គាត់អាចដឹកនាំឱ្យមានវឌ្ឍនភាពក្នុងការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាព។

នាយកសាលា បានដើរតួរនាទីយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយអប់រំបន្តពីមន្ទីរ និងការិយាល័យអប់រំស្រុក (ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ២០១៩)។ សាលារៀនមានទំនួលខុសត្រូវខ្ពស់លើ

ការអនុវត្តបន្ត ដើម្បីឱ្យគោលនយោបាយរបស់ក្រសួងមានប្រសិទ្ធភាពដល់លទ្ធផលសិក្សាសិស្ស។ ដើម្បីធានាការបង្រៀនរបស់គ្រូមានប្រសិទ្ធភាព គណៈគ្រប់គ្រងរមែងត្រួតពិនិត្យលើវត្តមានក្នុងការបំពេញការងាររបស់គ្រូ(ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩)។ គណៈគ្រប់គ្រងត្រូវពិនិត្យមើលថាតើការបង្រៀនរបស់លោកគ្រូមានកិច្ចតែងការ ឬមិនមាន។ ការបង្រៀនដែលមានកិច្ចតែងការនាំអោយដំណើរការរៀន និងបង្រៀនមានភាពរលូន និងមានប្រសិទ្ធភាព ។ ក្រៅពីនេះ នាយកសាលាមានតួនាទីសំខាន់ក្នុងការតាមដានការសិក្សារបស់សិស្ស និងជម្រុញទឹកចិត្តសិស្សអោយខិតខំរៀនសូត្រ ។ ចំណែកការលើកទឹកចិត្តរបស់នាយកសាលាជះឥទ្ធិពលយ៉ាងខ្លាំងដល់ការរៀននិងបង្រៀនរបស់គ្រូនិងលទ្ធផលសិក្សារបស់សិស្សផងដែរ។

ការបង្កើតចក្ខុវិស័យសាលារៀន ត្រូវមានភាពច្បាស់លាស់ ហើយគួរបំបែកចក្ខុវិស័យជាគោលដៅដែលផ្តោតអាទិភាពលើសកម្មភាពក្នុងផែនការកែលម្អសាលាសម្រាប់ការអនុវត្ត ក្រោមសមាសភាគនីមួយៗ។ អាជ្ញាធរមូលដ្ឋាន រួមទាំងគ្រូ មាតាបិតា សហគមន៍ និងសិស្ស គួរចូលរួមយ៉ាងសកម្មក្នុងដំណាក់កាលអនុវត្តទាំងអស់។ ជំរុញលើកទឹកចិត្តអ្នកជុំវិញខ្លួន ដើម្បីជួយអនុវត្តសកម្មភាពដែលជួយសម្រេចចក្ខុវិស័យឱ្យអស់ពីសមត្ថភាព។ ទទួលស្គាល់ សមិទ្ធផលរបស់អ្នកពាក់ព័ន្ធទាំងអស់ដែលជួយសម្រេចចក្ខុវិស័យនោះ។

គណៈគ្រប់គ្រងសាលារៀនត្រូវរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ព្រោះផែនការប្រតិបត្តិនេះមានសារៈសំខាន់ដែលបានធ្វើស្វ័យវាយតម្លៃលើកដំបូង ដោយផ្អែកលើទិន្នន័យដែលប្រមូលបានពីអ្នកពាក់ព័ន្ធទាំងអស់ដាក់បញ្ចូលក្នុងផែនការ នឹងគួរធ្វើស្វ័យវាយតម្លៃផែនការប្រតិបត្តិមុនដំណើរការរបស់ខ្លួននៅចុងឆ្នាំសិក្សា។

នាយកសាលាគួរធ្វើការគ្រប់គ្រងជាប្រចាំលើការអនុវត្តការងាររបស់បុគ្គលិក។ ប្រសិនបើធ្វើបានល្អការគ្រប់គ្រងការអនុវត្ត ការងារនឹងជួយបង្កើតស្មារតីក្រុមរឹងមាំ កន្លែងការងាររីករាយ និងបង្ហាញថា នាយកសាលាមានការដឹកនាំល្អ។ នាយកសាលាត្រូវបែងចែកតួនាទី និងភារកិច្ចច្បាស់លាស់ សម្រាប់ការបំពេញការងារតាមឆ្នាំនីមួយៗ ហើយធ្វើការវាយតម្លៃបុគ្គលិកដោយផ្អែកលើគោលការណ៍ និងលទ្ធផលការងារ។ ក្រៅ

ពីការងារគ្រប់គ្រងលើការងាររដ្ឋបាល និងបច្ចេកទេស នាយកសាលាក៏ត្រូវមានការលើកទឹកចិត្តបុគ្គលិកក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីពង្រឹងគុណវុឌ្ឍិគ្រូកាន់តែមានសមត្ថភាពខ្ពស់ជាងមុន។

ក្រសួងអប់រំ យុវជន និងកីឡា ក៏បានជួយគាំទ្រដល់សាលារៀនទាំងអស់ដែលបានអនុវត្តកម្មវិធីសាលាកុមារមេត្រី ទាំងផ្នែកបច្ចេកទេស រដ្ឋបាល និងធនធានមនុស្សដើម្បីធានាការអនុវត្តមាននិរន្តរភាព។ ក្នុងនោះក្រសួងបានរៀបចំវគ្គសិក្ខាសាលាជាច្រើនលើក ស្តីពីការធ្វើផែនការយុទ្ធសាស្ត្រ ការរៀបចំផែនការថវិកាសាលារៀន ការធ្វើផែនការពាក់ព័ន្ធនានា ការធ្វើស្វ័យវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី ដល់គណៈគ្រប់គ្រងសាលារៀន ជាបន្តបន្ទាប់តាមផែនការកំណត់ (ក្រសួងអយក ២០១៩)។

ក្នុងរយៈពេលជាងដប់ឆ្នាំ នៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី ក្រសួងអប់រំក៏បានរកឃើញនូវបញ្ហាប្រឈមមួយចំនួនដែលសាលារៀនមិនអាចអនុវត្តបានស្របតាមស្តង់ដារកម្មវិធី ដែលបញ្ហាប្រឈមទាំងនោះរួមមានដូចជា៖

បញ្ហាកង្វះខាតគ្រូបង្រៀន ជាចំណុចគន្លឹះមួយសម្រាប់ការលើកកម្ពស់ការអនុវត្តកម្មវិធីសាលាកុមារត្រី នៅកម្រិតបឋមសិក្សា ដែលនាយកសាលាចាំបាច់ត្រូវតែប្រើគ្រូកិច្ចសន្យា ឬគ្រូសហគមន៍ ដើម្បីជំនួសថ្នាក់រៀនដែលមិនមានគ្រូ។ យើងដឹងហើយថា ស្តង់ដារគ្រូកុមារមេត្រី ត្រូវមានចំណេះដឹងវិជ្ជាជីវៈ រួមនឹងសីលធម៌វិជ្ជាជីវៈ ជាចាំបាច់ នេះមិនទាន់និយាយដល់ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំទៀតផង ដូច្នេះថាតើឱ្យសម្រេចបាននូវសមាសភាគទី២ ការធានាប្រសិទ្ធភាពនៃការសិក្សារៀនសូត្រ បានដោយរបៀបណា។

បញ្ហាកង្វះអគារសិក្សា បន្ទប់សម្រាប់រៀបចំបណ្ណាល័យ បន្ទប់ពិសោធន៍ ទីចាត់ការ និងបន្ទប់កុំព្យូទ័រជាដើម។ ដូចដែលយើងបានដឹងស្រាប់ហើយថា បញ្ហាទាំងនេះជាបញ្ហាធំដែលពិបាកក្នុងការដោះស្រាយដែលត្រូវការធនធានថវិកា ច្រើនសម្រាប់ដោះស្រាយ។ កង្វះអគារសិក្សាបានបង្ខំឱ្យថ្នាក់រៀននៅបឋមសិក្សាដាក់សិស្សលើសនិយាម (និយាមសិស្ស-ថ្នាក់) ដែលធ្វើឱ្យធ្លាក់ចុះនូវគុណភាពសិក្សារបស់សិស្ស និងប្រសិទ្ធភាពផ្ទៃក្នុងរបស់សាលារៀន។ បន្ទប់ពិសោធន៍ និងបណ្ណាល័យ ដែលសាលារៀននៅជនបទដាច់ស្រយាលភាគច្រើនស្ទើតែមិនមាន និងមិនអាចអនុវត្តនូវស្តង់ដារកម្មវិធីសិក្សាបានឡើយ (ក្រសួងអយក ២០២២)។

បញ្ហាផ្សេងៗមួយចំនួនទៀត ដែលក្រសួងបានរកឃើញក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រី ដែលសាលារៀនបានជួបប្រទះដូចជា ការមិនសូវយល់ដឹងពីខ្លឹមសារអនុវត្តកម្មវិធីរបស់គណៈគ្រប់គ្រង ការមិនចូលរួមពីសហគមន៍ក្នុងការជួយកសាងផែនការនានារបស់សាលារៀន និងការអនុវត្តសកម្មភាពការងារមិនសូវមានតម្លាភាព និងគណនេយ្យភាព (ក្រសួងអយក ២០២២)។

ផ្អែកតាមខ្លឹមសារលើកឡើងរបស់អង្គការយូនីសេហ្វ (Unicef, 2021) ការបង្កើតសាលាកុមារមេត្រីថ្នាក់រៀនកុមារមេត្រី មិនមែនជាការបង្កើតសាលារៀនថ្មីនោះទេ វាគ្រាន់តែជាការធ្វើឱ្យសាលារៀនមួយក្លាយជាកន្លែងដែលមានផាសុកភាពសម្រាប់សិស្ស តាមរយៈការពង្រឹងលើប្រព័ន្ធការពារកុមារ សិទ្ធិសេរីភាព ការចូលរួម និងផ្តល់នូវទម្រង់នៃការអប់រំមួយប្រកបដោយគុណភាពសម្រាប់សិស្ស និងធ្វើឱ្យពួកគេចាត់ទុកសាលារៀនជាផ្ទះទីពីររបស់ពួកគេ។ ផ្ទុយមកវិញការអនុវត្តនៅតាមសាលារៀន ហាក់នៅមានកម្រិត ដោយមើលលើសូចនាករមួយចំនួន សាលារៀននៅអនុវត្តបានតិចតួច និងមិនមាននិរន្តរភាពលើដំណើរការអនុវត្ត ដោយសារមូលហេតុផ្សេងៗ ជាពិសេសពាក់ព័ន្ធនឹងកញ្ចប់ថវិកាជាដើម។

## ២.៣ សារៈប្រយោជន៍នៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី

ការអប់រំបានដើរតួនាទីយ៉ាងសំខាន់សម្រាប់កសាងធនធានមនុស្ស ពីអនក្ខរជន ប្រែក្លាយទៅជាអក្ខរជនប្រកបដោយការយល់ដឹង ចេះត្រិះរិះពិចារណា និងជាប្រយោជន៏ដល់ការអភិវឌ្ឍប្រទេសជាតិ។ ស្របពេលដែលរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់លើវិស័យអប់រំជាវិស័យអាទិភាព នៅក្នុងយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ ដែលផ្តោតលើការអភិវឌ្ឍន៍មូលធនមនុស្ស ជាអាទិភាពចម្បង ការសិក្សារៀនសូត្របានដើរតួនាទីយ៉ាងសំខាន់ក្នុងការកែប្រែអនាគតរបស់មនុស្ស សង្គម និងប្រទេសជាតិទាំងមូល។ ជាក់ស្តែងក្រសួងអប់រំ បាននឹងកំពុងខិតខំយ៉ាងខ្លាំងក្នុងកំណែទម្រង់វិស័យអប់រំ ក្នុងនោះក្រសួងអប់រំបាននឹងកំពុងបន្តអនុវត្តកម្មវិធីសាលាកុមារមេត្រី (CFS) តាំងពីឆ្នាំ ២០០៧ មកម្លេះ។ ការអនុវត្តកម្មវិធីសាលាកុមារមេត្រីនេះ បានផ្តល់នូវសារៈប្រយោជន៍ជាច្រើនសម្រាប់អ្នកពាក់ព័ន្ធដូចតទៅៈ

| | |
|---|---|
| ចំពោះសិស្ស | - ទទួលបានសាលារៀនមួយដែលជាទីស្រឡាញ់ ផ្តល់ភាពកក់ក្តៅ និងមានផាសុកភាព<br>- ទទួលបានការការពារសិទ្ធិ និងសុខសុវត្ថិភាព ទាំងនៅក្នុងថ្នាក់រៀន និងនៅក្នុងសាលារៀន<br>- មានសមត្ថភាពពេញលេញ តាមរយៈការសិក្សារៀនសូត្រប្រកបដោយគុណភាព<br>- មានសុជីវធម៌ សីលធម៌ល្អទាំងនៅក្នុងសាលា និងក្រៅសាលារៀន<br>- មានវិន័យសណ្តាប់ធ្នាប់ មិនបង្ករទំនាស់ ឬជំលោះ<br>- ចេះធ្វើការជាក្រុម ចេះសាមគ្គី និងមានភាពក្លាហានក្នុងការនិយាយជាសាធារណៈ<br>- ចេះដឹកនាំ និងចាត់ចែងកិច្ចការផ្សេងៗ តាមរយៈការធ្វើការជាក្រុម ការងារក្រុមប្រឹក្សាកុមារ<br>- ទទួលបានលទ្ធផលនៃការសិក្សារៀនសូត្រប្រកបដោយគុណភាព និងប្រសិទ្ធភាព។ |
| ចំពោះគ្រូបង្រៀន | - មានបំណិនក្នុងការបង្រៀនប្រកបដោយស្មារតីវិជ្ជាជីវៈ<br>- ពង្រឹងសមត្ថភាពគរុកោសល្យ និងបំណិនក្នុងការស្រាវជ្រាវ<br>- វាយតម្លៃសមត្ថភាពសិស្សស្របតាមស្តង់ដាកម្មវិធីសិក្សា<br>- មានទំនាក់ទំនងល្អជាមួយសហគមន៍ មាតាបិតា អាណាព្យាបាលសិស្ស<br>- យល់ដឹងពីដំណើរការកម្មវិធី និងយល់ដឹងពីការធ្វើផែនការនានារបស់សាលារៀន។ |
| ចំពោះសាលារៀន | - មានបរិស្ថានល្អ មានសោភ័ណភាពជាទីស្រឡាញ់ចូលចិត្តរបស់កុមារ |

| | |
|---|---|
| | - ធានាបាននូវប្រសិទ្ធភាពផ្ទៃក្នុងនៃការសិក្សារបស់សិស្ស (អត្រាដាប់ ធ្លាក់ បោះបង់)<br>- ពង្រឹងបាននូវការអនុវត្តវិន័យសាលារៀន និងការគោរពសិទ្ធកុមារជាមូលដ្ឋាន<br>- ធានាបាននូវការផ្តល់សេវាអប់រំនៅមូលដ្ឋានប្រកបដោយសមធម៌ និងបរិយាបន្ន<br>- កសាងទំនុងចិត្តសម្រាប់សហគមន៍នៅជុំវិញសាលារៀន។ |

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

ជំពូកនេះមានគោលបំណងធ្វើការបកស្រាយពន្យល់ អំពីការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ វិធីសាស្ត្រជ្រើសរើសសំណាក ប្រភពទិន្នន័យ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីសាស្ត្រវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣.១ ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងធ្វើការពន្យល់ទៅលើស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា តាមសមាសភាគនីមួយៗដែលបានកំណត់ តាមរយៈការប្រើវិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ (Mixed methods) បែបបរិមាណវិស័យ និងគុណវិស័យ ដើម្បីធ្វើការប្រមូលទិន្នន័យ។ វិធីសាស្ត្រនេះគឺជាលំនាំនៃការពិចារណាឱ្យបានស៊ីជម្រៅនៅក្នុងការស្រាវជ្រាវ ដើម្បីឱ្យមានភ័ស្តុតាងផ្សេងគ្នាមកបញ្ជាក់ និងបង្កើនចំណេះដឹងសំខាន់ៗ ជាងវិធីស្រាវជ្រាវតែមួយប្រភេទ (Creswell & Plano Clark, 2013)។ ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់នូវប្រភេទទិន្នន័យប្រមូលថ្មី(Primary Data) សម្រាប់ការបកស្រាយលទ្ធផលនៃការស្រាវជ្រាវ។ ការសិក្សានេះបានប្រើប្រាស់នូវ ឧបករណ៍ប្រមូលទិន្នន័យបែបបរិមាណវិស័យ តាមរយៈការប្រើប្រាស់កម្រងសំណួរស្ទង់មតិ ពីលោកគ្រូ អ្នកគ្រូ នៅតាមគ្រឹះស្ថានបឋមសិក្សាចំនួន ១៥ កន្លែង នៅក្នុងខេត្តត្បូងឃ្មុំ ដែលផ្តោតលើស្ថានភាពនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រីទាំង ៦ ចំណុច ដោយយកលំនាំតាមក្រសួងអប់រំ យុវជន និងកីឡា។ ចំពោះគណៈគ្រប់គ្រងសាលា មន្ត្រីជំនាញនៅការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត អ្នកស្រាវជ្រាវនឹងធ្វើការសម្ភាសដោយផ្ទាល់ មិនប្រើប្រាស់កម្រងសំណួរទម្រង់បិទបែបបរិមាណវិស័យឡើយ ដោយហេតុថា អ្នកស្រាវជ្រាវចង់បានការបកស្រាយលម្អិត និងពន្យល់ពីស្ថានភាពនៃការអនុវត្តកម្មវិធីកន្លងមក និងកំណត់ពីបញ្ហាប្រឈម ក៏ដូចជាដំណោះស្រាយក្នុងការបទពិសោធន៍នៃការដឹកនាំ និងគ្រប់គ្រងរបស់គាត់កន្លងមក និងសម្រាប់ទៅអនាគត។

**តារាងវិធីសាស្ត្រស្រាវជ្រាវតាមបរិមាណវិស័យ និងគុណវិស័យ៖**

| គោលបំណង | ឧបករណ៍ស្រាវជ្រាវ | សំណាក ស្រាវជ្រាវ | ការវិភាគទិន្នន័យ |
|---|---|---|---|
| ១. សិក្សាពីស្ថានភាពអនុវត្តកម្មវិធីសាលាកុមារមេត្រី២. បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធី | បរិមាណវិស័យៈប្រើប្រាស់កម្រងសំណួរ (Questionnaire) | -គ្រូបង្រៀនបឋមសិក្សា | -កម្រិតចង្អុលបង្ហាញពី មិនបានអនុវត្ត ទៅ អនុវត្តទៀងទាត់ (១ ដល់ ៥)<br>-ចំនួន (Frequency)<br>-ភាគរយ (%)<br>-គម្លាតមធ្យម (Mean)<br>-គម្លាតស្តង់ដា(Standard Deviation) |
| | គុណវិស័យៈប្រើប្រាស់សំណួរក្នុងការសម្ភាស(Interview protocol) | -មន្ត្រីជំនាញ<br>-នាយក/នាយិកា | -ការបកស្រាយខ្លឹមសារ(Transcript)<br>-ការទាញយកពាក្យគន្លឹះ(Coding)<br>-បកស្រាយអត្ថន័យរួម(Themes) |

## ៣.២ វិធីសាស្ត្រជ្រើសរើសសំណាក

ទិន្នន័យបរិមាណវិស័យ និងគុណវិស័យនៃការស្រាវជ្រាវត្រូវបានប្រមូលពីគ្រឹះស្ថានបឋមសិក្សាសាធារណៈចំនួន ១៥ សាលា ស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ។ សាលាទាំងនោះសុទ្ធសឹងជាសាលាដែលបានអនុវត្តកម្មវិធីសាលាកុមារមេត្រី តាំងពីឆ្នាំ២០០៧ ហើយលក្ខខណ្ឌនៃការកំណត់យកសាលារៀនដើម្បីប្រមូលទិន្នន័យគឺឈរលើចំណុច ៣ មានៈ ទី១ ជាសាលាដែលមានចំនួនសិស្សច្រើន (សាលាធំ) ទី២ ជាសាលាដែលមានសិស្សតិច (សាលាតូច) និងទី៣ ជាសាលាកម្រង។ ហេតុផលដែលយើងជ្រើសរើសយកលក្ខខណ្ឌទាំងបីនេះ ដោយសារតែសាលាធំ សាលាមានសិស្សច្រើន មានបុគ្គលិកច្រើន មានសហគមន៍ជុំវិញសាលារៀនច្រើន ទទួលបានថវិកាសម្រាប់ដំណើរការសាលារៀនច្រើន តម្រូវការខ្ពស់ និងការគ្រប់គ្រងដឹកនាំរបស់នាយកមានភាពលំបាក ស្មុគស្មាញ។ ចំពោះសាលាតូច មានសិស្សតិច មានគ្រូតិច សហគមន៍ជុំវិញសាលារៀនតិច និងប្រភពធនធានថវិកាក៏តិច តម្រូវការក៏តិច ហើយការដឹកនាំរបស់នាយក/នាយិកា មានភាពងាយស្រួលចាត់ចែងជាងសាលាធំ។ រីឯសាលាកម្រង ជាសាលារៀនដែលអ្នកសិក្សាស្រាវជ្រាវមើលឃើញថា មានការ

គ្រប់គ្រងដឹកនាំល្អ មានវិន័យសណ្តាប់ធ្នាប់ បរិស្ថានសិក្សាល្អ និងការសិក្សារបស់សិស្សមានគុណភាពល្អជាងសាលាសម្ព័ន្ធ។ ហេតុផលទាំងខាងលើនេះ ក្នុងនាមអ្នកស្រាវជ្រាវពិតជាចង់រកឱ្យឃើញពីស្ថានភាពអនុវត្តកម្មវិធីរបស់ក្រសួងអប់រំដូចគ្នា ថាតើមានភាពលម្អៀងគ្នាកម្រិតណា និងចង់បានលទ្ធផលមួយដែលអាចទទួលយកបានទាំងអស់គ្នា សម្រាប់ការវាយតម្លៃជារួម។ ភាពលម្អៀងដែលអាចមានភាពខុសប្លែកគ្នាខ្លះ ដោយសារកត្តាមួយចំនួន ដូចជាទីតាំងភូមិសាស្ត្ររបស់សាលារៀនស្ថិតនៅតំបន់ប្រជុំជន ឬទីជនបទដាច់ស្រយាល និងការយល់ដឹងរបស់សហគមន៍សាលារៀនទាំងមូល។

### ៣.២.១ ការជ្រើសរើសសំណាកបរិមាណវិស័យ

តារាងភាគសំណាកបរិមាណវិស័យ

| ក្រុង/ស្រុក | ចំនួនគ្រូបង្រៀនសរុប (នាក់) | ចំនួនសាលាបឋម បានជ្រើសរើស | ចំនួនគ្រូបង្រៀន (នាក់) |
|---|---|---|---|
| តំបែរ | ១៣១ | ៥ | ៥០ |
| ត្បូងឃ្មុំ | ១៦១ | ៥ | ៥១ |
| អូរាំងឪ | ៤៦១ | ៥ | ៥០ |
| សរុប | ៧៥៣ | ១៥ | ១៥១ |

នៅក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យក ១៥ សាលា ដោយរើសចេញពីស្រុកចំនួន ៣ មាន ស្រុកតំបែរ ស្រុកត្បូងឃ្មុំ និងស្រុកអូរាំងឪ ស្មើនឹងចំនួន ១៥១ ភាគសំណាក។ ដោយសារកត្តាលទ្ធភាពនៃការស្រាវជ្រាវនៅមានកម្រិត អ្នកស្រាវជ្រាវមិនអាចកំណត់យកសាលាគ្រប់ក្រុង ស្រុកនីមួយៗបានទាំងអស់នោះទេ។ ស្រុកតំបែរជាស្រុកមួយដែលស្ថិតនៅភាគខាងជើងនៃខេត្ត និងជាភូមិសាស្ត្រដាច់ស្រយាលមួយដែលសំបូរដោយសាលរៀនជនបទ មិនសូវមានប្រជុំជន ដូចស្រុកផ្សេងទៀយ។ ស្រុកអូរាំងឪជាស្រុកមួយស្ថិតនៅខាងលិចធៀងខាងត្បូង ហើយអ្នកស្រាវជ្រាវបានជ្រើសយកសាលាដែលស្ថិតនៅប្រជុំជនផង និងជនបទផង។ ចំណែកស្រុកត្បូងឃ្មុំ ជាស្រុកមួយដែលមានសក្តានុពល ផ្នែកសេដ្ឋកិច្ច ផ្នែកអប់រំ ដែលមានលក្ខណៈចម្រុះ មានសាលារៀននៅទីប្រជុំជន សាលារៀននៅទីជនបទដាច់ស្រយាល និងសាលាដែលមាន

ការគ្រប់គ្រងដឹកនាំបានល្អ។

រូបមន្តគណនាភាគសំណាក៖

តាមរូបមន្ត Taro Yamane, 1967 Yamane′s Formula : $n = \frac{N}{1+N(e)^2}$

ដោយកំណត់យកភាពជឿជាក់ 93% ដោយគ្រូបង្រៀនបឋមសិក្សា ទាំង បី ស្រុក មានចំនួន 753នាក់

តាមរូបមន្តយើងបាន $n = \frac{753}{1+753(0.07)^2} = 160$នាក់ តែដោយសារការប្រមូលកម្រងសំណួរ មានសំណាកខូច (មិនមានទិន្នន័យ) និងមិនច្បាស់លាស់ (គូសសញ្ញាជ្រើសរើសច្រើនក្នុងប្រភេទសំណួរតែមួយដែលមិនអាចកំណត់បាន) ចំនួន 9 ទើបកាត់ចេញនៅសល់សំណាកបានការ ស្មើ 151 ភាគសំណាក។

### ៣.២.២ ការជ្រើសរើសសំណាកគុណវិស័យ

ការជ្រើសរើសសំណាកក្នុងគុណវិស័យ ត្រូវបានជ្រើសចេញពីអង្គភាពផ្សេងៗគ្នា ដូចតទៅ៖

| ល.រ | អង្គភាព | តួនាទី | ចំនួន |
|---|---|---|---|
| ១ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | មន្ត្រីជំនាញ | ២នាក់ |
| ២ | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | មន្ត្រីជំនាញ | ៣នាក់ |
| ៣ | គ្រឹះស្ថានបឋមសិក្សាសាធារណៈ | គណៈគ្រប់គ្រង | ៧នាក់ |
| **សរុប** | | | ១២នាក់ |

ការសម្ភាសកំណត់យកអ្នកចូលរួមចំនួន ១២នាក់ មកពីអង្គភាពផ្សេងគ្នា ដែលសុទ្ធតែជាអ្នកមានបទពិសោធន៍ជំនាញលើការងារអប់រំ អ្នកដែលទទួលសេវាអប់រំដោយផ្ទាល់ និងអ្នកភាគីពាក់ព័ន្ធ។ សំណាកទាំងនោះរួមមាន មន្ត្រីជំនាញនៅការិយាល័យបឋមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចំនួន ១រូប មន្ត្រីជំនាញនៅការិយាល័យអធិការកិច្ច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចំនួន ១រូប មន្ត្រីជំនាញនៅការិយាអប់រំស្រុក ចំនួន ៣រូប នាយក/នាយិកាសាលាបឋមសិក្សា ចំនួន ៧រូប ដើម្បីចូលរួមក្នុងការឆ្លើយលើសំណួរសម្ភាសដែលបានរៀបចំ។

## ៣.៣ ប្រភពទិន្នន័យ

ការសិក្សាស្រាវនេះ បានប្រើប្រាស់កម្រងសំណួរ (Survey) យោងតាមសៀវភៅណែនាំប្រតិបត្តិកម្មវិធីសាលាកុមារមេត្រី របស់ក្រសួងអប់រំ យុវជន និងកីឡា និងសម្ភាសផ្ទាល់ (Interview) ក្នុងការប្រមូលទិន្នន័យ ដើម្បីសិក្សាពីការអនុវត្តកម្មវិធីសាលាកុមារមេត្រី។ ទិន្នន័យនៃសម្ភាសន៍ផ្ទាល់ត្រូវបានប្រមូល និងវិភាគ ដើម្បីសិក្សាពីស្ថានភាពនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី និងស្វែងយល់ពីបាតុភាពនានាដែលជួបប្រទះកំឡុងពេលអនុវត្តកម្មវិធីសាលាកុមារមេត្រីឱ្យបានច្បាស់លាស់ តាមរយៈការបង្កើតកម្រងសំណួរស្រាវជ្រាវ និងវិភាគលើលទ្ធផលដែលទទួលបានពីការស្រាវជ្រាវ ទៅបំពេញបន្ថែមលើកង្វះខាតក្នុងការអនុវត្តនាពេលកន្លងមក។ ម្យ៉ាងវិញទៀត អ្នកស្រាវជ្រាវក៏បានប្រើប្រាស់ស្នាដៃស្រាវជ្រាវមុនៗ (Previous Study) និងសៀវភៅ ឯកសារនានាដែលពាក់ព័ន្ធ ដើម្បីសិក្សាបន្ថែម។ ដូច្នេះការស្រាវជ្រាវនេះ ខ្ញុំសង្ឃឹមថាលទ្ធផលដែលបានពីការស្រាវជ្រាវនេះ នឹងបង្ហាញនូវកម្រិតនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រីមួយជាក់លាក់ នឹងជួយបំពេញបន្ថែម នូវរាល់កង្វះខាតលើការងារគ្រប់គ្រងចំពោះកម្មវិធីនេះ ជូនដល់លោកនាយក/នាយិកាសាលាកុមារមេត្រីទាំងអស់ឱ្យបន្តអនុវត្តមានភាពពេញលេញ និងស្របតាមស្តង់ដាររបស់កម្មវិធី។ ទិន្នន័យនៃកម្រងសំណួរត្រូវបានប្រមូល និងវិភាគដើម្បីសិក្សាពីភាគរយចំពោះស្ថានភាពនៃការអនុវត្ត និងចំណុចវិជ្ជមាន និងអវិជ្ជមាននៃការអនុវត្តកម្មវិធីនេះ។

## ៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ

### ៣.៤.១ វិធីសាស្ត្របម្រូលទិន្នន័យតាមរយៈកម្រងសំណួរ

ការប្រមូលទិន្នន័យនេះត្រូវបានប្រមូលចេញពីសំណាកចំនួន ១៥១នាក់ និងធ្វើឡើងក្នុងរយៈពេល ២ ខែ (រាប់បញ្ចូលទាំងការគិតត្រៀមទុកនូវអ្នកដែលអាចទាក់ទងផងមកសម្ភាស ការងារសង្កេតសាលារៀន រៀបចំកសារកម្រងសំណួរ សំនួរសម្ភាសន៍ និងលិខិតរដ្ឋបាលផ្សេងៗទៀតផង) ដែលអ្នកស្រាវជ្រាវបានទៅទស្សនាសាលាចំនួនបីទៅបួនដងក្នុងមួយសប្តាហ៍ និងចំណាយពេលប្រហែល ១ ទៅ ២ ម៉ោងក្នុងមួយលើក (មានការអង្កេតសាលារៀន ថ្នាក់រៀន បរិស្ថានសាលារៀន សួនបំណិនជីវិត កន្លែងលក់ចំណីអាហារ ការ

ទំនាក់ទំនងជាមួយលោកគ្រូ អ្នកគ្រូ ដើម្បីណែនាំពីការបំពេញកម្រងសំណួរ និងបញ្ហាផ្សេងៗ)។ មុនដំណើរការនៃការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានធ្វើបទបង្ហាញអំពីគោលបំណង និងខ្លឹមសារនៃការស្រាវជ្រាវទៅអ្នកចូលរួម។ បន្ទាប់ពីការធ្វើបទបង្ហាញ កម្រងសំណួរត្រូវបានចែកជូនអ្នកចូលរួម ដើម្បីឆ្លើយសំណួរនៃកម្រងសំណួរ។

កម្រងសំណួរដែលបានផ្តល់ជូនអ្នកចូលរួម ត្រូវបានរៀបចំឡើងដោយ ផ្អែកលើចរិកលក្ខណៈនៃកម្មវិធីសាលាកុមារមេត្រី មានសមាសភាគទាំង ៦ ដូចជា ១) កុមារទាំងអស់បានចូលរៀន មានចំនួន ១៥ សំណួរ, ២) ការសិក្សាប្រកបដោយប្រសិទ្ធភាព មានចំនួន ៣៤ សំណួរ ៣) សុខភាព សុវត្ថិភាព និងការការពារកុមារ ៣១ សំណួរ, ៤) ការឆ្លើយតបទៅនឹងយេនឌ័រ មានចំនួន ៩ សំណួរ, ៥) ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ មានសំណួរចំនួន ១៣, និង ៦) ការគ្រប់គ្រង និងដឹកនាំរបស់សាលារៀន មាន ១៤ សំណួរ សរុបសំណួរទាំងអស់មាន ១១៦សំណួរ។ នៅក្នុងសមាសភាគនីមួយៗ មានបង្កប់នូវសូវនាករគោល និងសូចនាកររង ជាច្រើនពាក់ព័ន្ធនឹងស្ថានភាពអនុវត្ត និងដំណើរការកម្មវិធីសាលាកុមារមេត្រី។ ចម្លើយនៃការឆ្លើយកម្រងសំណួរត្រូវបានប្រមូល និងរក្សាទុក ដើម្បីធ្វើការ វិភាគលើស្ថិតិទិន្នន័យដែលទទួលបាន។

### ៣.៤.២ វិធីសាស្ត្រប្រមូលទិន្នន័យតាមរយៈការសម្ភាសន៍ផ្ទាល់

បន្ទាប់ពីការប្រមូលទិន្នន័យដោយកម្រងសំណួរមួយសប្តាហ៍រួចមក សម្ភាសន៏ផ្ទាល់ត្រូវបានអនុវត្តដោយមានអ្នកចូលរួមចំនួន ១២នាក់ ដែលត្រូវបានស្នើសុំតាមរយៈទូរសព្ទ និងតាមការទំនាក់ទំនងផ្ទាល់ដើម្បីធ្វើសម្ភាស។ ការសម្ភាសន៍ផ្តោតលើការសួរបែបស៊ីជម្រៅនៃសំណួរបើកចំហ និងការវិភាគឯកសារ។ ការសម្ភាសនេះ បានកំណត់យកសំណួរពីរផ្នែកសំខាន់ៗ ដើម្បីសិក្សាស្វែងយល់ពី(១) ស្ថានភាពនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី ដែលមានសមាសភាគទាំង ៦ ជាគោល និង(២) បញ្ហាប្រឈមដែលសាលារៀនបាននឹងកំពុងជួបប្រទះ និងមិនអាចអនុវត្តបាននៅតាមសាលលារៀនក្នុងខេត្តត្បូងឃ្មុំ។

នៅមុនពេលសម្ភាសន៍ អ្នកសម្ភាសបានអាននូវគោលបំណងនៃការសម្ភាស និងអានកម្រងសំណួរសម្ភាសមួយៗដោយសង្ខេបដល់អ្នកចូលរួមសម្ភាសន៍ ដើម្បីឱ្យអ្នកចូលរួមបានយល់ពីគោលបំណង និងមាន

បម្រុងប្រយ័ត្នយកចិត្តទុកដាក់ក្នុងការផ្តល់ចម្លើយប្រកបដោយភាពច្បាស់លាស់ និងត្រឹមត្រូវ។ អ្នកស្រាវជ្រាវក៏បានសុំការអនុញ្ញាតថតសំឡេងពេលធ្វើសម្ភាស ដើម្បីថតយកខ្លឹមសារសំឡេងទាំងស្រុង ទុកសម្រាប់ស្តាប់ឡើងវិញ ងាយស្រួលក្នុងការវិភាគឱ្យបានល្អិតល្អន់ ជាពិសេសទុកសម្រាប់ធ្វើជាសម្តីដកស្រង់នៅត្រង់ចំណុចសំខាន់ណាមួយ។ បន្ទាប់អ្នកសម្ភាសន៍បានជូនលិខិតព្រមព្រៀងផ្តល់បទសម្ភាសន៍មួយច្បាប់ ដល់អ្នកចូលរួមសម្ភាសន៍ចុះហត្ថលេខាយល់ព្រម ដើម្បីទុកជាឯកសារ។

ពេលអ្នកចូលរួមយល់ព្រមឱ្យធ្វើបទសម្ភាសន៍ អ្នកសម្ភាសន៍ក៏បានចាប់ផ្តើមសួរសំណួរ និងធ្វើការកត់ត្រារាល់ចម្លើយដែលអ្នកចូលរួមបានឆ្លើយតបដោយសង្ខេបខ្លីៗ និងប្រកាន់ខ្លឹមសារគោលនៃចម្លើយតាមសំណួរ នីមួយៗ។ អ្នកស្រាវជ្រាវបានកត់ត្រាការសម្ភាសន៍ដោយរក្សាភាពយកចិត្តទុកដាក់ជាមួយដៃគូសន្ទនា ដើម្បីកុំឱ្យខកខានក្នុងការផ្តល់ព័ត៌មានដល់អ្នកស្រាវជ្រាវ ឬមានការរំខានដល់លំហូរនៃការឆ្លើយសំណួររបស់អ្នកចូលរួម។ បទសម្ភាសន៍ធ្វើឡើងនៅក្នុងបន្ទប់ធ្វើការដែលមានបរិយាកាសល្អ មិនមានសំឡេងរំខាន និងបរិវេណ ទីធ្លាសាលារៀនដូចជាបង្គុយ ដែលគ្មានការរំខានពីមនុស្សជុំវិញឡើយ។ ដំណើរការសម្ភាសប្រព្រឹត្តទៅរយៈពេល ៤០នាទី ទៅ ១ម៉ោង រាប់ទាំងពីចាប់ផ្តើមរហូតដល់ចប់កិច្ចសម្ភាសន៍។

នៅក្រោយពេលសម្ភាស អ្នកស្រាវជ្រាវក៏បានថ្លែងអំណរគុណចំពោះកិច្ចសហការ និងការផ្តល់ព័ត៌មានយ៉ាងក្បោះក្បាយដល់កិច្ចសម្ភាសន៍ និងបានស្នើសុំការអនុញ្ញាតហៅទូរស័ព្ទមកកាន់អ្នកផ្តល់បទសម្ភាសន៍ម្តងទៀត ក្នុងករណីចំបាច់ណាមួយ ដូចជាព័ត៌មានមិនគ្រប់គ្រាន់ ករណីសុំការបំភ្លឺបន្ថែម ឬកខ្វះខាតដោយអចេតនារាល់ចំណុចណាមួយ ដើម្បីទទួលបានព័ត៌មានបន្ថែមទាក់ទងនឹងការអនុវត្តកម្មវិធីសាលាកុមារមេត្រី ក្រោមការដឹកនាំ និងគ្រប់គ្រងរបស់អ្នកផ្តល់បទសម្ភាសន៍។

## ៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ

### ៣.៥.១ ការវិភាគកម្រងសំណួរ

ទិន្នន័យកម្រងសំណួរនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានត្រួតពិនិត្យ រៀបចំ បែងចែកតាមប្រភេទ និងវិភាគបកស្រាយ។ ដើម្បីធានាពីសុពលភាព និងភាពជឿជាក់លើទិន្នន័យនៃការវិភាគលើកម្រងសំណួរ អ្នក

សិក្សាស្រាវជ្រាវបានប្រើកម្មវិធីស្ថិតិ (SPSS) គឺត្រូវបានបកស្រាយដាក់ចូលក្នុងតារាងទិន្នន័យ (Data Analysis) ដើម្បីសិក្សាពីភាគរយ (Percentage) នៃអ្នកចូលរួមដែលបានបំពេញកម្រងសំណួរ ចំនួននៃសំណាក (Frequency) ហើយកតម្លៃមធ្យម (Mean) និងពិនិត្យមើលគម្លាតស្តង់ដា (Standard deviation) ចំពោះតម្លៃមធ្យមដែលរកឃើញនោះមានភាពខុសគ្នាកម្រិតណា អាចទទួលយកបានឬទេ (Statistically significant) ទៅលើការអនុវត្តលើសមាសភាគទាំង ៦ របស់កម្មវិធីកុមារមេត្រី។

នៅក្នុងកម្រងសំណួរបែបបរិមាណវិស័យរបស់គ្រូ ពីលេខរៀងទី១ ដល់លេខរៀងទី ១១៦ ប្រើប្រាស់ទម្រង់ Rating Scale របស់ Likert (1932) មាន ៥ កម្រិត គឺ (១) កម្រិតតិចបំផុត, (២) តិច, (៣) មធ្យម, (៤) ច្រើន, និង(៥) ច្រើនបំផុត។

តារាង Rating Scale របស់ Likert (1932)៖

| |
|---|
| [១= កម្រិតតិចបំផុត], [២= តិច], [៣= មធ្យម], [៤= ច្រើន], [៥= ច្រើនបំផុត] |

ការកំណត់ពិន្ទុលើតម្លៃមធ្យម គឺយកតាមលំនាំកម្រិតពិន្ទុរបស់ Boonchom Srisa-ard (Wannatawee, Worakham, & Panya, 2017)

M= 1.00 – 1.50 ទាបបំផុត

M= 1.51 – 2.50 ទាប

M= 2.51 – 3.50 មធ្យម

M= 3.51 – 4.50 ខ្ពស់

M= 4.51 – 5.00 ខ្ពស់បំផុត

គម្លាតស្តង់ដា (Standard Deviation) គឺជារង្វាស់នៃរបៀបដែលទិន្នន័យបែកខ្ញែកទាក់ទងទៅនឹងតម្លៃមធ្យម។ គម្លាតស្តង់ដាទាប ឬតូចបង្ហាញថាទិន្នន័យត្រូវបានប្រមូលផ្តុំយ៉ាងតឹងរ៉ឹងជុំវិញមធ្យម ហើយគម្លាតស្តង់ដារខ្ពស់ ឬធំបង្ហាញថាទិន្នន័យត្រូវបានរីករាលដាល (គម្លាត) កាន់តែច្រើន។ គម្លាតស្តង់ដារទាបមានន័យថាទិន្នន័យត្រូវបានចង្កោមជុំវិញមធ្យម ហើយគម្លាតស្តង់ដារខ្ពស់បង្ហាញថាទិន្នន័យត្រូវបានរីករាល

ដាលកាន់តែច្រើន (អ្នកបំពេញជ្រើសរើសកម្រិតចង្អុលបង្ហាញផ្សេងៗគ្នា)។ គម្លាតស្តង់ដារនៅជិតសូន្យ បង្ហាញថាចំណុចទិន្នន័យគឺនៅជិតមធ្យម ចំណែកគម្លាតស្តង់ដារខ្ពស់ ឬទាបបង្ហាញថាចំណុចទិន្នន័យរៀងគ្នាខាងលើ ឬខាងក្រោមមធ្យម (Deborah, 2021)។

ជាទូទៅតម្លៃនៃគម្លាតស្តង់ដា មិនបានបញ្ជាក់ថាទីន្ន័យ "ល្អ" ឬ "មិនល្អ" នោះទេ វាគ្រាន់តែជាការបង្ហាញពីបម្រែបម្រួលនៃតម្លៃមធ្យមដែលត្រូវបានគេវាស់វែងតែប៉ុណ្ណោះ។ តាមការសិក្សា គេអាចសន្និដ្ឋានបានថា គម្លាតស្តង់ដាតូចជាងលេខមួយ (SD< 1) ជាទិន្នន័យដែលមិនមានគម្លាតគ្នាឆ្ងាយ ផ្ទុយមកវិញតម្លៃគម្លាតស្តង់ដា SD> 1 មានន័យថាទិន្នន័យមានគម្លាតគ្នាឆ្ងាយ។

ដើម្បីអះអាងទិន្នន័យដែលយកមកបកស្រាយ កាន់តែមានភាពជឿជាក់ អ្នកស្រាវជ្រាវបានអនុវត្តតាមច្បាប់របស់ George and Mallery (2003)៖

> Alpha > 0.9 (ល្អប្រសើរ), > 0.8 (ល្អ), > .7 (អាចទទួលយកបាន), > 0.6 (ក្នុងការពិចារណា),
>
> > 0.5(កម្រិតជឿជាក់តិចតួច), and < 0.5 (មិនអាចទទួលយកបាន)

មេគុណអាល់ហ្វារបស់ Cronbach វាស់ស្ទង់ភាពស៊ីសង្វាក់ផ្ទៃក្នុង ឬភាពជឿជាក់នៃសំណុំនៃធាតុស្ទង់មតិមួយ។ វាត្រូវបានគេប្រើជាទូទៅបំផុតនៅពេលដែលអ្នកមានសំណួរ Likert ច្រើននៅក្នុងការស្ទង់មតិ/កម្រងសំណួរដែលបង្កើតជាមាត្រដ្ឋាន ហើយអ្នកចង់កំណត់ថាតើមាត្រដ្ឋានអាចទុកចិត្តបានដែរឬទេ។

កម្រិតវាយតម្លៃរបស់អាល់ហ្វា (Alpha)៖

< 0.5 ទិន្នន័យមិនអាចយកជាការបាន

> 0.5 ទិន្នន័យមានភាពជឿជាក់តិចតួច

> 0.6 ទិន្នន័យត្រូវពិចារណា

> 0.7 ទិន្នន័យអាចទទួលយកបាន

> 0.8 ទិន្នន័យល្អជឿជាក់បាន

> 0.9 ទិន្នន័យល្អប្រសើរ

### ៣.៥.២ ការវិភាគសម្ភាសន៍ផ្ទាល់

ទិន្នន័យសម្ភាសន៍ផ្ទាល់នៃការសិក្សាស្រាវជ្រាវនេះ គឺត្រូវបានធ្វើការត្រួតពិនិត្យ រៀបចំនិងបែងចែកតាមប្រភេទ (Coding) និងវិភាគបកស្រាយ។ ទិន្នន័យនៃការវិភាគលើសម្ភាសន៍ផ្ទាល់ គឺត្រូវបានបកស្រាយដាក់ចូលក្នុងតារាងទិន្នន័យ និងធ្វើការប្រៀបធៀបគ្នា ដោយរកចំណុចរួម ឬចំណុចស្រដៀងគ្នានៃចម្លើយដែលបានសម្ភាសន៍ ដើម្បីកត់ត្រាចូលក្នុងតារាងចម្លើយ។ ភាពខុសគ្នាមួយចំនួន ក៏ត្រូវបានកត់សម្គាល់ និងធ្វើការសិក្សាវិភាគបន្ថែមលើចម្លើយដែលមានភាពលម្អៀងច្រើន ដោយសារមូលហេតុផ្សេងៗពាក់ព័ន្ធនឹងភាពមិនសុក្រឹត្យនៃចម្លើយ ភាពមិនច្បាស់លាស់ និងការពុំសូវយល់ដឹងរបស់អ្នកចូលរួមសម្ភាសន៍។

## ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានអនុញ្ញាតដោយក្រសួងអប់រំ យុវជន និងកីឡា យោងលិខិតលេខ ៤០៨២ អយក.វជអ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជម្រាបមកមន្ទីរអប់រំ រាជធានីខេត្ត ដើម្បីជួយសម្របសម្រួលលើការចុះប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវរយៈពេល ១ ខែកន្លះ។ អ្នកសិក្សាស្រាវជ្រាវបានយកលិខិតនោះ ប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ បន្ទាប់មកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានចេញលិខិតរដ្ឋបាលមួយច្បាប់ទៀតអនុញ្ញាតឱ្យសាមីជនអាចចុះប្រមូលទិន្នន័យបាននៅតាមសាលាគោលដៅក្នុងខេត្តដែលបានគ្រោងទុក ហើយសាមីជនបានយកលិខិតទៅប្រគល់ជូនតាមសាលាបឋមសិក្សាសាធារណៈគោលដៅនៅក្នុងខេត្ត ដើម្បីធ្វើការប្រមូលទិន្នន័យ និងសម្ភាសន៍។

ការស្រាវជ្រាវនេះបានរក្សាសុវត្ថិភាពបុគ្គល និងធានាលើអត្តសញ្ញាណរបស់អ្នកចូលរួមទាំងអ្នកចូលរួមសម្ភាសន៍ និងអ្នកបំពេញកម្រងសំណួរ។ អ្នកស្រាវជ្រាវបានស្នើសុំសេចក្តីអនុញ្ញាតពីអ្នកចូលរួម ដោយការធ្វើកំណត់ហេតុនៃកិច្ចព្រមព្រៀងសម្ភាសន៍ ដោយមានចុះហត្ថលេខាពីភាគីចូលរួមត្រឹមត្រូវ។ ព័ត៌មានអំពីបុគ្គលភាព រូបភាព ខ្សែអាត់សំឡេង (Voice record) និងអត្តសញ្ញាណរបស់អ្នកចូលរួម មិនត្រូវបានបង្ហាញជាសាធារណៈឡើយ។ ទស្សនៈ និងចម្លើយរបស់អ្នកចូលរួម ត្រូវបានធ្វើការវិភាគ និងបកស្រាយដោយការ

គោរពតាមក្រមសីលធម៌នៃការស្រាវជ្រាវក្នុងការសិក្សាអំពី(១). សិក្សាពីស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិត បឋមសិក្សា (២). ឈ្វេងយល់ពីបញ្ហាប្រឈមដែលកើតមានក្នុងពេលអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ។

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

ជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើការបកស្រាយពីលទ្ធផលស្រាវជ្រាវ និងការពិភាក្សាលើលទ្ធផលស្រាវជ្រាវ។ លទ្ធផលស្រាវជ្រាវ ដែលបានមកអ្នកស្រាវជ្រាវនឹងធ្វើការវិភាគទៅតាមផ្នែកនីមួយៗនៃទម្រង់ស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យ។ លទ្ធផលស្រាវជ្រាវបែបបរិមាណវិស័យ អ្នកស្រាវជ្រាវនឹងប្រើប្រាស់កម្មវិធីកុំព្យូទ័រ (SPSS) ដើម្បីវិភាគលើលទ្ធផលដែលទទួលបានតាមរយៈកម្រងសំណួរ ចំនួន ១៥១កម្រងសំណួរ ប្រមូលបានពីលោកគ្រូ-អ្នកគ្រូ ដែលបង្រៀននៅតាមសាលាបឋមសិក្សា ក្នុងស្រុកចំនួន បី នៃខេត្តត្បូងឃ្មុំ។ លទ្ធផលនៃការប្រមូលទិន្នន័យតាមរយៈការធ្វើកម្រងសំណួរ បានឆ្លុះបញ្ចាំងទៅនឹងសំណួរស្រាវជ្រាវពីរផ្នែកសំខាន់ៗ មាន ១) ស្ថានភាពនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី (CFS) ដែលនឹងចង្អុលបង្ហាញនូវកម្រិតអនុវត្តលើសមាសភាគទាំង ៦ របស់កម្មវិធី និង ២) បង្ហាញពីបញ្ហាប្រឈម ឬផលលំបាកដែលសាលារៀនបានជួបប្រទះ។

លទ្ធផលស្រាវជ្រាវបែបគុណវិស័យ ដែលទទួលបានតាមរយៈការសម្ភាសន៍ចេញពីសំណាកចំនួន ១២រូប (រួមមាននាយកសាលា ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៅមន្ទីរអប់រំ និងការិយាល័យអប់រំស្រុក) អ្នកស្រាវជ្រាវបានធ្វើចំណាត់ថ្នាក់ (Classify) នៃប្រភេទចម្លើយ ហើយធ្វើការតំរៀប (Coding) លើមតិយោបល់ដែលដូចគ្នា ឬស្រដៀងគ្នា ដើម្បីទាញសេចក្តីសន្និដ្ឋានរួមមួយ។ លទ្ធផលដែលទទួលបានពី ការធ្វើសម្ភាសន៍នឹងទៅបំពេញបន្ថែមលើអ្វីដែលបានរកឃើញតាមរយៈកម្រងសំណួរស្ទង់មតិឱ្យកាន់តែមានភាពច្បាស់លាស់ជាពិសេសបានឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំងពីរផ្នែកខាងលើឱ្យកាន់តែស៊ីជម្រៅ និងមានភាពជឿជាក់ខ្ពស់។

ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ រួមមានស្ថានភាពនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី ដែលសាលារៀនធ្វើកន្លងមកទទួលបានលទ្ធផលកម្រិតណា ប្រសិទ្ធភាពបែបណា និងពិភាក្សាលើបញ្ហាប្រឈមនានាដែលសាលាជួបប្រទះក្នុងកិច្ចដំណើរការកម្មវិធី។

## ៤.១ លទ្ធផលបរិមាណវិស័យ

### ៤.១.១ ព័ត៌មានទូទៅនៃភាគសំណាកដែលប្រមូលបាន

ទិន្នន័យរួមអំពីព័ត៌មានទូទៅនៃភាគសំណាក់ដែលប្រមូលបាន

| ភាគសំណាក | | ចំនួន (នាក់) |
|---|---|---|
| គ្រូបង្រៀននៅបឋមសិក្សា | ស្រុកត្បូងឃ្មុំ | ៥១ |
| | ស្រុកអូរាំងឪ | ៥០ |
| | ស្រុកតំបែរ | ៥០ |
| សរុប | | ១៥១ |

នៅក្នុងតារាងខាងលើបង្ហាញថា ចំនួនសំណាកដែលបានជ្រើសរើសសម្រាប់ការប្រមូលទិន្នន័យលើកម្រងសំណួរ មានចំនួន ១៥៦សំណាក ហើយសំណាកដែលប្រមូលបានមកវិញសរុបចំនួន ១៥១ ស្មើនឹង ៩៦.៧៩% នៃចំនួនសំណាកសរុប។ ក្នុងនោះ៖ អ្នកស្រាវជ្រាវបានរកឃើញសំណាកដែលមានភាពមិនច្បាស់លាស់ មិនបានបំពេញអំពីព័ត៌មានទូទៅ និងមិនបានគូសសញ្ញាគ្រីស (√) លើកម្រងសំណួរ គ្រប់សំណួរចំនួន ២ សំណាក និងសំណាកដែលបាត់បង់ ដោយមិនបានត្រឡប់មកវិញចំនួន ៣ សំណាក ស្មើនឹង ៣.២១%។ សំណាកដែលយកប្រើ និងធ្វើការវិភាគទិន្នន័យក្នុងការសិក្សាស្រាវជ្រាវនេះ ត្រូវមានព័ត៌មានទូទៅគ្រប់គ្រាន់ បានបំពេញទៅតាមកម្រងសំណួរនីមួយ និងអាចកំណត់បានលើចម្លើយដែលបានឆ្លើយតបទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗ។

#### ៤.១.១.១ ចំនួនអ្នកឆ្លើយតបគិតតាមភេទ



នៅក្នុងចំណោមអ្នកចូលរួមបំពេញកម្រងសំណួរទាំង ១៥១នាក់ យើងឃើញថា មានអ្នកគ្រូ ចំនួន ៩៥នាក់ ដែលបានបំពេញស្មើនឹង ៦២.៩១% ច្រើនជាងចំនួនលោកគ្រូដែលបានចូលរួមបំពេញមានចំនួនត្រឹមតែ ៥៥នាក់ប៉ុណ្ណោះ។ ករណីគ្រូជាស្ត្រីចូលរួមបំពេញច្រើនជាងគ្រូជាបុរស ដោយសារតែនៅតាមគ្រឹស្ថានបឋមសិក្សានីមួយៗ ដែលអ្នកស្រាវជ្រាវបានជ្រើសរើស មានចំនួនអ្នកគ្រូ ច្រើនជាងលោកគ្រូ ស្ទើរតែគ្រប់សាលា និងម្យ៉ាងទៀតក៏ដោយសារសាលាមួយចំនួនមានគ្រូជាបុរស កាន់តួនាទីជាគណៈគ្រប់គ្រង ដូច្នេះអ្នកសិក្សាស្រាវជ្រាវមិនបានកំណត់យកដើម្បីឱ្យបំពេញកម្រងសំណួរ។

ការកំណត់យកភេទស្រី ឬប្រុសក្នុងការចូលរួមបំពេញកម្រងសំណួរ មិនមែនជាបញ្ហាចោទសម្រាប់លទ្ធផលនៃការស្រាវជ្រាវនោះឡើយ ដោយសារគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលមកដូចៗគ្នា និងមានគុណវុឌ្ឍិ និងបំណិនវិជ្ជាជីវៈប្រហាក់ប្រហែលគ្នា។ សម្រាប់ការបង្រៀននៅកម្រិតបឋមសិក្សា យើងសង្កេតឃើញថា សិស្សានុសិស្សជាកុមារា និងកុមារី មានទម្លាប់ចូលចិត្តរៀនជាមួយអ្នកគ្រូ ជាងលោកគ្រូ នេះក៏ដោយសារតែគ្រូបង្រៀនជាស្ត្រី មានកាយវិការទន់ភ្លន់ សម្តីពិរោះ ចេះយល់ចិត្ត ចេះលួងលោម និងលើកទឹកចិត្តសិស្សច្រើនជាងគ្រូបង្រៀនជាបុរស។

### ៤.១.១.២ ចំនួនអ្នកឆ្លើយតបគិតតាមអាយុ



ក្រាបសសរខាងលើ  បង្ហាញពីចន្លោះអាយុអ្នកចូលរួមបំពេញលើកម្រងសំណួរស្រាវជ្រាវ  ក្នុងនោះ ឃើញមានលោកគ្រូ អ្នកគ្រូស្ថិតនៅអាយុចន្លោះពី ៣១ ឆ្នាំ ដល់ ៤០ ឆ្នាំ មានចំនួនច្រើនជាងគេ រហូតដល់ ៦០នាក់ស្មើនឹង ៣៩.៧០% នៃចំនួនគ្រូសរុប ១៥១នាក់។ ដោយឡែកគ្រូបង្រៀននៅអាយុចន្លោះ ២០ ឆ្នាំទៅ ៣០ ឆ្នាំ និងអាយុ ៤១ ឆ្នាំឡើង មានចំនួនប្រហាក់ប្រហែលគ្នា។ លោកគ្រូអ្នកគ្រូដែលមានអាយុនៅចន្លោះនេះ មានន័យថាពួកគាត់សុទ្ធសឹងតែមានសមត្ថភាពពេញលេញ បទពិសោធន៍ និងមានសុខភាពល្អ សម្រាប់ការបំពេញការងារបង្រៀនប្រចាំថ្ងៃរបស់ពួកគាត់ផងដែរ។

### ៤.១.១.៣ ចំនួនអ្នកឆ្លើយតបគិតតាមកម្រិតវប្បធម៌

**ទិន្នន័យអ្នកឆ្លើយតបតាមកម្រិតវប្បធម៌**




ក្រាបនេះ បង្ហាញពីកម្រិតវប្បធម៌នៃការអប់រំរបស់អ្នកចូលរួមធ្វើកម្រងសំណួរ។ តាមទិន្នន័យយើងឃើញថា ស្ថិតិអ្នកដែលទទួលបានការអប់រំ មានសញ្ញាបត្រកម្រិតមធ្យមសិក្សាទុតិយភូមិ មានចំនួនច្រើនលើសលប់ចំនួន ១០៧នាក់ ស្មើនឹង ៧០.៩០% ហើយអ្នកដែលមានកម្រិតសញ្ញាបត្រខ្ពស់ជាងបរិញ្ញាបត្រ មានត្រឹមតែ ៣នាក់ ស្មើនឹង ២% ប៉ុណ្ណោះ។ ក្នុងនោះយើងក៏ឃើញមានលោកគ្រូ អ្នកគ្រូដែលមានកម្រិត

សញ្ញាបត្របរិញ្ញាបត្រ មានចំនួន ២៧នាក់ ស្មើនឹង ១៧.៩០% និងលោកគ្រូ អ្នកគ្រូមានកម្រិតសញ្ញាបត្រត្រឹមមធ្យមសិក្សាបឋមភូមិ មានចំនួន ១៤នាក់ផងដែរស្មើនឹង ៩.៣០% ដែលបានចូលរួមបំពេញកម្រងសំណួរ។

កម្រិតចំណេះដឹង និងគុណវុឌ្ឍិគ្រូបង្រៀន បានជះឥទ្ធិពលដល់ការយល់ឃើញលើសកម្មភាពនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី ជាពិសេសលើការឆ្លើយតបទៅនឹងសូចនាករនីមួយៗដែលបានវាស់វែង។ ជាងនេះទៅទៀត វាក៏បានជះឥទ្ធិពលលើការបង្រៀនរបស់ពួកគាត់ផ្ទាល់ និងការរៀនរបស់សិស្សផងដែរ។ តែទោះបីជាយ៉ាងណាក៏ដោយ ពួកគាត់មានបំណិនវិជ្ជាជីវៈ មានបទពិសោធន៍នៃការបំពេញការងារយូរឆ្នាំ និងមានវិន័យ និងក្រមសីលធម៌វិជ្ជាជីវគ្រូបង្រៀន ដែលកត្តាទាំងនេះ ធ្វើឱ្យទិន្នន័យដែលយើងប្រមូលបាននៅតែមានភាពត្រឹមត្រូវអាចទទួលយកបាន។

### ៤.១.១.៤ ចំនួនអ្នកឆ្លើយតបគិតតាមបទពិសោធន៍ការងារ

**ក្រាបផ្និតបង្ហាញទិន្នន័យអ្នកឆ្លើយតបតាមបទពិសោធន៍បម្រើការងារ**




ក្រាបផ្និតនេះបង្ហាញថា អ្នកដែលមានបទពិសោធន៍បំពេញការងារចន្លោះពី ៥ ឆ្នាំដល់ ១០ ឆ្នាំ មានចំនួន ៣៩នាក់ និងចន្លោះពី ១១ ឆ្នាំ ដល់ ១៥ ឆ្នាំ មានចំនួន ៣៤នាក់បានចូលរួមបំពេញកម្រងសំណួរច្រើនជាងគេដែលបទពិសោធន៍ចន្លោះឆ្នាំទាំងនេះ មានន័យថា គ្រូបង្រៀនស្ថិតក្នុងវ័យកណ្ដាលមិនចាស់ពេក

ហើយក៏មិនក្មេងពេកដែរ។ ចំណុចនេះក៏បាន សបញ្ជាក់ថា នៅតាមសាលាបឋមសិក្សា មានគ្រូបង្រៀនដែលមានបទពិសោធន៍បង្រៀនច្រើនឆ្នាំផង ថែមទាំងជាគ្រូដែលស្ថិតនៅក្នុងបរិបទនៃការសិក្សាស្រាវជ្រាវអភិវឌ្ឍខ្លួនបន្ថែមទៀតផងដែរ។

គ្រូដែលមានបទពិសោធន៍តិចជាង ៥ ឆ្នាំ មានចំនួន ២៦នាក់ ស្មើនឹង ១៧.២០% ដែលសុទ្ធសឹងជាគ្រូបង្រៀនទើបទទួលបានការបណ្តុះបណ្តាលថ្មីៗ និងមានកម្រិតយល់ដឹងខ្ពស់លើវិធីសាស្ត្របង្រៀនថ្មីៗ។ យ៉ាងណាមិញ ក៏មានលោកគ្រូ អ្នកគ្រូ ដែលមានបទពិសោធន៍បម្រើការងារលើសពី ២០ ឆ្នាំប្រមាណ ២១.២០% ស្មើនឹងចំនួន ៣២នាក់ចូលរួមឆ្លើយតបកម្រងសំណួរ ដែលពួកគាត់សុទ្ធតែជាអ្នកមានបទពិសោធន៍ការងារយូរឆ្នាំ និងជាអ្នកដែលបានដឹង បាបចូលរួមអនុវត្តជាមួយ កម្មវិធីសាលាកុមារមេត្រីនាពេលកន្លងមក តាំងពីអនុវត្តដំបូងនៅកម្ពុជាអំឡុង ឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ន (ក្រសួងអប់រំ ២០០៨)។ គ្រូបង្រៀនដែលមានបទពិសោធន៍ការងារយូរឆ្នាំពួកគាត់អាចកំណត់បាននូវស្ថានភាពអនុវត្តមួយច្បាស់លាស់ ហើយអាចធ្វើការវាយតម្លៃ និងចង្អុលបង្ហាញនូវកម្រិតនៃការអនុវត្តនាពេលកន្លងមក និងក្នុងពេលបច្ចុប្បន្ន។

**កម្រិតជឿជាក់លើទិន្នន័យដែលប្រមូលបានពីកម្រងសំណួរ**

| Cronbach's Alpha | N of Items |
|---|---|
| 0.93 | 13 |

ផ្អែកលើទិន្នន័យដែលប្រមូលបានពីកម្រងសំណួរ អ្នកស្រាវជ្រាវបានសិក្សាលើកម្រិតជឿជាក់លើទិន្នន័យក្នុងកម្មវិធី SPSS តាមរូបមន្ត Cronbach's Alpha ហើយទទួលបានលទ្ធផល Alpha= 0.93 ដែលមានន័យថាទិន្នន័យដែលបានវាស់វែងសម្រាប់ការស្រាវជ្រាវ មានភាពទុកចិត្ត និងជឿជាក់បានកម្រិតណា។

### ៤.១.២ កម្រិតអនុវត្តលើសមាសភាគទី១

**សមាសភាគទី១៖ ធានាកុមារទាំងអស់បានចូលរៀន**

តារាង១ កម្រិតអនុវត្តលើការជានាកុមារចូលរៀន

| ល.រ | បរិយាយ | N | Mean | Std. Deviation | កម្រិតវាស់វែង |
|---|---|---|---|---|---|
| 1 | កុមារដល់វ័យសិក្សាទាំងអស់បានចូលរៀនតាមចំណុចដៅនៃផែនការ | 151 | 4.16 | 0.73 | ល្អបង្គួរ |
| 2 | គណៈកម្មការទ្រទ្រង់សាលារៀន ចូលរួមរៀបចំចុះឈ្មោះកុមារចូលរៀន | 151 | 3.92 | 1.02 | ល្អបង្គួរ |
| 3 | បានរៀបចំស្ថិតិកុមារទាំងអស់( កុមារពិការ កុមារជួបការលំបាក......) | 151 | 4.11 | 0.88 | ល្អបង្គួរ |
| 4 | បានប្រើប្រាស់ទិន្នន័យទាំងអស់ខាងលើនេះក្នុងការកសាងផែនការអភិវឌ្ឍសាលារៀន | 151 | 4.09 | 0.86 | ល្អបង្គួរ |
| 5 | បានបង្កើតក្រុមបណ្តាញ និងដំណើរការក្រុមបណ្តាញតាមភូមិ | 151 | 3.05 | 1.35 | មធ្យម |
| 6 | ស្ថិតិ ទិន្នន័យសិស្សត្រូវបានប្រមូលចងក្រង វិភាគ និងរក្សាទុកជាឯកសារ | 151 | 4.01 | 0.93 | ល្អបង្គួរ |
| 7 | កុមារនៅក្នុងផែនទីសិក្សា ដែលមិនបានចូលរៀនត្រូវបានកំណត់ និងប្រមូលឱ្យចូលរៀន | 151 | 3.78 | 0.91 | ល្អបង្គួរ |
| 8 | ផែនទីសិក្សា និងផែនទីខ្នងផ្ទះ តាំងបង្ហាញនៅទីចាត់ការ | 151 | 3.47 | 1.35 | មធ្យម |
| 9 | ប្រមូលកុមារដែលជួបការលំបាក ហើយបោះបង់ការសិក្សា ឱ្យចូលរៀន | 151 | 3.33 | 1.20 | មធ្យម |
| 10 | កំណត់មុខសញ្ញាសិស្សដែលអវត្តមានញឹកញាប់ និងយន្តការគាំទ្រ | 151 | 3.70 | 1.01 | ល្អបង្គួរ |
| 11 | អន្តរាគមន៍ និងគាំទ្រចំពោះកុមារជួបការលំបាក ឱ្យបានរៀនសូត្រដូចកុមារធម្មតា | 151 | 3.67 | 0.95 | ល្អបង្គួរ |
| 12 | មានកិច្ចការពិសេស និងសកម្មភាពបង្រៀនពិសេសសម្រាប់អ្នកអវត្តមានញឹកញាប់ | 151 | 3.38 | 1.01 | មធ្យម |
| 13 | រៀបចំបន្ទប់រៀន ដែលអាចឱ្យកុមារពិការចល័តបាន | 151 | 3.62 | 1.27 | ល្អបង្គួរ |
| 14 | អគារសិក្សា និងទីធ្លាសាលាមានជម្រាលសម្រាប់កុមារពិការចល័តបាន | 151 | 3.51 | 1.26 | ល្អបង្គួរ |
| 15 | បន្ទប់ទឹកបង្គន់លក្ខណៈងាយស្រួលឱ្យកុមារពិការប្រើប្រាស់បាន | 151 | 3.51 | 1.32 | ល្អបង្គួរ |
| សរុបរួមសមាសភាគទី១ | | 151 | 3.69 | 1.07 | ល្អបង្គួរ |

តារាង១ ខាងលើបង្ហាញថា សូចនាករនៃសមាសភាគទី១ មានតម្លៃមធ្យមខុសៗគ្នា។ លំដាប់ពិន្ទុលើការចូលរៀនរបស់កុមារ ស្របតាមចំណុចដៅនៃផែនការ ស្ថិតក្នុងកម្រិតខ្ពស់លំដាប់លេខ១ ដែលមានតម្លៃមធ្យម M= 4.16 និងគម្លាតស្តង់ដា SD= 0.73។ ផ្នែកការរៀបចំស្ថិតិកុមារ (កុមារធម្មតា និងកុមារពិការ) ទទួលបានកម្រិតពិន្ទុខ្ពស់លំដាប់លេខ ២ ដែលមាន M= 4.11, SD= 0.88 និងការប្រើប្រាស់ទិន្នន័យកុមារខាងលើ ដើម្បីធ្វើផែនការអភិវឌ្ឍសាលារៀនបានពិន្ទុខ្ពស់លំដាប់ទី ៣ ដែលមាន M= 4.09, SD= 0.86។ ដោយឡែក ការបង្កើតក្រុមបណ្តាញតាមភូមិ និងដំណើរការក្រុមបណ្តាយ មានលំដាប់ពិន្ទុទាបជាងគេ ដែលមានមធ្យមពិន្ទុ M= 3.05 និងគម្លាតស្តង់ដា SD= 1.35។ ជារួមយើងឃើញថា សមាសភាគទី១ ការចូលរៀនរបស់កុមារ មានមធ្យមពិន្ទុរួម M= 3.69។ លទ្ធផលនេះបង្ហាញថា សមាសភាគទី១ ទទួលបានលទ្ធផលកម្រិតល្អបង្គួរ ដែលមានចំនួន ១៥ សំណួរ ផ្តោតលើការអនុវត្តកម្មវិធីសាលាកុមារមេត្រី (CFS)។

ការធានាការចូលរៀនរបស់កុមារ សំដៅដល់ការធ្វើសកម្មភាពទាំងឡាយដែលគាំទ្រយន្តការនៃការចូលរៀនប្រកបដោយសមភាព សមធម៌ និងបរិយាបន្ន (ក្រសួងអប់រំ ២០១៩)។ ដើម្បីធានាដល់ការចូលរៀនប្រកបដោយប្រសិទ្ធភាព គណៈគ្រប់គ្រងសាលារៀន ត្រូវធ្វើជំរឿនស្ថិតិកុមារដែលត្រូវដល់វ័យសិក្សានៅក្នុងភូមិសិក្សាចំណុះសាលារៀនឱ្យបានច្បាស់លាស់ ទិន្នន័យពិតប្រាកដ និងប្រើប្រាស់ទិន្នន័យទាំងនោះសម្រាប់ធ្វើជាផែនការនៃទទួលសិស្សចូលរៀនថ្មីតាមឆ្នាំសិក្សានីមួយៗ។

យោងតាមតារាងទិន្នន័យបង្ហាញថា សាលារៀនភាគច្រើនបានយកចិត្តទុកដាក់ចំពោះការប្រមូលកុមារគ្រប់អាយុឱ្យចូលរៀន ស្របតាមផែនការដែលបានកំណត់។ ក្នុងន័យនេះវាស្របទៅនឹងស្ថិតិរបស់សន្និបាតអប់រំ ឆ្នាំ២០២២ នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ បានចង្អុលបង្ហាញពីអត្រាពិតនៃការចូលរៀនថ្មី មានចំនួន ៨៨.៧៣% ដែលជាតួរលេខមួយបង្ហាញពីការអត្រានៃការចូលរៀនខ្ពស់។ ប៉ុន្តែបើក្រឡេកទៅមើលលើអត្រាពិតនៃការសិក្សាវិញ កាលពីឆ្នាំ២០២១ មានចំនួន ៩៧.៨៤% ចំណែកនៅឆ្នាំ២០២២ ថយមកនៅត្រឹមតែ ៨៧.៩១%ប៉ុណ្ណោះ។ ថ្វីត្បិតតែអត្រាទិន្នន័យសន្និបាទមានការថយចុះរវាងឆ្នាំទាំងពីរនេះក៏ពិតមែន ប៉ុន្តែអត្រាភាគរយនៅតែរក្សាបានខ្ពស់ដដែល ដែលចំណុចនេះវាស្របទៅនឹងអ្វីដែលយើងបានរក

ឃើញតាមរយៈកម្រងសំណួរ ដែលបានឆ្លុះបញ្ចាំងពីការប្រមូលកុមារចូលរៀនទទួលបានភាគរយខ្ពស់ជាងគេ និងមានគម្លាតស្តង់ដារតិចជាងគេ ដែលធ្វើឱ្យយើងអាចសន្និដ្ឋានបានថាចំណុចនេះសាលារៀនបានអនុវត្ត សូចនាករទី១នេះមានប្រសិទ្ធភាព។

ទន្ទឹមនឹងសូចនាករទី១ នេះ ក៏យើងសង្កេតឃើញថា មានសូចនាករផ្សេងៗជាច្រើនទៀតដែល អនុវត្តមិនបានល្អ មានកម្រិតពិន្ទុទាប ដូចជាការបង្កើត និងដំណើរការក្រុមបណ្តាញតាមភូមិ មាន M= 3.05 និងមានគម្លាតស្តង់ដា SD= 1.35 ឃើញថានេះជាតួរលេខតិចជាងគេ ហើយសាលារៀនភាគច្រើនស្ទើតែទាំង អស់ដែលមិនបានអនុវត្ត និងមិនបានបង្កើតក្រុមបណ្តាញតាមភូមិនេះតែម្តង។ ការបង្កើតបណ្តាញតាមភូមិ មានសារៈសំខាន់ណាស់សម្រាប់គាំទ្រសមកម្មភាពប្រមូលកុមារចូលរៀន ដែលយើងត្រូវធ្វើមុនពេលយុទ្ធនា ការ ដូចជាការប្រជុំនៅតាមភូមិនីមួយៗ ដោយអញ្ជើញភាគីពាក់ព័ន្ធមកចូលរួមជាមួយ ដើម្បីពន្យល់ពីអ្វីដែល ជាគោលបំណងរបស់សាលារៀន។ នាយកសាលាត្រូវបែងចែកសមាសភាពអ្នកចុះស្រង់ស្ថិតិភូមិផ្ទាល់ ឬឃុំ ដោយសហការជាមួយអាជ្ញាធរ ហើយបែងចែកវិភាគឱ្យបានច្បាស់លាស់ពីចំនួនកុមារដែលបានចូលរៀន និង ចំនួនកុមារនៅក្រៅសាលារៀន (ក្រសួងអប់រំ ២០១៩)។

យោងតាមទិន្នន័យសម្ភាសពីនាយកសាលាមួយរូប គាត់បានលើកឡើងថា «ការប្រមូលកុមារគ្រប់ អាយុចូលរៀនគឺគាត់យកទិន្នន័យពីសាលាឃុំ ដើម្បីយកមកធ្វើចំណោលរកសិស្សដែលត្រូវចូលរៀនថ្នាក់ទី១ ដោយមិនបានចុះស្រង់ស្ថិតិផ្ទាល់ពីមូលដ្ឋានភូមិសិក្សានីមួយៗឡើយ» (#D01)។ ការយកទិន្នន័យទាំងស្រុង ពីសាលាឃុំបែបនេះ មិនទទួលបានទិន្នន័យប្រាកដនិយមឡើយ ពីព្រោះពេលដែលលោកមេភូមិ ឬសមាជិក ភូមិស្រង់ទិន្នន័យ អាចធ្វើមុនច្រើនខែ ជាហេតុនាំឱ្យកុមារមួយចំនួន មិនទាន់គ្រប់អាយុ ធ្វើឱ្យថយចុះខុសពី ជាក់ស្តែង។ ទន្ទឹមនឹងនេះក៏មានលោកនាយកសាលាមួយចំនួន បានលើកឡើងស្រដៀងៗគ្នា ពីរឿងអាយុនៃ ការចូលរៀនរបស់សិស្សនៅសាលារដ្ឋបច្ចុប្បន្ន ដោយកំណត់យក អាយុ ៦ឆ្នាំ ឬ ៧០ខែ តែកុមារមួយចំនួន ភាគច្រើនមកចុះឈ្មោះចូលរៀនថ្នាក់ទី១ ទាំងដែលមិនទាន់គ្រប់អាយុ ហើយសាលាមិនទទួល ត្រូវអាណា

ព្យាបាលបញ្ជូនទៅសាលាឯកជនវិញ។ នេះជាចំណុចមួយសំខាន់ដែរ ដែលក្នុងនាមសាលារៀនថាតើតម្រូវដាច់ខាតត្រូវតែគ្រប់អាយុទើបទទួល ឬខ្វះត្រឹម ៦ខែ ឬ៤ ខែអាចអនុញ្ញាតឱ្យចូលរៀនទី១ បាន ឬមិនបាន។

ផ្អែកលើក្របខ័ណ្ឌគោលនយោបាយ ក៏បានលើកឡើងពីការធានាប្រសិទ្ធភាពនៃការចូលរៀនដោយសមធម៌ និងបរិយាបន្ន និងធានាឱកាសសិក្សាពេញមួយជីវិត ដូច្នេះសាលាអាចបត់បែនតាមសភាពការជាក់ស្តែង។ ជាបទពិសោធន៍ដែលទទួលបានពីការសម្ភាសនាយិកា មួយរូប ដើម្បីដោះស្រាយបញ្ហាខាងលើ គាត់បានអនុញ្ញាតឱ្យសិស្សចូលរៀន ព្រោះសិស្សទាំងនោះស្ទើតែទាំងអស់បានឆ្លងកាត់មត្តេយ្យរួចហើយ និងឱ្យចូលរៀនតែស្ថិតក្នុងការផ្ញើបណ្តោះអាសន្ន ចាំលុះគ្រាគ្រប់អាយុ ទើបបញ្ចូលថ្នាក់ពេញលេញ។ ចំណុចមួយចំនួនទៀតពាក់ព័ន្ធនឹងរចនាសម្ព័ន្ធអគារសិក្សា និងបន្ទប់រៀន មានលក្ខណៈចាស់ទ្រុឌទ្រោម និងមួយចំនួនស្ទើតែបោះបង់ចោល ដែលនេះក៏ផ្អែកមួយយ៉ាងសំខាន់សម្រាប់ការទាក់ទាញកុមារឱ្យចង់រៀន ជាពិសេសគឺមិនបានការទុកចិត្តពីសំណាក់មានតាបិតាសិស្ស។

### ៤.១.៣ កម្រិតអនុវត្តសមាសភាគទី២

នៅក្នុងផ្នែកនេះ នឹងធ្វើការបង្ហាញនូវតារាងលទ្ធផលដែលបានវាស់វែងលើការអនុវត្តសមាសភាគទី ២ នៃកម្មវិធីសាលាកុមារមេត្រី តាមសូចនាករគោល ទាំង ៩ រួមមានធនធានក្នុងការបង្រៀន និងរៀន ការអនុវត្តកម្មវិធីសិក្សា ការប្រើប្រាស់សៀវភៅសិក្សាគោល និងឯកសារក្នុងការសិក្សា ស្តង់ដាកម្មវិធីសិក្សា សង្គារឹម និងសម្ភារពិសោធន៍ កម្មវិធីបំណិនជិវិត កម្មវិធីអប់រំពិសេស ការផ្តល់សេវាតម្រង់ទិសវិជ្ជាជីវៈ និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។

**សមាសភាគទី២៖ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន**

តារាង២ ការងារបច្ចេកទេសបង្រៀន និងរៀន

| ល.រ | បរិយាយ | N | Mean | Std. Deviation | កម្រិតវាស់វែង |
|---|---|---|---|---|---|
| 16 | ការរៀបចំបន្ទប់មុខវិជ្ជា (បន្ទប់គណិត បន្ទប់វិទ្យាសាស្ត្រ.....) | 151 | 1.69 | 1.05 | ខ្សោយ |
| 17 | មានបណ្ណាល័យសិក្សា និងដំណើរការរៀងរាល់ថ្ងៃ | 151 | 3.61 | 1.37 | ល្អបង្គួរ |
| 18 | រោងជាងផលិតសម្ភារៈបង្រៀន និងរៀន | 151 | 1.84 | 0.98 | ខ្សោយ |
| 19 | សួនជីវៈចម្រុះ និងការប្រើប្រាស់ក្នុងការបង្រៀន | 151 | 2.42 | 1.21 | ខ្សោយ |

| | | | | | |
|---|---|---|---|---|---|
| 20 | ការអញ្ជើញសហគមន៍ក្នុងការផ្ដល់បទឧទ្ទេសពីជំនាញផ្សេងៗ | 151 | 2.56 | 1.49 | មធ្យម |
| 21 | រៀបចំបរិស្ថានសិក្សាក្រៅថ្នាក់ (ខ្ទម បង្គុយ សួនធរណីមាត្រ ...) | 151 | 3.53 | 1.33 | ល្អបង្គួរ |
| 22 | បំណែងចែកកម្មវិធី និងសៀវភៅសិក្សាតាមមុខវិជ្ជាច្បាស់លាស់ និងតាមម៉ោងកំណត់ | 151 | 4.33 | 0.86 | ល្អបង្គួរ |
| 23 | ប្រើស្តង់ដាកម្មវិធី និងសៀវភៅសិក្សាគោលក្នុងការ រៀបចំផែនការបង្រៀន | 149 | 4.32 | 0.76 | ល្អបង្គួរ |
| 24 | ប្រើប្រាស់វិធីបង្រៀនបែបសិស្សមជ្ឈមណ្ឌល | 151 | 4.28 | 0.71 | ល្អបង្គួរ |
| 25 | វាយតម្លៃការសិក្សារបស់សិស្សបានត្រឹមត្រូវ | 150 | 4.37 | 0.70 | ល្អបង្គួរ |
| 26 | សិស្សមានសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាគ្រប់ៗគ្នា | 151 | 4.54 | 0.61 | ល្អ |
| 27 | គ្រូមានសៀវភៅណែនាំ និងឯកសារយោងផ្សេងៗទៀត | 151 | 4.29 | 0.80 | ល្អបង្គួរ |
| 28 | មានការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោលបានហ្មត់ចត់ | 151 | 4.44 | 0.69 | ល្អបង្គួរ |
| 29 | មានឯកសារសិក្សាក្រៅពីសៀវភៅសិក្សាគោល (ចាប់ពី បីប្រភេទឡើងទៅ) | 151 | 3.55 | 1.04 | ល្អបង្គួរ |
| 30 | ការប្រឡងឆមាសត្រូវបានរៀបចំទៅតាមស្តង់ដាកម្មវិធីសិក្សា និងដាក់ពិន្ទុបានត្រឹមត្រូវ | 151 | 4.39 | 0.79 | ល្អបង្គួរ |
| 31 | តេស្តស្តង់ដា សម្រាប់ថ្នាក់ទី៣ និងទី៦ បានអនុវត្តរៀងរាល់ឆ្នាំ | 151 | 3.51 | 1.50 | ល្អបង្គួរ |
| 32 | តេស្តឡើងថ្នាក់ ត្រូវបានរៀបចំឡើងនៅចុង និងដើមឆ្នាំសិក្សា | 150 | 3.98 | 1.15 | ល្អបង្គួរ |

តារាង២ បង្ហាញពីសូចនាករដែលមានទិន្នន័យលេចធ្លោជាងគេ សិស្សមានសៀវភៅសិក្សាគោល (សៀវភៅពុម្ព) គ្រប់មុខវិជ្ជាទាំងអស់ ដែលមានពិន្ទុមធ្យម M= 4.54 និងគម្លាតស្តង់ដា SD= 0.61។ ដោយឡែកទិន្នន័យដែលមានពិន្ទុមធ្យមទាបជាងគេបំផុត M= 1.70 និងគម្លាតស្តង់ដា SD= 1.06 និយាយអំពីការរៀបចំបន្ទប់មុខវិជ្ជា តាមមុខវិជ្ជានីមួយៗ ដូចជាបន្ទប់ គណិតវិទ្យា បន្ទប់វិទ្យាសាស្ត្រ បន្ទប់ពិសោធន៍ផ្សេងៗជាដើម ដែលសាលារៀនមិនអាចបំពេញបានតាមក្របខ័ណ្ឌកម្មវិធី។ យើងកត់សម្គាល់ឃើញថា សូចនាករគោលអំពីធនធានសម្រាប់បង្រៀន និងរៀន ដែលបានបរិយាយចាប់ពីលេខ ១៦ រហូតដល់លេខ ២១ សុទ្ធតែទទួលបានមធ្យមពិន្ទុកម្រិតមធ្យម M< 3.75 និងទាបបំផុតក្នុងចំណោមសូចនាករដទៃទៀត។ ក្នុងន័យនេះ យើងអាចសន្និដ្ឋានបានថា ការប្រើប្រាស់ធនធានក្នុងការបង្រៀន និងរៀន មិនបានអនុវត្តឱ្យមានប្រសិទ្ធភាពនោះទេ។

យោងតាមប្រសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ធ្លាប់បានលើកឡើងថា «ការសិក្សាប្រកបដោយប្រសិទ្ធភាព អាស្រ័យលើគុណ

ភាពគ្រូ និងមានរចនាសម្ព័ន្ធអគារសិក្សាគ្រប់គ្រាន់ ដូចជាបន្ទប់រៀន បណ្ណាល័យ បណ្ណាល័យអេឡិចត្រូនិក បន្ទប់ពិសោធន៍ បន្ទប់មុខវិជ្ជាជាដើម ដើម្បីឱ្យសិស្សមានជម្រើសកាន់តែសម្បូរបែបក្នុងការស្វែងរកចំណេះដឹង»។ ផ្អែកលើលក្ខខណ្ឌកម្មវិធីសាលាកុមារមេត្រីរបស់អង្គការយូនីសេហ្វ បានលើកឡើងអំពីសាលារៀនត្រូវរៀបចំរចនាសម្ព័ន្ធអគារសិក្សាបានល្អ សមស្របតាមអាយុ និងកម្រិតថ្នាក់របស់សិស្ស ដើម្បីជានាការសិក្សាប្រកបដោយផាសុខភាព ជាទីមេត្រីរបស់កុមារ (UNICEF, 2011)។ ជាមួយគ្នានេះដែរ ក្របខ័ណ្ឌកម្មវិធីកុមារមេត្រី នៅកម្ពុជា ក៏បានបង្ហាញពីធនធានសម្រាប់កាបង្រៀន និងរៀន ក្នុងគោលបំណងដើម្បីឱ្យការរៀនសូត្រគួរឱ្យចាប់អារម្មណ៍ និងមានប្រសិទ្ធភាពសម្រាប់សិស្ស គ្រូត្រូវមានធនធានគ្រប់គ្រាន់ និងសម្ភារផ្សេងៗ និងទីកន្លែងសម្រាប់ឱ្យសិស្សរៀនសូត្រ (ក្រសួងអប់រំ ២០១៩)។

យ៉ាងណាមិញ បើយើងក្រឡេកមកមើលលទ្ធផលដែលយើងទទួលបាន សបញ្ជាក់ថា សាលារៀនពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការកសាងរចនាសម្ពន្ធសាលារៀនឱ្យបានសមស្របឡើយ ជាពិសេសពាក់ព័ន្ធការរៀបចំបន្ទប់ពិសោធន៍ បន្ទប់មុខវិជ្ជា សម្ភារសម្រាប់ដំណើរការពិសោធន៍ ដែលជាលក្ខខណ្ឌខ្ពស់មួយពិបាកក្នុងការសម្រេច។ ការរៀបចំបន្ទប់ពិសោធន៍ និងការដឹកនាំសិស្សធ្វើពិសោធន៍ មិនត្រឹមតែផ្តោតលើធនធានថវិកាតែមួយមុខនោះទេ បូករួមជាមួយសមត្ថភាពរបស់គ្រូបង្រៀនជាចាំបាច់ក្នុងការដឹកនាំ។ ការផលិតសម្ភារបច្ចេកទេសទុកសម្រាប់បង្រៀន និងគាំទ្រដល់ការរៀនរបស់សិស្ស ក៏ជាបញ្ហាប្រឈមមួយដែរ ដែលសាលារៀនមិនអាចអនុវត្តបាន។

ផ្អែកលើទិន្នន័យក្នុងតារាងខាងលើ សូចនាករនិយាយពីរោងជាងផលិតសម្ភារបង្រៀន និងរៀនមានពិន្ទុមធ្យម M ត្រឹមតែ 1.84 ប៉ុណ្ណោះ ហើយមានគម្លាតស្តង់ដាទាប SD= 0.98 នេះមានន័យថាស្ទើតែគ្រប់សាលារៀនទាំងអស់ដែលបានជ្រើសរើស គឺមិនមានការដំណើរការរោងជាងនោះទេ និងមិនមានការផលិតសម្ភារសម្រាប់បង្រៀន និងរៀននោះដែរ។ យោងតាមរបាយការណ៍ពីការសម្ភាសន៍នាយកសាលាមួយរូប បានលើកឡើងថា ការរៀបចំបន្ទប់តាមមុខវិជ្ជា សាលាមិនអាចអនុវត្តបានដោយសារការខ្វះបន្ទប់រៀន មិនគ្រប់គ្រាន់តាមនិយាមសិស្ស/ថ្នាក់ មួយវិញទៀតខ្វះធនធានសម្ភារបច្ចេកទេសសម្រាប់កិច្ចដំណើរការ។ ការ

ផលិតសម្ភារ ក៏ដូចគ្នា មិនបានរៀបចំជាបន្ទប់រោងជាងឡើយ ដោយហេតុផលទីមួយ មិនមានបន្ទប់ដាច់ដោយឡែកសម្រាប់ការដាក់ដំណើរការរោងជាង និងទីពីរមិនមានបុគ្គលិកសម្រាប់កាន់ផ្នែករោងជាង។

ទន្ទឹមនឹងនេះ យើងក៏ឃើញទិន្នន័យដែលបានពិន្ទុមធ្យមកម្រិតទាបក្រោម M< 3 មានដូចជា ការបង្កើតសួនជីវៈចម្រុះ សម្រាប់ប្រើប្រាស់ក្នុងការបង្រៀន ឃើញថាសាលារៀនមួយចំនួនធំ ក៏មិនបានអនុវត្ត។ យោងតាមការអង្កេតសាលារៀនផ្ទាល់ពីអ្នកសិក្សាស្រាវជ្រាវ មើលឃើញថា សាលារៀនមួយភាគធំ មិនមានបរិស្ថានបៃតងសម្រាប់ជាទីមេត្រីរបស់កុមារទេ ជាពិសេសការរៀបចំសួន ជីវៈចម្រុះមិនមានដំណាំ ក៏ដូចជារុក្ខជាតិសម្បូរបែបឡើយ មានត្រឹមតែផ្កា និងបន្លែមួយមុខ ឬពីរមុខប៉ុណ្ណោះ។ អ្នកស្រាវជ្រាវមើលឃើញថា មិនមានសួនជីវៈចម្រុះកើតចេញពីការគ្រប់គ្រងផ្ទាល់របស់នាយកសាលាតែម្តង ព្រោះសាលារៀនមានធនធានសម្រាប់បង្កើតសួនជីវៈចម្រុះនេះ ទីកន្លែង និងស្ថានភាពដី ក៏អំណោយផល តែការអនុវត្ត និងការថែទាំគ្មានប្រសិទ្ធភាព។

តារាង៣ សម្ភារគាំទ្រកិច្ចដំណើរការសិក្សារៀនសូត្រ

| ល.រ | បរិយាយ | N | Mean | Std. Deviation | កម្រិតវាស់វែង |
|---|---|---|---|---|---|
| 33 | តុ និងកៅអីសិក្សាគ្រប់គ្រាន់ សម្រាប់សិស្សទាំងអស់ | 151 | 4.60 | 0.62 | ល្អ |
| 34 | កម្ពស់តុ កៅអីសិស្ស សមស្របទៅនឹងអាយុរបស់សិស្ស និងងាយចល័ត | 151 | 4.49 | 0.71 | ល្អបង្គួរ |
| 35 | កម្ពស់ក្តារខៀនសមស្របទៅនឹងកម្រិតថ្នាក់ និងនៅល្អសម្រាប់ការប្រើប្រាស់ | 151 | 4.40 | 0.78 | ល្អបង្គួរ |
| 36 | សម្ភារៈដំណើរការពិសោធន៍សមស្រប | 151 | 2.66 | 1.14 | មធ្យម |

យោងតាមតារាង៣ បានបង្ហាញអំពីការប្រើប្រាស់សម្ភារ សង្ហារឹមដែលគាំទ្រដល់ដំណើរការរៀនសូត្ររបស់សិស្ស ដែលបានមកពីការស្ទង់មតិពីអ្នកចូលរួមចំនួន ១៥១នាក់បានគូសបញ្ជាក់ថា សូចនាករដែលរៀបរាប់ពីចំនួនតុ និងកៅអីសិក្សាមានគ្រប់គ្រាន់សម្រាប់សិស្សទាំងអស់ដើម្បីអង្គុយសិក្សារៀនសូត្រ ស្ថានភាពតុ កៅអី និងក្តារខៀនសម្រាប់គាំទ្រកិច្ចដំណើរការសិក្សា សុទ្ធតែមានពិន្ទុមធ្យមខ្ពស់ (M> 4) និងគម្លាតស្តង់ដា SD < 1 ដែលបញ្ជាក់ថា សាលារៀនមានសង្ហារឹមគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការសិក្សារបស់សិស្ស។ ផ្ទុយមកវិញឃើញថា សាលារៀនភាគច្រើនមានសង្ហារឹម និងសម្ភាររូបវ័ន្តគ្រប់គ្រាន់ ប៉ុន្តែនៅខ្វះសម្ភារ

បច្ចេកទេសសម្រាប់ដំណើរការបង្រៀនសិស្ស ដូចជាឧបករណ៍សម្រាប់ធ្វើតេស្ត ធ្វើពិសោធន៍ និងសម្រាប់អនុវត្តក្នុងម៉ោងវិទ្យាសាស្ត្រជាដើម។ នៅចំណុចបរិយាយពីសម្ភារពិសោធន៍ មានមធ្យមពិន្ទុត្រឹមតែ 2.66 ប៉ុណ្ណោះ បានសេចក្តីថា សាលាបានអនុវត្តលក្ខខណ្ឌរបស់កម្មវិធីត្រង់ចំណុចនេះ បានតិចតួចបំផុត។

តារាង៤ ផ្តោតលើការផ្តល់សេវា និងការអភិវឌ្ឍសមត្ថភាព

| ល.រ | បរិយាយ | N | Mean | Std. Deviation | កម្រិតវាស់វែង |
|---|---|---|---|---|---|
| 37 | បំណិនចាំបាច់ត្រូវបានបញ្ចូលក្នុងការបង្រៀនតាមមុខវិជ្ជានីមួយៗ (បំណិនទន់) | 151 | 3.47 | 0.88 | មធ្យម |
| 38 | ការបង្កើតកម្មវិធីបំណិនជីវិតសម្រាប់សាលាតាមបែបពិគ្រោះយោបល់ | 151 | 3.23 | 1.05 | មធ្យម |
| 39 | ការបង្រៀនអាជីពងាយដោយប្រើអាជីវករក្នុងសហគមន៍ | 151 | 2.91 | 1.07 | មធ្យម |
| 40 | ការបង្រៀនបំណិនជីវិតមានលក្ខណៈជាការស្រាវជ្រាវងាយៗ និងមានការចូលរួមពីសមាគមន៍ដើម្បីដោះស្រាយបញ្ហានៅក្នុងមូលដ្ឋាន | 151 | 2.95 | 1.12 | មធ្យម |
| 41 | យន្តការត្រួតពិនិត្យសុខភាពសិស្ស (កុមារត្រូវការជំនួយពិសេស) | 149 | 3.46 | 1.14 | មធ្យម |
| 42 | ការអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នា ដោយយកចិត្តទុកដាក់ដល់កុមារពិការ | 151 | 3.34 | 1.23 | មធ្យម |
| 43 | សកម្មភាពជួយសិស្សរៀនយឺត | 151 | 4.25 | 1.00 | ល្អបង្គួរ |
| 44 | សេវាពិគ្រោះយោបល់ដល់សិស្សមានវិបត្តិ | 151 | 3.33 | 1.04 | មធ្យម |
| 45 | សេវាតម្រង់ទិសវិជ្ជាជីវៈដល់សិស្សមិនអាចបន្តការសិក្សា | 151 | 3.27 | 1.19 | មធ្យម |
| 46 | កំណត់ច្បាស់លាស់បញ្ហាប្រឈមរបស់សិស្ស | 151 | 3.88 | 1.06 | ល្អបង្គួរ |
| 47 | ផែនការសកម្មភាព សម្រាប់ដោះស្រាយការប្រឈមរបស់សិស្ស | 151 | 3.60 | 0.95 | ល្អបង្គួរ |
| 48 | គ្រូម្នាក់ៗមានផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន ឬបាននឹងកំពុងបន្តការសិក្សា | 151 | 4.05 | 0.96 | ល្អបង្គួរ |
| 49 | គ្រូធ្វើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍស្នាដៃថ្មីៗ | 151 | 3.96 | 1.02 | ល្អបង្គួរ |
| សរុបរួមសមាសភាគទី២ | | 151 | 3.63 | 1.00 | ល្អបង្គួរ |

បរិយាយពីលេខ ៣៧ ដល់លេខ ៤០ នៅក្នុងតារាងខាងលើនេះ បង្ហាញពីកម្មវិធីបំណិនជីវិត ដែលជាសូចនាករគោល។ យើងឃើញថាចំណុចបរិយាយនីមួយៗ និយាយពីការអញ្ជើញសហគមន៍មកផ្តល់បទឧទ្ទេសពីជំនាញផ្សេងៗ ការបង្រៀនអាជីពងាយពីអាជីវករក្នុងសហគន៍ ការបង្រៀនបំណិនជីវិតមានលក្ខណៈជាការស្រាវជ្រាវងាយៗ និងមានការចូលរួមពីសមាគមន៍ដើម្បីដោះស្រាយបញ្ហានៅក្នុងមូលដ្ឋាន ទទួលបានលទ្ធផលកម្រិតមធ្យម ដែលមានមធ្យមពិន្ទុ ចន្លោះពី 2.91 ទៅ 3.47។ បានសេចក្តីថាសាលារៀនអនុវត្តបានតិចតួច និងមធ្យម ដោយសារតែសហគមន៍ និងសាលារៀន មិនសូវមានទំនាក់ទំនងជាមួយគ្នា មិនបានផ្លាស់ប្តូរចំណេះដឹង និងចែករំលែកបទពិសោទន៍គ្នាទៅវិញទៅមក ទាក់ទងនឹងបំណិននៅមូលដ្ឋានដែលចាំបាច់ត្រូវ

បង្រៀនដល់សិស្សនោះទេ។ ចំណុចនេះយើងឃើញថា បានដើរផ្ទុយពីកម្មវិធីសាលាកុមារមេត្រី និងក្របខ័ណ្ឌកម្មវិធីសិក្សាជាតិ រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ផងដែរថា ការបង្រៀនត្រូវស្របតាមបរិបទ និងនានាភាពនៃសាលារៀន។

ជាការពិតការបង្រៀនអាជីពងាយពីសហគមន៍ និងបំណិនជាមូលដ្ឋានដែលចាំបាច់មួយចំនួន ពិតជាមានសារៈសំខាន់សម្រាប់សិស្ស ព្រោះវាជាចំណែកមួយនៃការអប់រំ បែបក្រៅប្រព័ន្ធផង ក្នុងប្រព័ន្ធផង ដើម្បីធានាថាសិស្សមិនត្រឹមតែចេះចំណេះដឹងនៅសាលាមួយមុខនោះទេ តែត្រូវចេះនូវអ្វីដែលសហគមន៍ និងមូលដ្ឋាន គេត្រូវការផងដែរ។ បំណិនជីវិតសំដៅដល់ បំណិនខាងបញ្ញា បំណិនបុគ្គល បំណិនអន្តរបុគ្គល និងបំណិនវិជ្ជាជីវៈដែលអនុញ្ញាតឱ្យមានការសម្រេចចិត្ត មានទំនាក់ទំនង ប្រកបដោយប្រសិទ្ធភាព ព្រមទាំងបំណិនខាងការចេះរស់នៅក្នុងសង្គមប្រកបដោយសាមគ្គីភាព (រាជរដ្ឋាភិបាល ២០១៩)។

ការផ្តល់ឱ្យសិស្សនូវចំណេះដឹងសម្បូរបែប តាមរយៈការស្រាវជ្រាវថ្មីៗ បទពិសោធន៍ថ្មី និងវិធីសាស្ត្រថ្មីក្នុងការបង្រៀន អាស្រ័យលើគ្រូបង្រៀនជាអ្នកសិក្សាស្រាវជ្រាវយកមកបង្ហាញសិស្សានុសិស្ស។ ចំណុចនេះយើងឃើញថា គ្រូបង្រៀនមានមិនច្រើនប៉ុន្មានទេ ដែលបានបន្តការសិក្សាពង្រឹងចំណេះដឹង និងបង្កើនគុណវុឌ្ឍិគ្រូ ជាពិសេសពាក់ព័ន្ធនឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍ស្នាដៃថ្មីៗ។ ចំណុចនេះ តាមរយៈការលើកឡើងរបស់នាយកសាលា បានលើកឡើងប្រហាក់ប្រហែលគ្នា ថាគ្រូមួយចំនួនធំដែលជាគ្រូបង្រៀនយូរឆ្នាំ មានវ័យចាស់ គ្រូខ្លះជិតនឹងចូលនិវត្តន៍ ពួកគាត់មិនដែលបានបន្តការសិក្សា ឬអភិវឌ្ឍន៍កម្រិតវប្បធម៌ឡើយដោយសារកត្តាជីវភាពគ្រួសារ ចម្ងាយផ្លូវទៅរៀន មធ្យោបាយ កត្តាវ័យចាស់ជិតចូលនិវត្តន៍ និងកត្តាផ្សេងៗទៀត ដែលពួកគាត់មិនបានស្រាវជ្រាវ និងរៀនបន្តបាន។ ប៉ុន្តែទន្ទឹមនឹងនេះ ក៏មានគ្រូដែលទើបចេញបង្រៀនថ្មីៗ គាត់បានបន្តការសិក្សារៀនសូត្របន្ថែម (ថ្នាក់សៅរ៍-អាទិត្យ) និងបានចែករំលែកវិធីបង្រៀនថ្មីៗ ដល់គ្រូបង្រៀនជំនាន់មុន តាមរយៈការប្រជុំបច្ចេកទេស និងថ្នាក់និទស្សន៍ជាដើម។

ពាក់ព័ន្ធនឹងយន្តការត្រួតពិនិត្យសុខភាពសិស្ស ការធានាការអប់រំបរិយាបន្ន សំដៅដល់ការរួមបញ្ចូលគ្នានៃការផ្តល់សេវាអប់រំ ការប្រើប្រាស់សេវានានានៅតាមគ្រឹះស្ថានសិក្សា សម្រាប់មនុស្សគ្រប់រូបដោយមិនគិត

ពីពិការភាព ឋានៈ យេនឌ័រ ពណ៌សម្បុរ សាសនា ជាតិសាសន៍ ស្ថានភាព និងជីវភាពគ្រួសារ និងប្រឹក្សាយោបល់ជួយសិស្សដែលមានបញ្ហា និងវិបត្តិផ្សេងៗ ទទួលបានមធ្យមពិន្ទុកម្រិតមធ្យម (M< 4) បញ្ជាក់ថាសាលារៀននីមួយៗ បានអនុវត្តក្នុងស្ថានភាពមធ្យមនៅឡើយ ដោយមិនទាន់បានយកចិត្តទុកដាក់ខ្ពស់ក្នុងការរឹតបន្តឹង និងអនុវត្តឱ្យមានប្រសិទ្ធភាពនោះទេ។ ការផ្តល់សេវាពិគ្រោះដល់សិស្សមានវិបត្តិ បានជួយដល់សិស្សក្នុងការស្វែងរកដំណោះស្រាយបានសមស្រប និងកាត់បន្ថយការបោះបង់ការសិក្សាផងដែរ (ក្រសួងអប់រំ ២០០៨)។ លើសពីនេះទៀតការតម្រង់ទិសវិជ្ជាជីវៈពិតជាមានសារៈសំខាន់សម្រាប់ពួកគាត់ ដើម្បីជួយវែកផ្លូវឱ្យពួកគាត់ចាប់យកឱកាសការងារលើជំនាញណាមួយដែលគាត់ពេញចិត្ត និងទេព្យកោសល្យរបស់ពួកគាត់ទៅថ្ងៃមុខ។

ទោះបីជាយ៉ាងណា សូចនាករដែលបានបង្ហាញពីកម្រិតស្ថានភាពអនុវត្តបានល្អ ដែលមានពិន្ទុមធ្យមខ្ពស់ (M> 4) ឃើញថាសាលារៀនអនុវត្តបានច្រើនផងដែរ ពាក់ព័ន្ធនឹងបរិក្ខាថ្នាក់រៀន មានចំនួនតុកៅអី ស្របតាមចំនួនសិស្ស ក្តារខៀនមានស្ថានភាពល្អ កម្ពស់តុកៅអី ក្តារខៀនស្របតាមអាយុសិស្ស ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោលមានប្រសិទ្ធភាពខ្ពស់។ សកម្មភាពជួយសិស្សរៀនយឺតសាលារៀនភាគច្រើនបានអនុវត្ត តាមរយៈកម្មវិធីបំប៉នថ្ងៃព្រហស្បតិ៍ រៀងរាល់ខែ ក្នុងមួយខែចំនួន ៣ថ្ងៃ ផ្តោតលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា។

ការប្រឡងឆមាស និងការដាក់ពិន្ទុបានត្រឹមត្រូវ បានអនុវត្តភាគច្រើន ដែលចំណុចនេះសាលារៀនភាគច្រើនគោរពតាមការណែនាំ និងមានការកំណត់ថ្ងៃប្រឡងត្រឹមត្រូវតាមការណែនាំរបស់មន្ទីរអប់រំខេត្ត។ ដោយឡែកការធ្វើតេស្តឡើងថ្នាក់នៅចុងឆ្នាំ និងដើមឆ្នាំសិក្សា មានការធ្លាក់ចុះ ដោយបានអនុវត្តតាមសាលារៀនមួយចំនួនប៉ុណ្ណោះ។ ការធ្វើតេស្តឡើងថ្នាក់នេះ តាមការលើកឡើងរបស់នាយកសាលា បានពន្យល់ថាការធ្វើតេស្តឡើងថ្នាក់ត្រូវការពេលវេលា និងការវាយតម្លៃច្បាស់លាស់ ហើយយើងក៏បានធ្វើការប្រឡងឆមាសដំណាច់ឆមាសនីមួយៗក្នុងឆ្នាំសិក្សាដូចគ្នា និងបានយកពិន្ទុឆមាសទាំងពីរលើក បូកចូលគ្នា ចែករកមធ្យមពិន្ទុដំណាច់ឆ្នាំ វាយចេញចំណាត់ថ្នាក់ជាប់ធ្លាក់ដែលនេះជាការវាស់ស្ទង់សមត្ថភាពសិស្សដូចទៅនឹងការធ្វើ

តេស្តផងដែរ។ ដោយឡែកការអនុវត្តតេស្តស្តង់ដាថ្នាក់ជាតិ សាលាអនុវត្តតាមការរៀបចំរបស់ក្រសួង ក្នុងការជ្រើសរើសសាលារៀនមួយណាជាសាលាសំណាក និងវាយតម្លៃជាលក្ខណៈជាតិ ដោយសាលាមិនទាន់បានយកក្រុបខ័ណ្ឌវាយតម្លៃថ្នាក់ជាតិ មកដាក់បញ្ចូលសម្រាប់វាយតម្លៃក្នុងសាលារៀនរបស់ខ្លួនឡើយ។

សរុបមកយើងអាចសន្និដ្ឋានបានថា ការអនុវត្តលើសមាសភាគទី២ និយាយពីប្រសិទ្ធភាពនៃការបង្រៀន និងរៀនរបស់គ្រូ និងសិស្ស មានស្ថានភាពកម្រិតល្អបង្គួរ ដោយសាលារៀនភាគច្រើនបានបំពេញទៅតាមក្របខ័ណ្ឌកម្មវិធី និងមួយចំនួនមិនទាន់បានអនុវត្តទាំងស្រុងនោះទេ ទោះបីជាចំណុចមួយចំនួនបានអនុវត្ត ប៉ុន្តែស្ថានភាពមិនបានទៀងទាត់ និងមិនសូវមានប្រសិទ្ធភាព។ យោងលើរបាយការណ៍អប់រំរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ អត្រាសិស្សជាប់មធ្យមភាគវង្វង់ ៨៧% ហើយអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា បាន ៨៨% ដែលស្ថិតនៅក្រោមចំណុចដៅ (មន្ទីរអយក.តឃ ២០២២)។ ថ្វីត្បិតអត្រាសិស្សជាប់មធ្យមភាគមានកម្រិតល្អ តែប្រសិទ្ធភាពនៃការរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ នៅមានកម្រិតដែលទាំងសាលារៀនគួរយកចិត្តទុកដាក់អនុវត្តបន្ថែម ហើយការិយាល័យអប់រំស្រុក និងមន្ទីរអប់រំ គួរពង្រឹងការពិនិត្យតាមដានឱ្យបានទៀងទាត់។

### ៤.១.៤ កម្រិតអនុវត្តលើសមាសភាគទី៣

នៅក្នុងតារាងតារាង៥ និងតារាង៦ ខាងក្រោមនេះ បង្ហាញពីស្ថានភាពនៃការអនុវត្តសមាសភាគទី៣ របស់កម្មវិធី CFS ដែលផ្តោតលើសូចនាករគោលចំនួន ៩ មានបរិស្ថានសាលារៀនស្អាត បង្គន់អនាម័យ ទឹកស្អាតសម្រាប់ប្រើប្រាស់ សម្ភារបរិក្ខារសម្រាប់ការលាងដៃ អនាម័យម្ហូបអាហារនៅសាលារៀន នីតិវិធីការពារសុវត្ថិភាពកុមារ ការទប់ស្កាត់អំពើហិង្សាលើកុមារ កម្មវិធីអប់រំកាយ និងកីឡា និងការអនុវត្តកម្មវិធីអាហារូបត្ថម្ភដល់កុមារ។

**សមាសភាគទី៣៖ សុខភាព សុវត្ថិភាព និងការការពារកុមារ**

តារាង៥ សុខភាពសិក្សា

| ល.រ | បរិយាយ | N | Mean | Std. Deviation | កម្រិតវាស់វែង |
|---|---|---|---|---|---|
| 50 | បរិស្ថានសាលារៀនមានសណ្តាប់ធ្នាប់ និងគ្មានសំរាម | 151 | 3.99 | 0.72 | ល្អបង្គួរ |

| | | | | | |
|---|---|---|---|---|---|
| 51 | កាកសំណល់រឹងត្រូវបានប្រមូលចោលដោយសុវត្ថិភាព | 151 | 4.04 | 0.90 | ល្អបង្គួរ |
| 52 | មានអាងស្តុកទឹកកខ្វក់ និងចរន្តលូបង្ហូរទឹក | 151 | 2.86 | 1.49 | មធ្យម |
| 53 | ទីធ្លាកម្សាន្តរាបស្មើ និងមានសុវត្ថិភាព | 151 | 4.23 | 0.89 | ល្អបង្គួរ |
| 54 | បង្គន់អនាម័យអាចឱ្យសិស្សប្រើប្រាស់បានជាប្រចាំ | 151 | 4.19 | 0.93 | ល្អបង្គួរ |
| 55 | មានសាប៊ូ និងទឹកស្អាតជានិច្ច | 151 | 4.35 | 0.80 | ល្អបង្គួរ |
| 56 | មានធុងសំរាមក្នុងបង្គន់ | 151 | 3.53 | 1.48 | ល្អបង្គួរ |
| 57 | មានអាងស្តុកទឹក (ស៊ីទែនទឹក) និងងាយស្រួលប្រើប្រាស់ | 151 | 4.53 | 0.75 | ល្អ |
| 58 | មានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់ | 151 | 4.54 | 0.73 | ល្អ |
| 59 | ទឹកស្អាតសម្រាប់ផឹក ដែលផ្តល់ដោយសាលារៀន | 151 | 4.00 | 1.27 | ល្អបង្គួរ |
| 60 | ការពិនិត្យសុវត្ថិភាពទឹកសម្រាប់ផឹកជាប្រចាំ | 151 | 4.00 | 1.22 | ល្អបង្គួរ |
| 61 | ការគ្រប់គ្រង និងប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធិភាព | 151 | 4.29 | 0.89 | ល្អបង្គួរ |
| 62 | កន្លែងលាងសម្អាតដៃគ្រប់គ្រាន់សម្រាប់សិស្ស | 151 | 4.19 | 1.10 | ល្អបង្គួរ |
| 63 | សាប៊ូ និងទឹកគ្រប់គ្រាន់សម្រាប់ការលាងដៃមុនញ៉ាំអាហារ | 151 | 4.29 | 0.93 | ល្អបង្គួរ |
| 64 | បណ្តុះសិស្សឱ្យទម្លាប់ក្នុងការលាងសម្អាតដៃ | 151 | 4.47 | 0.79 | ល្អបង្គួរ |

ផ្អែកលើទិន្នន័យដែលបានវាស់វែងខាងលើ យើងសង្កេតឃើញថា សូចនាករដែលមានពិន្ទុមធ្យមខ្ពស់ជាងគេ M= 4.54 ដែលមានគម្លាតស្តង់ដា (SD) ត្រឹមតែ 0.73 គឺនិយាយពី សាលារៀនមានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់។ សូចនាករដែលនិយាយពីអាងស្តុកទឹក (ស៊ីទែនទឹក) និងងាយស្រួលប្រើប្រាស់សម្រាប់សិស្ស ក៏ទទួលបានមធ្យមពិន្ទុខ្ពស់លេខរៀងទី២ ដែលមាន M= 4.53 និងគម្លាតស្តង់ដា SD= 0.75។ យើងក៏សង្កេតឃើញមានសូចនាករពីរ ដែលទទួលបានធម្យមពិន្ទុស្មើគ្នា ដែលមានតម្លៃ M= 4.00 ដូចគ្នា មួយនិយាយពីទឹកស្អាតសម្រាប់ផឹក ដែលផ្តល់ដោយសាលារៀន និងមួយទៀតនិយាយពីការពិនិត្យសុវត្ថិភាពទឹកសម្រាប់ផឹកជាប្រចាំ។ ផ្ទុយមកវិញយើងឃើញមានសូចនាករដែលទទួលបានពិន្ទុមធ្យមទាបជាងគេ គឺផ្តោតលើសាលារៀនមានអាងស្តុកទឹកកខ្វក់ និងចរន្តលូបង្ហូរទឹក ដែលទទួលបានត្រឹមតែ 2.86 និងគម្លាត 1.49 មានន័យថាសាលារៀនភាគច្រើនមិនទាន់មានប្រព័ន្ធលូសម្រាប់រំដោះទឹកចេញឱ្យបានត្រឹមត្រូវនោះទេ។

នៅក្នុងផ្នែកនេះយើងឃើញថាការរៀបចំប្រព័ន្ធទឹកសម្រាប់ប្រើប្រាស់នៅសាលារៀន មានលក្ខណៈល្អប្រសើរ ដោយសាលារៀនភាគច្រើនលើសលប់មានអណ្តូងទឹកសម្រាប់ប្រើប្រាស់ និងសាលាមួយចំនួនបានតភ្ជាប់បណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់បន្ថែមលើប្រភពទឹកផ្សេងៗ។ បន្ថែមពីនេះ សាលារៀនមួយភាគធំក៏មានអាងទឹក និងស៊ីទែនទឹកសម្រាប់ស្តុកទឹកប្រើប្រាស់ ដូចជាលាងសម្អាតដៃ ស្រោចស្រប់ដំណាំ រុក្ខជាតិ

និងសួនច្បារជាដើម ដែលភាគច្រើនទទួលបានមធ្យមពិន្ទុកម្រិតខ្ពស់ (M> 4)។ ក្នុងនោះយោងតាមបទសម្ភាសន៍ជាមួយនាយកសាលាមួយរូប បានលើកឡើងអំពីសាលារៀនរបស់គាត់ មានទឹកសម្រាប់ឱ្យសិស្សអាចញ៉ាំបាន ដោយបានសហការជាមួយក្រុមហ៊ុនទឹកស្អាត ដើម្បីឱ្យក្រុមហ៊ុនផ្គត់ផ្គង់ទឹកជាប្រចាំដល់សាលារៀនរបស់គាត់។ សូចនាករដែលនិយាយអំពីការគ្រប់គ្រង និងការប្រើប្រាស់ទឹកនៅសាលារៀន យើងឃើញថាសាលារៀនភាគច្រើនបានអនុវត្តបានល្អ តាមក្របខ័ណ្ឌដែលបានណែនាំ។

ងាកមកមើលការរៀបចំបរិស្ថានសាលារៀន ទទួលបានលទ្ធផលមធ្យមកម្រិតខ្ពស់ ដែលមានពិន្ទុមធ្យម M= 3.99, SD= 0.72 ដែលនេះបញ្ជាក់ថាសាលារៀនច្រើនជាង ៥០% បានយកចិត្តទុកដាក់លើការងារបរិស្ថាន ព្រោះចំណុចដែលសំខាន់ និងចាំបាច់ដែលសាលារៀនត្រូវធ្វើ។ បរិស្ថានសាលារៀនផ្តោតលើបរិស្ថានក្នុងថ្នាក់ និងក្រៅថ្នាក់ ដែលត្រូវរៀបចំឱ្យបានស្អាត មានសណ្តាប់ធ្នាប់ មានសោភ័ណភាព និងជាប្រយោជន៍សម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស (ក្រសួងអប់រំ, ២០១៩)។

ការរៀបចំបរិស្ថានបានត្រឹមត្រូវតាមស្តង់ដាកម្មវិធីសាលាកុមារមេត្រី ត្រូវធានាថា មានសួនរាបស្មើ និងមានប្រព័ន្ធលូបង្ហូរទឹក ដើម្បីបញ្ចៀសការលិចលង់ មានសុវត្ថិភាព សម្រាប់សិស្ស មានរបងព័ទ្ធជុំវិញ មានការរៀបចំធុងញែកសម្រាម មានការទុកដាក់កាកសំណល់តាមផ្នែកដោយសុវត្ថិភាព និងមិនមានការំខានពីមជ្ឈដ្ឋានជុំវិញ។

តារាង៦ សុវត្ថិភាព និងការការពារកុមារ

| ល.រ | បរិយាយ | N | Mean | Std. Deviation | កម្រិតវាស់វែង |
|---|---|---|---|---|---|
| 65 | កន្លែងលក់ចំណីអាហារមានអនាម័យ ដែលមានទីធ្លា និងបរិស្ថានស្អាតល្អ | 151 | 4.13 | 0.77 | ល្អបង្គួរ |
| 66 | បម្រាមចំពោះចំណីអាហារប៉ះពាល់ដល់សុខភាព(គ្រឿងកំប៉ុង នំកញ្ចប់ដែលហាមឃាត់ ស្ករគ្រាប់ ...) | 151 | 4.28 | 0.92 | ល្អបង្គួរ |
| 67 | ការត្រួតពិនិត្យអនាម័យចំណីអាហារក្នុងសាលារៀន | 151 | 4.05 | 0.88 | ល្អបង្គួរ |
| 68 | ធុងញែកសំរាម មានជាប់ជានិច្ច | 151 | 3.47 | 1.30 | មធ្យម |
| 69 | មានការណែនាំជាលាយលក្ខណ៍អក្សរ អំពីការការពារកុមារ | 151 | 3.56 | 1.08 | ល្អបង្គួរ |
| 70 | មានរបាយការណ៍ និងការបញ្ជូននៅពេលកុមារមានគ្រោះថ្នាក់ | 151 | 3.45 | 1.32 | មធ្យម |
| 71 | ប្រើយន្តការក្រុមប្រឹក្សាកុមារ ដែលបានកំណត់យ៉ាងច្បាស់ពីតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់ពួកគេ | 151 | 3.87 | 1.07 | ល្អបង្គួរ |
| 72 | គ្រូចូលរួមក្នុងកម្មវិធីបង្ការអំពើហិង្សាលើកុមារ | 151 | 4.19 | 0.97 | ល្អបង្គួរ |
| 73 | មានការដាក់វិន័យតឹងរឹង ក្នុងករណីមានការបំពានលើកុមារ | 151 | 3.96 | 1.16 | ល្អបង្គួរ |
| 74 | កត់ត្រាពីឧប្បទ្ទវហេតុ និងធ្វើបណ្ដឹងចោទប្រកាន់ | 151 | 3.39 | 1.24 | មធ្យម |
| 75 | មានសកម្មភាពអប់រំកាយនិងកីឡាប្រចាំសប្ដាហ៍ | 151 | 4.07 | 1.06 | ល្អបង្គួរ |
| 76 | មានប្រភេទ និងសម្ភារកីឡាយ៉ាងតិច បីប្រភេទ | 151 | 3.21 | 1.22 | មធ្យម |
| 77 | គ្រូអប់រំកាយ និងកីឡាទទួលបានការបណ្ដុះបណ្ដាលត្រឹមត្រូវ | 151 | 3.22 | 1.32 | មធ្យម |
| 78 | គ្រូនិងមាតាបិតានិយាយពីសារប្រយោជន៍នៃអាហាររូបបត្ថម្ភសម្រាប់ការលូតលាស់របស់សិស្ស | 151 | 3.75 | 0.96 | ល្អបង្គួរ |
| 79 | មានកម្មវិធីដាំស្លដែលបង្ហាញពីសារប្រយោជន៍អាហាររូបបត្ថម្ភ | 151 | 2.52 | 1.23 | មធ្យម |
| 80 | ឱ្យសិស្សអនុវត្តអាហារូបត្ថម្ភនៅផ្ទះរបស់សិស្ស | 151 | 3.09 | 1.21 | មធ្យម |
| សរុបរួមសមាសភាគទី៣ | | 151 | 3.74 | 1.02 | ល្អបង្គួរ |

នៅក្នុងតារាង៦ ខាងលើផ្ដោតលើសុវត្ថិភាពចំណីអាហារ និងការការពារកុមារ។ ពាក់ព័ន្ធការអនុវត្តបម្រាមចំពោះចំណីអាហារប៉ះពាល់ដល់សុខភាព មានដូចជា នំហឹរ នំកញ្ចប់ផ្សេងៗ ស្ករគ្រាប់ ភេសជ្ជៈផ្អែម ដែលហាមឃាត់មិនឱ្យលក់ដូរតាមសាលារៀន មានស្ថានភាពល្អប្រសើរ ដោយអនុវត្តបានញឹកញាប់ ដែលមានពិន្ទុមធ្យមរហូតដល់ M= 4.28, SD= 0.92 មានន័យថាសាលារៀនបានអនុវត្តបម្រាមចំណីអាហារប៉ះពាល់សុខភាពមានប្រសិទ្ធភាព។

តាមការលើកឡើងរបស់មន្ត្រីការិយាល័យបឋមសិក្សា មួយរូបលើកឡើងថា មិនត្រឹមតែនៅក្នុងក្របខ័ណ្ឌកម្មវិធីកុមារមេត្រី ប៉ុណ្ណោះទេ យោងលិខិតណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា និងលិខិត

លេខ ៤២២/២៣ សជណ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តត្បូងឃ្មុំ ក៏បានណែនាំបន្ថែម និងជារើយៗស្តីពីការរឹតបន្តឹងការលក់ដូរនំចំណីតាមសាលារៀន ដោយមានខ្លឹមសារថា «...កន្លងមករដ្ឋបាលខេត្តបានសង្កេតឃើញថានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន មានការលក់ចំណីអាហារនាំចូលពីក្រៅស្រុក ដែលចំណីអាហារមួយចំនួនធំប៉ះពាល់ដល់សុខភាពរបស់សិស្ស ចំណែកចំណីអាហារបែបខ្មែរវិញ បែរជាពុំសូវមានការធ្វើ និងដាក់លក់ឡើយ។ ដើម្បីលើកកម្ពស់សុខភាព និងសុខុមាលភាពសិស្សានុសិស្ស រដ្ឋបាលខេត្តស្នើលោកប្រធានមន្ទីរ យកចិត្តទុកដាក់បន្ថែម ជម្រុញឱ្យមានការលក់នំខ្មែរនៅតាមសាលារៀន និងហាមឃាត់ចំពោះការលក់ចំណីអាហារដែលគ្មានប្រភព ហួសកាលបរិច្ឆេទ គេសជ្ជៈផ្អែម នំដែលមានជាតិខ្លាញ់ ហឹរ និងប្រៃខ្លាំងជាដើម...»។

តាមកិច្ចសម្ភាសន៍ជាមួយមន្ត្រីមួយរូបបានលើកឡើងជុំវិញបញ្ហានេះថា «ទោះបីមានការហាមឃាត់ប៉ុន្តែតាមការចុះពិនិត្យតាមដានកន្លងមកឃើញនៅមានការលក់ដូរនំចំណីដែលក្រសួងបានហាមឃាត់នៅឡើង ដោយមិនអាចលុបបំបាត់បានទាំងស្រុងនោះទេ នៅតែមានលក់ជាបន្តនៅតាមសាលាមួយចំនួន» (#Stuff01)។ ការជជែកគ្នារវាងគ្រូ និងមាតាបិតាសិស្សអំពីអាហារូបត្ថម្ភសម្រាប់ការលូតលាស់របស់សិស្ស មានការធ្លាក់ចុះតួលេខដោយសាលារៀន មិនសូវបានយកចិត្តទុកដាក់ខ្លាំង កត្តាបន្តិចបន្តួចដែលអាចជះឥទ្ធិពលដល់សិស្សនៅពេលអនាគត។ ការពិភាក្សាគ្នា រវាងគ្រូ និងមាតាបិតាសិស្ស ធ្វើឱ្យគ្រូអាចដឹងពីរបបអាហារដែលសិស្សហូបនៅផ្ទះរបៀបមេច និងផ្តល់ជាយោបល់សម្រាប់អាណាព្យាបាលយកទៅអនុវត្តបន្ថែម។ ក្នុងនោះក៏ឃើញមានសូចនាករមួយនិយាយពីការបង្កើតកម្មវិធីដាំស្ល ប៉ុន្តែសាលារៀនមួយភាគធំ មិនបានអនុវត្តនោះទេ មានមធ្យមពិន្ទុត្រឹមតែ 2.52 (កម្រិតទាប) ដោយហេតុផលផ្សេងៗគ្នា និងមានគម្លាតស្តង់ដា SD> 1 មានន័យថាសាលារៀនភាគតិចបានអនុវត្ត។

យោងតាមកិច្ចសម្ភាសន៍ជាមួយគណៈគ្រប់គ្រងសាលរៀនភាគច្រើនលើកឡើងស្រដៀងៗគ្នា អំពីកង្វះខាតសម្ភារសម្រាប់ចម្អិន និងគ្រូបង្រៀនខ្វះបច្ចេកទេសក្នុងការធ្វើ។ អាហារូបត្ថម្ភពិតជាមានសារសំខាន់

បំផុតសម្រាប់ក្មេងៗដែលកំពុងតែលូតលាស់ ទាំងរាងកាយ បញ្ញា និងស្មារតី ដែលទាំងគ្រូ និងអាណាព្យាបាល ត្រូវតែយកចិត្តទុកដាក់ឱ្យបានល្អប្រសើរជាងនេះ។

អ្នកស្រាវជ្រាវបានកត់សម្គាល់ឃើញថា សូចនាករដែលមានមធ្យមពិន្ទុក្រោម ៤ (M<4) ភាគច្រើននិយាយពីការការពារកុមារ ដោយអំពើកេងប្រវ័ញ្ច ហិង្សា ឬរំលោភបំពានលើកុមារ និងការប្រើប្រាស់យន្តការក្រុមប្រឹក្សាកុមារនៅតាមសាលារៀន។ ចំណុចទាំងអស់នេះសាលារៀនហាក់មិនសូវបានយកចិត្តទុកដាក់ក្នុងការអនុវត្តដោយសារនាពេលកន្លងមក មិនមានការពិនិត្យតាមដានឱ្យបានជាប់លាប់។

ផ្អែកតាមគោលនយោបាយជាតិស្ដីពីប្រព័ន្ធកិច្ចការពារកុមារកម្ពុជា (NCP) ២០១៩-២០២៩ របស់រាជរដ្ឋាភិបាលកម្ពុជា បានលើកឡើងថា កុមារត្រូវទទួលបានការការពារដែលមានលក្ខណៈជាប្រព័ន្ធ រួមមានការការពារសុខមាលភាពរបស់កុមារ ការការលើប្រព័ន្ធច្បាប់ ការការពារផ្នែកសុខភាព និងការការពារផ្នែកសេវាអប់រំ (រាជរដ្ឋាភិបាល ២០១៩)។ ទន្ទឹមនឹងនេះ បើយើងក្រឡេកមើលក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា ក៏បានគូសបញ្ជាក់ផងដែរថា កុមារជាទំពាំងស្នងឬស្សីប្រកបដោយសក្ដានុពល និងត្រូវទទួលបានការការពារដោយមានកំណត់ពីតួនាទី និងការទទួលខុសត្រូវ របស់ក្រសួងស្ថាប័នដើម្បីឆ្លើយតបនៅនឹងតម្រូវការជាក់ស្តែងរបស់កុមារ (ក្រសួងសង្គមកិច្ច ២០២១)។

ជាក់ស្តែង នៅត្រង់ចំណុចនេះយើងឃើញថា ក្រសួងអប់រំបន្ទាប់ពីដាក់ចេញនូវកម្មវិធីសាលាកុមារមេត្រីឱ្យអនុវត្តរួចមក កុមារគ្រប់រូបត្រូវបានយកចិត្តទុកដាក់ពីមន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់ ជាពិសេសនៅសាលារៀនផ្ទាល់។ គ្រូបង្រៀនមានតួនាទីសំខាន់បំផុត ក្នុងការតាមដាន និងអប់រំណែនាំដល់កុមារទាំងអស់ត្រូវតែជៀសវាងនូវអំពើហិង្សា ព្រោះវាអាចប្រឈមនឹងវិធានការច្បាប់។ គ្រូបង្រៀនគួរតែអនុវត្តតួនាទីក្រុមប្រឹក្សាកុមារឱ្យមានដំណើរការល្អ និងមានប្រសិទ្ធភាព ដើម្បីចូលរួមចំណែកទប់ស្កាត់ ក៏ដូចជាជួយតាមដានរាល់សកម្មភាពណាដែលចាត់ទុកជាអំពើហិង្សា ទាំងក្នុងសាលា និងក្រៅសាលារៀន។

ដើម្បីកាត់បន្ថយអំពើហិង្សា ឬការរំលោភបំពានលើកុមារ សាសារៀនត្រូវតែរៀបចំសកម្មភាពកីឡា និងអប់រំកាយ ឱ្យបានញឹកញាប់ និងទៀងទាត់ ព្រោះកីឡានាំមកនូវសុខភាព និងការសាមគ្គីភាព វៀរចាកអំពើ

អបាយមុខទាំងឡាយ ដែលសង្គមហាមឃាត់។ យ៉ាងណាមិញក្រឡេកមកមើលសូចនាករៀបរាប់ពីសកម្មភាពកីឡា ទទួលបានពិន្ទុមធ្យមកម្រិតមធ្យមនៅឡើយ ដោយសាលារៀនមួយចំនួនមិនសូវមានសកម្មភាពកីឡា និងអប់រំកាយនោះទេ។

សរុបមក តាមការសម្ភាសន៍នាយកគណៈគ្រប់គ្រងសាលាផង និងមន្ទីរអប់រំផង យើងឃើញថាសាលារៀនបានអនុវត្តតាមសូចនាករទាំងអស់ ប៉ុន្តែស្ថិតក្នុងស្ថានភាពមិនទៀងទាត់ឡើយ ដោយសូចនាករមួយចំនួន អនុវត្តបានតិចតួច និងមួយចំនួនបានខ្លះ ដោយកត្តាផ្សេងៗ។ អ្នកស្រាវជ្រាវរកឃើញអំពីកត្តាទាំងនោះមានដូចជាការមិនបានបង្កើតឱ្យមានគណៈកម្មការសម្រាប់អនុវត្តឱ្យមានប្រសិទ្ធភាព ខ្វះការពិនិត្យតាមដាន ខ្វះធនធានសម្រាប់អនុវត្ត (ធនធានមនុស្ស និងសម្ភារ) និងកត្តាធំបំផុត ការមិនយកចិត្តទុកដាក់អនុវត្តតាមផែនការឱ្យបានហ្មត់ចត់។ ទោះបីជាយ៉ាងណាទិន្នន័យដែលបានបង្ហាញយើងអាចសន្និដ្ឋានបានពីការអនុវត្តសមាសភាគទី៣ នេះថាស្ថិតក្នុងកម្រិតល្អបង្គួរដោយមានសូចនាករដែលមានមធ្យមពិន្ទុ M>3.50 មានចំនួនច្រើន។

### ៤.១.៥ កម្រិតអនុវត្តលើសមាសភាគទី៤

តារាងខាងក្រោមនេះបង្ហាញពីលទ្ធផល ដែលឆ្លើយតបទៅនឹងយេនឌ័រនៅសាលារៀន ដែលបានវាស់វែងលើសូចនាករគោលទាំងបី មាន ១) ការលើកទឹកចិត្តកុមារា និងកុមារីឱ្យទទួលបានឱកាសស្មើគ្នា ចូលរួមក្នុងសកម្មភាព និងកម្មវិធីនានា ២) ការផ្តល់ឱកាសឱ្យស្ត្រីចូលរួមក្នុងការដឹកនាំ និងគ្រប់គ្រង និង ៣) សមធម៌ក្នុងការអប់រំ សម្រាប់សិស្សស្រី និងសិស្សប្រុស។

**សមាសភាគទី៤៖ ការឆ្លើយតបទៅនឹងយេនឌ័រ**

តារាង៧ ការឆ្លើយតបនឹងយេនឌ័រ

| ល.រ | បរិយាយសូចនាករ | N | Mean | Std. Deviation | កម្រិតវាស់វែង |
|---|---|---|---|---|---|
| 81 | មានតំណាងកុមារីនៅក្នុងក្រុមប្រឹក្សាកុមារតាមសាខា និងអនុសាខានីមួយៗ | 151 | 3.95 | 1.15 | ល្អបង្គួរ |
| 82 | ប្រធានថ្នាក់ជាកុមារា ឬកុមារីមានចំនួនប្រហាក់ប្រហែលគ្នា | 151 | 4.23 | 0.95 | ល្អបង្គួរ |
| 83 | បានបង្កើតទីប្រឹក្សាកុមារី និងមានដំណើរការ | 151 | 3.88 | 1.13 | ល្អបង្គួរ |

| | | | | | |
|---|---|---|---|---|---|
| 84 | គ្រូបង្រៀនជាស្ត្រី មានតួនាទីក្នុងគណៈកម្មការ និងក្រុមប្រឹក្សានានា | 151 | 3.70 | 1.30 | ល្អបង្គួរ |
| 85 | ផ្តល់តួនាទីដឹកនាំ ក្នុងគណៈគ្រប់គ្រងសាលា | 151 | 3.94 | 1.09 | ល្អបង្គួរ |
| 86 | លើកទឹកចិត្តស្ត្រីដែលសកម្មការងារគ្រប់ផ្នែក | 151 | 4.00 | 1.11 | ល្អបង្គួរ |
| 87 | កម្មវិធីអាហារូបករណ៍បានផ្តល់អាទិភាពដល់សិស្សស្រី និងសិស្សប្រុសដែលជួបការលំបាក | 151 | 4.45 | 0.78 | ល្អបង្គួរ |
| 88 | មានរៀបចំវេទិការយេនឌ័រ និងការចូលរួមអភិវឌ្ឍនានាដោយមានការចូលរួមពីកុមារី | 151 | 3.47 | 1.18 | មធ្យម |
| 89 | ការគាំទ្រកុមារីក្នុងការសិក្សាពីសហគមន៍ | 151 | 3.63 | 1.11 | ល្អបង្គួរ |
| សរុបរួមសមាសភាគទី៤ | | 151 | 3.91 | 1.09 | ល្អបង្គួរ |

នៅក្នុងតារាងនេះ យើងសង្កេតឃើញថា សូចនាករនិយាយអំពី ការផ្តល់អាទិភាពដល់សិស្សស្រី និងសិស្សប្រុសដែលជួបការលំបាកឱ្យទទួលបានអាហារូបករណ៍ មានមធ្យមពិន្ទុកម្រិតខ្ពស់ M= 4.45 និងគម្លាតស្តង់ដា SD= 0.78 ដែលបញ្ជាក់ពីកម្រិតវាស់វែងមួយមានភាពល្អ និងសុក្រឹត្យ។ លទ្ធផលក៏បានបង្ហាញនូវសូចនាករមួយទៀតដែលមានកម្រិតមធ្យមពិន្ទុខ្ពស់លំដាប់ទី២ គឺការជ្រើសរើសប្រធានថ្នាក់ ជាកុមារា និងកុមារី មានចំនួនប្រហាក់ប្រហែលគ្នា មាន M= 4.23 និងគម្លាតស្តង់ដា SD= 0.95។ ពិន្ទុមធ្យមមានកម្រិតខ្ពស់មានន័យថា សាលារៀនពិតជាបានអនុវត្តសូចនាករដែលបានបរិយាយ ដោយអ្នកបំពេញកម្រងសំណួរ ជ្រើសយកកម្រិតចង្អុលបង្ហាញ ក្នុងស្ថានភាពអនុវត្តញឹកញាប់ និងទៀងទាត់។

ដោយឡែកយើងក៏សង្កេតឃើញផងដែរថា ការលើកទឹកចិត្តស្ត្រីដែលសកម្មការងារ និងការផ្តល់តួនាទីដឹកនាំ ក្នុងចង្កោមគណៈគ្រប់គ្រងសាលារៀន សុទ្ធតែទទួលបានមធ្យមពិន្ទុខ្ពស់ ក្នុងរង្វង់ 3.94 ទៅ 4.00 ដែលយើងសន្និដ្ឋានថាពិតជាអនុវត្តសូចនាករនេះ មានប្រសិទ្ធភាព។ ក៏ប៉ុន្តែ បើយើងមើលលើគម្លាតស្តង់ដា (SD) យើងឃើញថា មានកម្រិតខ្ពស់ដូចគ្នា ខុសគ្នាត្រង់ថាគម្លាតស្តង់ដាខ្ពស់ គឺលទ្ធផលមិនសូវល្អឡើយ ដោយសារអ្នកបំពេញកម្រងសំណួរ បានជ្រើសយកកម្រិតចង្អុលបង្ហាញច្រើនផ្សេងៗគ្នា ក្នុងចំណោមពី ១ ដល់ ៥។ ចំណុចនេះក៏គួសបញ្ជាក់ថា ការអនុវត្តសកម្មភាពនៃសូចនាករនេះ មានភាពមិនទាន់សុក្រឹត្យ។ មួយវិញទៀត ក្នុងចំណោមសូចនាករទាំង៩ ដែលរៀបរាប់ពីសកម្មភាពគាំទ្រដល់ការឆ្លើយតបទៅនឹងយេនឌ័រ

នៅសាលារៀន ភាគច្រើនការជ្រើសយកម្រិតចង្អុលបង្ហាញចាប់ពីកម្រិតអប្បបរមា ដល់អតិប្បរមា ដែលនាំឱ្យគម្លាតនៃការឆ្លើយកាន់តែធំ (SD > 1)។

យោងតាមបទសម្ភាសន៍ជាមួយគណៈគ្រប់គ្រងសាលារៀនផ្ទាល់ អ្នកស្រាវជ្រាវបានរកឃើញថា ការចូលរួមលើកកម្ពស់យេនឌ័រនៅតាមសាលារៀន ធ្វើឡើងក្នុងរូបភាពមួយប្រហាក់ប្រហែលគ្នា ដោយគណៈគ្រប់គ្រងសាលា និងលោកគ្រូអ្នកគ្រូ បានយកចិត្តទុកដាក់លើការផ្តល់ឱកាសស្មើគ្នារវាងកុមារា និងកុមារីក្នុងការសិក្សារៀនសូត្រ ចូលរួមសកម្មភាពនានានៅក្នុងសាលា និងនៅក្នុងសង្គម ដោយមានគ្រូជាអ្នកដឹកនាំ។ នៅសាលារៀនមានគ្រូបង្រៀនជាស្ត្រីមួយរូប ត្រូវបានចាត់តាំងជា ទីប្រឹក្សាកុមារី សម្រាប់ជួយអប់រំណែនាំដល់ក្មេងស្រីជុំទង់ពីរបៀបថែទាំសុខភាព និងអនាម័យខ្លួនប្រាណជាដើម។

នៅក្នុងថ្នាក់រៀនវិញ សិស្សប្រុស និងសិស្សស្រី ត្រូវបានយកចិត្តទុកដាក់ស្មើៗគ្នា ពីលោកគ្រូអ្នកគ្រូ ដោយមិនមានការរើសអើងភេទ ជីវភាព ឋានៈគ្រួសារ និងពណ៌សម្បុរឡើយ។ ចំពោះគ្រូបង្រៀនជាស្ត្រីវិញ នៅតាមសាលានីមួយៗ មានចំនួនច្រើនជាងបុរស ដែលធ្វើឱ្យអង្គភាពមួយមានការឆ្លើយតបទៅនឹងយេនឌ័ររួចជាស្រេចក្នុងការរៀបចំបុគ្គលិក។ ជាក់ស្តែងចំនួនគ្រូបង្រៀនជាស្ត្រីដែលយើងធ្វើសំណាកក្នុងចំណោម ១៥០នាក់ មានស្ត្រីចំនួន ៩៥នាក់ប្រមាណ ៦៣% ទៅហើយ។ ថ្វីត្បិតគ្រូបង្រៀនជាស្ត្រីច្រើនជាងបុរសពិតមែន ប៉ុន្តែចំនួនស្ត្រីដែលមានតួនាទីនៅក្នុងជួរគណៈគ្រប់គ្រងនៅមានចំនួនតិចជាងបុរសវិញ ហើយសាលារៀនមួយចំនួនមិនមានការបង្កើតទីប្រឹក្សាកុមារីនៅក្នុងគណៈកម្មការនានារបស់សាលារៀនឡើយ និងមួយចំនួនទៀតបង្កើតមានជារូបរាងគណៈកម្មការ ប៉ុន្តែមានត្រឹមតែរចនាសម្ព័ន្ធមិនមានកិច្ចដំណើរការនោះទេ។

បញ្ហាចោទទាំងនេះ អ្នកស្រាវជ្រាវរកឃើញថា វាជាការធ្វេសប្រហែសរបស់គណៈគ្រប់គ្រងសាលារៀន ដែលមិនបានរៀបចំ និងយកចិត្តទុកដាក់លើការអនុវត្តឱ្យមានប្រសិទ្ធភាព។ ក្នុងចំណោមសាលារៀនដែលបានជ្រើសរើស ក៏មានសាសារៀនចំនួន ២ ដែលមានគណៈគ្រប់គ្រងសាលាជាស្ត្រី (នាយិកា) ចំណុចនេះ យើងអាចវាយតម្លៃថា ការចូលរួមកិច្ចការដឹកនាំនិងគ្រប់គ្រងនៅតាមសាលារៀន គឺមិនទាន់ឆ្លើយតបបានល្អទៅនឹងសកម្មភាពយេនឌ័របានឡើយ។

យោងតាមបទសម្ភាសន៍ជាមួយប្រធានការិយាល័យមួយរូប បានកត់សម្គាល់ថា កត្តាដែលសាលារៀនមួយមិនអាចរៀបចំឱ្យបានឆ្លើយតបទៅនឹងពាក់ព័ន្ធសកម្មភាពគ្រប់គ្រងដឹកនាំ គឺមានកត្តាច្រើន។ ទីមួយ សមត្ថភាពបុគ្គល នៅមានកម្រិត (រាប់បញ្ចូលទាំងគុណវុឌ្ឍិ កម្រិតវិជ្ជាជីវៈ បំណិនផ្សេងៗ) ដែលធ្វើឱ្យយើងពិបាកក្នុងការៀបចំ ព្រោះវាជាហានិភ័យមួយចំពោះសាលារៀននៅថ្ងៃខាងមុខ។ ទីពីរ ឆន្ទៈ និងមនសិការ ដែលពិបាកក្នុងការរកមនុស្សម្នាក់មកគ្រប់គ្រងសាលារៀនប្រកបដោយស្មារតីទទួលខុសត្រូវ និងមានចក្ខុវិស័យវែងឆ្ងាយ។ និងទីបីគឺពេលវេលា ការមានពេលវេលាគ្រប់គ្រាន់ សម្រាប់អង្គភាព សំខាន់ណាស់ ព្រោះថា ការងារមួយចំនួន មិនត្រូវបានធ្វើនៅក្នុងម៉ោងរដ្ឋបាលឡើយ ដែលចំណុចទាំងអស់នេះភាគច្រើនប្រឈមចំពោះស្ត្រីភេទក្នុងការដឹកនាំ គ្រប់គ្រង ប៉ុន្តែក៏មិនមែនមានន័យថា ស្ត្រីមិនអាចធ្វើបានដែរ។ ចំពោះការរៀបចំវេទិកាយេនឌ័រ ដើម្បីផ្សព្វផ្សាយឱ្យមានការយល់ដឹងបន្ថែម សាលារៀនភាគច្រើនក៏មិនសូវបានអនុវត្តដោយសារ កត្តាពេលវេលា ជាពិសេសសម័យសង្គលឌីជីថល ក៏មានការបង្ហាញផ្សព្វផ្សាយតាមបណ្តាញសង្គមនានាដូចជា Facebook, You tube ជាដើមអំពីការអប់រំយេនឌ័រ។

សរុបមកយើងសន្និដ្ឋានថា ការអនុវត្តសកម្មភាពយេនឌ័រនៅសាលារៀនមានភាពល្អប្រសើរ ដោយសាលារៀនភាគច្រើនបានបំពេញតាមលក្ខខណ្ឌកម្មវិធីកុមារមេត្រីដែលផ្តល់ឱ្យ និងបានអនុវត្តក្នុងកម្រិតល្អបង្គួរ។ ភាពខ្វះចន្លោះមួយចំនួនដែលសាលារៀនធ្វើមិនបាន អ្នកស្រាវជ្រាវរកឃើញថា បណ្តាលមកពីការយល់ដឹងរបស់គណៈគ្រប់គ្រងសាលាមិនទាន់ស៊ីជម្រៅលើសកម្មភាពយេនឌ័រ និងមួយចំនួនទៀតបណ្តាលមកពីកត្តាពេលវេលារបស់បុគ្គលក្នុងការចូលរួមសកម្មភាពឱ្យបានទៀងទាត់។ ទោះបីជាយ៉ាងណា ការរក្សាបាននូវសមភាពយេនឌ័រ វាជារឿងវិជ្ជមានសម្រាប់សាលារៀនក្នុងការផ្តល់សេវាអប់រំនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព សមភាព និងបរិយាបន្ន។

### ៤.១.៦ ស្ថានភាពអនុវត្តលើសមាសភាគទី៥

តារាង៨ ខាងក្រោមនេះបង្ហាញពីស្ថានភាពអនុវត្តលើសូចនាករនៃសមាសភាគទី៥ របស់កម្មវិធីសាលាកុមារមេត្រី (CFS) ដែលទទួលបានពីការស្ទង់មតិភាគសំណាក ១៥១ ហើយក្នុងនោះមានភាគ

សំណាកចំនួន ២ ដែលគាត់មិនបានឆ្លើយនូវសូចនាករ ទី៧ និងទី៩។ ថ្វីត្បិតតែពួកគាត់មិនបានឆ្លើយតប គ្រប់តាមសូចនាករដែលយើងចង់បាន ប៉ុន្តែលទ្ធផលបានបង្ហាញពីកម្រិតជឿជាក់លើទិន្នន័យ (Alpha= 0.93) ដែលយើងអាចទុកចិត្ត និងអាចធ្វើការបកស្រាយលើទិន្នន័យនេះបានដោយមិនមានភាពលម្អៀង ដោយអនុលោមតាមច្បាប់របស់ George and Mallery (2003)។

**សមាសភាគទី៥៖ ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍**

តារាង៨ ការចូលរួមពីភាគីពាក់ព័ន្ធ

| ល.រ | បរិយាយសូចនាករ | N | Mean | Std. Deviation | កម្រិតវាស់វែង |
|---|---|---|---|---|---|
| 90 | កុមារចូលរួមរៀបចំផែនការអភិវឌ្ឍសាលារៀន | 151 | 3.19 | 1.49 | មធ្យម |
| 91 | កម្មវិធីមិត្តជួយមិត្ត(សិស្សថ្នាក់ធំជួយថ្នាក់តូច) | 151 | 3.45 | 1.18 | មធ្យម |
| 92 | ការរៀបចំចាត់ចែងសកម្មភាពក្នុងសាលា និងសង្គមដោយកុមារ | 151 | 3.19 | 1.19 | មធ្យម |
| 93 | មានការរៀបចំនិងបង្កើតស្នាដៃកុមារ | 151 | 3.63 | 1.07 | ល្អបង្គួរ |
| 94 | ការពិនិត្យនិងចុះហត្ថលេខាលើសៀវភៅតាមដានការសិក្សាសិស្សរៀងរាល់ខែ | 151 | 4.58 | 0.64 | ល្អ |
| 95 | ការតាមដានការសិក្សា និងកិច្ចការផ្ទះរបស់កុមារ | 151 | 4.43 | 0.82 | ល្អបង្គួរ |
| 96 | ការចូលរួមនៅក្នុងយុទ្ធនាការប្រមូលកុមារចូលរៀននិងកិច្ចប្រជុំនានារបស់សាលារៀន | 150 | 3.86 | 1.12 | ល្អបង្គួរ |
| 97 | ការចូលរួមកៀគររកធនធានសម្រាប់កសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន | 151 | 3.53 | 1.06 | ល្អបង្គួរ |
| 98 | ការពិនិត្យតាមដានទៅលើដំណើរការសាងសង់ជួសជុលអគារ និងសម្ភារៈវត្ថុ | 150 | 3.62 | 1.12 | ល្អបង្គួរ |
| 99 | ការចូលរួមថែរក្សាការពារទ្រព្យសម្បត្តិសាលារៀន | 151 | 4.19 | 0.98 | ល្អបង្គួរ |
| 100 | មានកម្មវិធីឱ្យមាតាបិតាទស្សនកិច្ចសាលារៀន និងផ្តល់បទពិសោធន៍ល្អៗយ៉ាងតិចម្តងក្នុង១ឆ្នាំ | 151 | 3.05 | 1.39 | មធ្យម |
| 101 | ចូលរួមក្នុងការតាមដាន ការអនុវត្តម៉ោងពេលបង្រៀនរបស់គ្រូបង្រៀន | 151 | 3.65 | 1.11 | ល្អបង្គួរ |
| 102 | ចូលរួមកិច្ចប្រជុំប្រចាំត្រីមាសពិនិត្យមើលផែនការ និងការរីកចម្រើនរបស់សិស្ស និងសាលារៀន | 151 | 3.49 | 1.22 | មធ្យម |
| សរុបរួមសមាសភាគទី៥ | | 149 | 3.68 | 1.11 | ល្អបង្គួរ |

ផ្អែកលើតារាង៨ យើងសង្កេតឃើញការជ្រើសយកកម្រិតចង្អុលបង្ហាញលើស្ថានភាពអនុវត្តនៃសូចនាករនីមួយៗ ពីលេខ ៩០ ដល់ ១០២ ដែលផ្តោតលើសូចនាករគោលចំនួនបួនធំៗ មាន ១) ក្រុមប្រឹក្សាកុមារ

បានចូលរួមការងារសាលារៀន និងសង្គម, ២) មាតាបិតាសិស្សចូលរួមតាមដាន និងជំរុញការសិក្សារបស់កូន, ៣) គណៈកម្មការទ្រទ្រង់សាលាចូលរួមកសាងថែរក្សាសាលារៀន និង ៤) កម្មវិធីរបស់សាលាត្រូវបានគាំទ្រដោយមាតាបិតា និងអាណាព្យាបាលសិស្ស។

ចំណុចបរិយាយទាំងនោះមានកម្រិតចង្អុលបង្ហាញ ចាប់ពីកម្រិតអប្បបរមា (លេខ១) រហូតដល់កម្រិតអតិបរមា (លេខ៥) ធ្វើគម្លាតស្តង់ដារនៃពិន្ទុដែលទទួលបានមានគម្លាតធំ (SD=1)។ ការពិនិត្យនិងចុះហត្ថលេខាលើសៀវភៅតាមដានការសិក្សាសិស្សរៀងរាល់ខែ ទទួលបានមធ្យមពិន្ទុខ្ពស់ជាងគេ M= 4.58 និងមានគម្លាត SD= 0.64 ដែលជាទិន្នន័យមួយល្អ មានភាពសុក្រឹត្យ។ ទន្ទឹមនេះ យើងក៏ឃើញថា ការតាមដានការសិក្សា និងកិច្ចការផ្ទះរបស់កុមារ ក៏ទទួលបានលទ្ធផលអនុវត្តបានល្អ ដែលមានគម្លាតស្តង់ដាតូច (SD)= 0.82 និងបានមធ្យមពិន្ទុខ្ពស់ M= 4.43។ ផ្ទុយមកវិញ សូចនាករអំពីការមានកម្មវិធីឱ្យមាតាបិតាទស្សនកិច្ចសាលារៀន និងផ្តល់បទពិសោធន៍ល្អៗយ៉ាងតិចម្តងក្នុង១ឆ្នាំ យោងតាមទិន្នន័យគឺទទួលបានកម្រិតលទ្ធផលតិច ដែលមានកម្រិតមធ្យមពិន្ទុ M= 3.00 ទាបជាងគេក្នុងចំណោមសមាសភាគទី៥ និងមានគម្លាតធំ SD= 1.39។

កិច្ចសហប្រតិបត្តិការ និងការចូលរួមរបស់មាតាបិតា ដែលជាអាណាព្យាបាលសិស្សក្នុងវិស័យអប់រំនាំមកនូវផលវិជ្ជមានលើការសិក្សារបស់សិស្សានុសិស្ស ជាពិសេសលើវិន័យ និងវត្តមានក្នុងថ្នាក់ ព្រមទាំងការលើកជាសំណូមពរជូនដល់សាលា និងការប្រមូលការគាំទ្រនានា (ក្រសួងអបរំ ២០០៦)។ ជាងនេះទៅទៀតភាពជាដៃគូរជាមួយសហគមន៍ និងសាលារៀន បានចែករំលែកនូវទំនួលខុសត្រូវក្នុងដំណើរការសាលារៀន និងជួយដល់សិស្សសម្រេចបាននូវគោលបំណងនៃការអប់រំដែលមិនមែនសាលា ឬសហគមន៏ទទួលបានផលប្រយោជន៏នោះទេ(Tondeur, 2013)។ តួយ៉ាងលទ្ធផលខាងលើបានបង្ហាញថា សាលារៀនមួយភាគធំ បានយកចិត្តទុកដាក់ក្នុងការផ្តល់ឱកាសឱ្យកុមារចូលរួមក្នុងសកម្មភាពនានារបស់សាលារៀន តាមរយៈការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាកុមារ ការប្រជុំធ្វើផែនការនានារបស់សាលារៀន ការផ្តល់តួនាទីដល់កុមារនៅក្នុងជួរគណៈកម្មការនានាជាដើម។

សូចនាករពីមួយ (90) ដល់បួន (93) ខាងលើគូសបញ្ជាក់ពីការចូលរួមរបស់កុមារ យើងឃើញថា បានអនុវត្តក្នុងកម្រិតមធ្យមដូចៗគ្នា ដែលមានមធ្យមពិន្ទុ (M) ចន្លោះពី 3.19 ដល់ 3.63 ដែលជាការផ្តល់សិទ្ធិឱ្យកុមារជួយរៀបចំ និងចាត់ចែងកិច្ចដំណើរការសាលារៀន។ ក៏ប៉ុន្តែយើងក៏ឃើញថា សូចនាករទាំងបួននេះ មានគម្លាតពិន្ទុធំ SD> 1 ដែលមានន័យថាក៏មានសាលារៀនមួយភាគធំទៀតដែរ ដែលនៅមិនទាន់អនុវត្តក្នុងការ ផ្តល់ឱកាសឱ្យកុមារបានចូលរួមយ៉ាងជិតស្និទជាមួយសាលារៀន។ យោងតាមកិច្ចសម្ភាសន៍ជាមួយនាយកសាលាភាគច្រើនបានលើកឡើងថា ការចូលរួមក្នុងរបស់កុមារក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន និងផែនការផ្សេងៗទៀត គឺមិនសូវបាន ផ្តល់ឱកាសឱ្យកុមារា ឬកុមារី បានចូលរួមនោះទេ ដោយសារតែការកសាងផែនការមានភាពស្មុគស្មាញ និងល្អិតល្អន់ដែលកុមារភាគច្រើនគាត់មិនសូវមានគំនិតយោបល់ ឬសំណូមពរអ្វីដែរ។ ការចូលរួមរបស់មាតាបិតាសិស្ស (លេខ ៩៤, ៩៥ និង ៩៦) បង្ហាញពីកម្រិតមួយមានលក្ខណៈល្អប្រើសើរក្នុងការអនុវត្ត ព្រោះទទួលបានពិន្ទុមធ្យម ពី 3.86 ដល់ 4.58 (កម្រិតល្អបង្គួរ)។ ជាក់ស្តែងនាយិកាសាលាបឋមសិក្សាមួយរូប បានលើកឡើងអំពីការចូលរួមរបស់មាតាបិតាសិស្ស និងសប្បុរសជនទូទៅ ក្នុងរូបភាពជាថវិកាដែលមានទំហំទឹកប្រាក់ច្រើនអាចជួយអភិវឌ្ឍសាលារៀនបានល្អមួយកម្រិត។ ជាការពិតណាស់សហគមន៍គឺជាប្រភពធនធានរបស់សាលារៀន បើសាលារៀនមានទំនាក់ទំនងល្អជាមួយសហគមន៍ ជាពិសេសមាតាបិតាសិស្ស នោះពួកគាត់នឹងចូលរួមជាមួយសាលារៀន មិនថាក្នុងរូបភាពណាក៏ដោយ។ នាយិកាដដែលបានលើកឡើងថា «...ការចូលរួមរបស់គ្រួសារ សហគមន៍ កើតចេញពីការកសាងទំនុងចិត្តលើសកម្មភាពអប់រំនៅសាលារៀផ្ទាល់តែម្តង...» (#D02)។ ក្រៅពីការចូលរួមរបស់មាតាបិតា ឬសហគមន៍ គណៈគ្រប់គ្រងសាលា បានធ្វើការសហការយ៉ាងជិតស្និតនឹងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជួយសម្រួល និងការពារសិស្សពីគ្រោះថ្នាក់នានាដែលអាចនឹងកើតមានជាយថាហេតុ ដូចជាគ្រោះថ្នាក់ចរាចរណ៍ បញ្ហាក្មេងទំនើងតាមសាលា ឬការប្រើប្រាស់គ្រឿងញៀនជាដើម (គោលនយោបាយជាតិ ស្តីពីសុខភាពសិក្សា ២០១៩)។

យ៉ាងណាមិញ ការចូលរួមប្រជុំរវាងមាតាបិតាសិស្សជាមួយសាលារៀន អនុវត្តបានមួយចំនួនប៉ុណ្ណោះ ដែលចំណុចនេះហើយជាបញ្ហាមួយតែងរារាំងដល់ទំនាក់ទំនងរវាងភាគីទាំងពីរ ដោយមិនដែលបាន

ជួបប្រជុំជជែកពិភាក្សាគ្នា ថាតើសាលារៀនត្រូវការការគាំទ្រផ្នែកអ្វីខ្លះពីសហគមន៍ ហើយសហគមន៍ចង់បានអ្វីពី សាលារៀនវិញ? តាមការសម្ភាសជាមួយនាយកសាលា ភាគច្រើនសាលារៀនមិនដែលមានការប្រជុំទៀងទាត់ជាមួយមាតាបិតាអាណាព្យាបាលសិស្សនោះទេ ហើយមានសាលារៀនភាគតិច ដែលមិនដែលបានប្រជុំសោះតែម្តង។ ទាំងនេះសុទ្ធតែជាកត្តាដែលបង្កភាពដាច់ឆ្ងាយខ្វះសាមគ្គីរវាងសាសារៀន និងសហគមន៍ដែលដើរផ្ទុយពីក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីទាំងស្រុង។

សូចនាករចង្អុលបង្ហាញពីការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលា មានដូចជា៖ ការចូលរួមនៅក្នុងយុទ្ធនាការប្រមូលកុមារចូលរៀននិងកិច្ចប្រជុំនានារបស់សាលារៀន, ការចូលរួមកៀគររកធនធានសម្រាប់កសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន, ការពិនិត្យតាមដានទៅលើដំណើរការសាងសង់ជួសជុលអគារ និងសម្ភារវ័ន្តរបស់សាលារៀន មានកម្រិតអនុវត្តប្រហាក់ប្រហែលគ្នា ដែលមានមធ្យមពិន្ទុ M ក្នុងរង្វង់ 3.56 ដល់ 3.87 ស្ថិតក្នុងស្ថានភាពល្អបង្គួរ។ ដោយឡែកសូចនាករមួយដែល និយាយពីការចូលរួមថែរក្សាការពារទ្រព្យសម្បត្តិសាលារៀន ទទួលបានលទ្ធផលល្អ ដែលមានមធ្យមពិន្ទុខ្ពស់ ដល់ ៤.៩២ និងមានគម្លាតត្រឹមតែ ០.៩៨ ប៉ុណ្ណោះ នេះមានន័យថា សាលារៀនស្ទើតែទាំងអស់ត្រូវបានមាតាបិតាសិស្សចូលរួមជួយថែទាំ និងការពារទ្រព្យសម្បត្តិរបស់សាលា។

យ៉ាងណាក៏ដោយ បើយើងមើលពី សកម្មភាពនានា ដែលគាំទ្រពីការចូលរួមពីសហគមន៍ក្នុងការងារបង្រៀន និងរៀន ក្នុងសូចនាករទាំងពីរចុងក្រោយ ហាក់មិនសូវបានលទ្ធផលល្អនោះទេ ដោយទិន្នន័យដែលអ្នកគូសយកចាប់ពី កម្រិតចង្អុលបង្ហាញ លេខ ១ ទៅដល់ លេខ ៥ មានន័យថាសាលារៀនបានអនុវត្តមានប្រសិទ្ធភាពមានចំនួនច្រើន ហើយសាលារៀនដែលមិនបានអនុវត្ត និងអនុវត្តបានតិចតួចក៏មានចំនួនច្រើនដូចគ្នា ដែលធ្វើឱ្យគម្លាតស្តង់ដាកាន់តែធំ (SD> 1)។

### ៤.១.៧ ស្ថានភាពអនុវត្តលើសមាសភាគទី៦

តារាងខាងក្រោមនឹងបង្ហាញពីស្ថានភាពនៃការអនុវត្តការងារគ្រប់គ្រង និងដឹកនាំសាលារៀន របស់គណៈគ្រប់គ្រងសាលា តាមបែបកុមារមេត្រី ដោយផ្តោតលើសូចនាករចំនួនបួន មានការគ្រប់គ្រងដឹកនាំ ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ការងារបច្ចេកទេស ការច្រេងក្រងព័ត៌មាន និងរបាយការណ៍។

**សមាសភាគទី៦៖ ការគ្រប់គ្រង និងដឹកនាំសាលារៀន**

តារាង៩ ការគ្រប់គ្រង ដឹកនាំ

| ល.រ | បរិយាយ | N | Mean | Std. Deviation | កម្រិតវាស់វែង |
|---|---|---|---|---|---|
| 103 | គ្រូបង្រៀនបានចូលរួមកសាងផែនការនានារបស់សាលារៀន | 151 | 3.79 | 1.18 | ល្អបង្គួរ |
| 104 | បុគ្គលិក និងគ្រូបង្រៀនអាចរៀបរាប់បានពីផែនការអភិវឌ្ឍរបស់សាលារៀន | 151 | 3.68 | 1.07 | ល្អបង្គួរ |
| 105 | បែងចែកតួនាទី និងភារកិច្ចច្បាស់លាស់ | 151 | 4.42 | 0.73 | ល្អបង្គួរ |
| 106 | វាយតម្លៃបុគ្គលិកដោយផ្អែកលើគោលការណ៍ និងលទ្ធផលការងារ | 151 | 4.2 | 0.89 | ល្អបង្គួរ |
| 107 | មានគណៈកម្មការគ្រប់គ្រង និងប្រើប្រាស់ថវិកា | 151 | 4.41 | 0.83 | ល្អបង្គួរ |
| 108 | មានការបង្ហាញតារាងចំណូល និងចំណាយ | 151 | 4.18 | 1.00 | ល្អបង្គួរ |
| 109 | មានរបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវ | 151 | 4.33 | 0.92 | ល្អបង្គួរ |
| 110 | ប្រជុំបច្ចេកទេសរាល់ខែ និងមានប្រសិទ្ធភាព | 151 | 4.13 | 0.75 | ល្អបង្គួរ |
| 111 | ធ្វើអធិការកិច្ចថ្នាក់រៀន (អង្កេតថ្នាក់រៀន) និងផ្តល់ព័ត៌មានត្រឡប់ក្នុងការជួយគ្រូបង្រៀន | 151 | 3.91 | 1.08 | ល្អបង្គួរ |
| 112 | ពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីសិក្សាជាប្រចាំ (ខ្លឹមសារ និងវិធីសាស្ត្របង្រៀន) | 151 | 4.17 | 0.95 | ល្អបង្គួរ |
| 113 | ជានាការវាយតម្លៃសិស្សបានត្រឹមត្រូវតាមស្តង់ដាកម្មវិធី | 151 | 4.10 | 0.88 | ល្អបង្គួរ |
| 114 | មានរបាយការណ៍រីកចម្រើនរបស់សាលានៅគ្រប់ដំណាក់កាល | 151 | 4.05 | 0.99 | ល្អបង្គួរ |
| 115 | មានរបាយការណ៍ហិរញ្ញវត្ថុដែលមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសាលា | 151 | 4.24 | 0.92 | ល្អបង្គួរ |
| 116 | មានព្រឹត្តបត្រព័ត៌មានសាលារៀនបិទនៅក្តារខៀនព័ត៌មាន | 151 | 3.96 | 1.00 | ល្អបង្គួរ |
| សរុបរួមសមាសភាគទី៦ | | 151 | 4.11 | 0.94 | ល្អបង្គួរ |

ផ្អែកតាមតារាង៩ ខាងលើនេះ៖ យើងឃើញថាសូចនាករដែលបានមធ្យមពិន្ទុខ្ពស់ជាងគេនិយាយពីបំណែងចែកតួនាទី និងភារកិច្ចច្បាស់លាស់ ដែលមាន M= 4.42 គម្លាតស្តង់ដា SD= 0.73។ ដោយឡែកសូចនាករដែលបានពិន្ទុទាបជាងគេ បរិយាយពីបុគ្គលិក និងគ្រូបង្រៀនអាចរៀបរាប់បានពីផែនការអភិវឌ្ឍ

របស់សាលារៀន ដែលមធ្យមពិន្ទុ M= 3.68 គម្លាត SD= 1.07 ដែលមានន័យថា គ្រូបង្រៀន និងបុគ្គលិក មិនសូវបានយល់ដឹង និងអាចរៀបរាប់បានអំពីផែនការអភិវឌ្ឍរបស់សាលារៀននោះទេ។ ពាក់ព័ន្ធការងារគ្រប់គ្រងដឹកនាំ របស់នាយកសាលាយើងឃើញថា ក្នុងចំណោមបរិយាយទាំងបួនខាងលើ ទទួលបានពិន្ទុល្អចំនួនពីរ និងមិនសូវល្អចំនួនពីរ ដែលមានន័យថា ស្ថានភាពលើការគ្រប់គ្រងទូទៅរបស់នាយក/នាយិកា នៅក្នុងកម្រិតល្អបង្គួរ។ ចំពោះការគ្រប់គ្រង និងប្រើប្រាស់ថវិកា យើងឃើញថា គ្រប់សូចនាករដែលពាក់ព័ន្ធ ចាប់ពី ១០៧ ដល់ ១០៩ ទទួលបានមធ្យមពិន្ទុ M > 4 ដែលបញ្ជាក់ពី ស្ថានភាពនៃការប្រើប្រាស់ថវិកានៅសាលារៀនអនុវត្តបានល្អ។ ពាក់ព័ន្ធការងារបច្ចេកទេសរបស់នាយក/នាយិកា ក៏ទទួលបានលទ្ធផលអនុវត្តបានល្អប្រសើផងដែរ ដែលនិយាយពីការប្រជុំបច្ចេកទេសតាមខែនីមួយៗ ទទួលបានមធ្យមពិន្ទុ M= 4.13 គម្លាតស្តង់ដាត្រឹមតែ SD= 0.75 ប៉ុណ្ណោះ។

ការងារអធិការកិច្ចថ្នាក់រៀន និងការត្រួតពិនិត្យលើខ្លឹមសារ និងវិធីសាស្ត្របង្រៀនក៏សាលារៀនបានអនុវត្តក្នុងកម្រិតល្អ ដែលមានតម្លៃ M> 4។ ការចងក្រងរបាយការណ៍នានា មានដូចជារបាយការណ៍នៃភាពរីកចម្រើនរបស់សាលរៀន និងរបាយការណ៍ហិរញ្ញវត្ថុដោយមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសាលាឃើញថាសាលារៀនអនុវត្តបានល្អ ដោយមានមធ្យមពិន្ទុខ្ពស់ (M> 4) ដោយឡែកការបិទផ្សាយរបាយការជាសាធារណៈ តាមរយៈព្រឹត្តបត្រនៅតាមក្តារខៀនព័ត៌មាន សាលារៀនហាក់អនុវត្តមិនសូវបានល្អនោះទេដោយសាររកឃើញថាសូចនាករនេះ មានពិន្ទុមធ្យម តូចជាង 4 និងមានគម្លាតស្តង់ដា ធំជាង 1 ។

យោងតាមការធ្វើសម្ភាសជាមួយនាយកសាលា មាននាយកភាគច្រើនបានលើកឡើងប្រហាក់ប្រហែលគ្នាអំពីការគ្រប់គ្រង ដោយផ្តោតលើការងារពីរផ្នែកសំខាន់ៗមាន ទី១. ការងារគ្រប់គ្រងរដ្ឋបាល និងទី២. ការងារបច្ចេកទេស។ ការងារគ្រប់គ្រងរដ្ឋបាល គណៈគ្រប់គ្រងមាននាយក/នាយិកា នាយករង ឬនាយិការង រួមទាំងបុគ្គលិកទីចាត់ការ បានរៀបចំធ្វើបំណែងចែកគ្រូបង្រៀន បំណែងចែកភារកិច្ចច្បាស់លាស់ដល់បុគ្គលិកទាំងអស់ដើម្បីប្រគល់ភារកិច្ចដែលត្រូវអនុវត្តតាមឆ្នាំសិក្សានីមួយៗ។ ការរៀបចំធ្វើរបាយការណ៍បវេសនកាលដើមឆ្នាំ របាយការណ៍ប្រចាំខែ របាយការណ៍ឆមាស របាយការដំណាច់ឆ្នាំ និងរបាយការណ៍ពាក់

ព័ន្ធផ្សេងៗ ដែលទីចាត់ការត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានទៀងទាត់។ កិច្ចរៀបចំដំណើរការសាលារៀនក្នុងឆ្នាំសិក្សានីមួយៗ ក៏មានការចូលរួមចំណែកពីលោកគ្រូ អ្នកគ្រូ ទាំងអស់នៅក្នុងសាលាទើបអាចប្រព្រឹត្តទៅបានជោគជ័យ ជាពិសេសគឺការប្រជុំលើកផែនការសម្រាប់អនុវត្តតាមឆ្នាំនីមួយៗ ការកំណត់សកម្មភាពគោល និងអាទិភាពដែលត្រូវបំពេញ។

ចំពោះការងារបច្ចេកទេស អ្នកស្រាវជ្រាវរកឃើញថា នាយកភាគតិចតែប៉ុណ្ណោះ បានផ្តោតខ្លាំងលើការងារនេះ ដោយសង្កត់ធ្ងន់លើការងារបង្រៀន និងរៀន។ យោងតាមឯកសារណែនាំ របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ បោះពុម្ពឆ្នាំ ២០០៨ បានលើកឡើងពីលក្ខណៈសម្បតិរបស់សាលាកុមារមេត្រី ដោយផ្តោតសំខាន់លើវិធីសាស្ត្របង្រៀនសិស្សដែលមានភាពទាក់ទាញសម្រាប់កុមារគ្រប់រូប និងរក្សាបាននូវបរិយាបន្នក្នុងការសិក្សា។ ក្នុងន័យនេះ ការបង្រៀន ត្រូវផ្តោតលើល្បែងសិក្សាជាចំបាច់ និងការប្រើប្រាស់សម្ភារឧបទ្ទេសក្នុងការបង្រៀនជាជាងឱ្យតែសិស្សអាន និងកត់ត្រាមេរៀនចូលសៀវភៅ។ ផ្ទុយទៅវិញយើងឃើញថា នាយកសាលាភាគច្រើនមិនសូវយកចិត្តទុកដាក់លើការងារបច្ចេកទេសនោះទេ ដូចជាការធ្វើថ្នាក់និទ្ទស្សន៍ ការប្រជុំផលិតសម្ភារបង្រៀន និងរៀន ជាដើមគឺមិនសូវមានសកម្មភាពអនុវត្តនោះទេ។ ការងារគ្រប់គ្រងការងារបច្ចេកទេសរបស់នាយក វាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្ស ដល់ប្រសិទ្ធភាពផ្ទៃក្នុងរបស់សាលារៀនផងដែរ។

ងាកមកមើលការប្រើប្រាស់ និងខ្ទង់ចំណាយថវិកាលើសកម្មភាពគោលទាំងពីរ ដែលសកម្មភាពគោលទីមួយ ផ្តោតលើការគាំទ្រកិច្ចដំណើរការ និងសកម្មភាពគោលទីពីរ ផ្តោតលើការកែលម្អគុណភាពអប់រំ ឃើញថាតាមសាលានីមួយៗ បានចាត់ចែងបានត្រឹមត្រូវ តាមខ្ទង់ចំណាយនីមួយៗ គ្រាន់តែសកម្មភាពមួយចំនួនដែលបានគ្រោង ហាក់មិនសូវត្រូវតាមមុខសញ្ញាចំណាយដែលកំណត់ដោយអន្តរក្រសួង (លិខិតលេខ ៨០១៥ របស់ក្រសួងសេដ្ឋកិច្ច និងក្រសួងអប់រំ)។ ទោះជាយ៉ាងណា យើងឃើញសាលាទាំងអស់ដែលយើងបានចុះធ្វើសម្ភាសន៍ជាមួយនាយក ហើយពិនិត្យមើលរបាយការណ៍មួយចំនួន មានភាពល្អប្រសើរច្រើន លើការងារគ្រប់គ្រងទូទៅ ការអភិវឌ្ឍសាលារៀន ការពង្រឹងវិន័យសណ្តាប់ធ្នាប់ បរិស្ថានសិក្សា និងមានរបាយ

ការណ៍ហិរញ្ញវត្ថុត្រឹមត្រូវ តាមការណែនាំ។ ជារួមការអនុវត្តលើការងារគ្រប់គ្រងសាលារៀនតាមបែបកុមារមេត្រី អាចសន្និដ្ឋានបានថា ស្ថិតក្នុងស្ថានភាពល្អបង្គួរ បើធៀបទៅនឹងស្តង់ដារបស់កម្មវិធី។

### ៤.១.៨ សរុបលទ្ធផលរួមលើស្ថានភាពអនុវត្តសមាសភាគទាំង ៦

ខាងក្រោមនេះជាតារាងទិន្នន័យបង្ហាញពីកម្រិតអនុវត្តកម្មវិធីដែលមាន ៦សមាសភាគ និងត្រូវបានវាយតម្លៃ ដាក់ពិន្ទុចំណាត់ថ្នាក់ទៅតាមសភាគនីមួយៗ និងសរុបជារួម។

តារាង១០ កម្រិតអនុវត្តលើសមាសភាគទាំង ៦

| បរិយាយ | មធ្យមពិន្ទុរួម (Mean) | គម្លាតស្តង់ដារួម (SD) | កម្រិតវាស់វែង |
|---|---|---|---|
| សមាសភាគទី១ | 3.69 | 1.08 | ល្អបង្គួរ |
| សមាសភាគទី២ | 3.64 | 1.01 | ល្អបង្គួរ |
| សមាសភាគទី៣ | 3.75 | 1.02 | ល្អបង្គួរ |
| សមាសភាគទី៤ | 3.92 | 1.09 | ល្អបង្គួរ |
| សមាសភាគទី៥ | 3.69 | 1.11 | ល្អបង្គួរ |
| សមាសភាគទី៦ | 4.12 | 0.95 | ល្អបង្គួរ |
| សរុបរួម | 3.80 | 1.04 | ល្អបង្គួរ |

ផ្អែកតាមតារាង១០ ខាងលើ អ្នកស្រាវជ្រាវបានបូកសរុបលទ្ធផលនៃការវាស់វែងលើតម្លៃធម្យមពិន្ទុរួម ក្នុងសមាសភាគនីមួយៗ យកមកបញ្ចូលគ្នា និងទាយយកលទ្ធផលរួមមួយ។ លទ្ធផលបង្ហាញថាស្ថានភាពអនុវត្តលើសមាសភាគទាំង ៦ របស់កម្មវិធីសាលាកុមារមេត្រី ក្នុងកម្រិតល្អបង្គួរ ដែលមានតម្លៃមធ្យមស្មើ ៣.៨០។ ថ្វីត្បិតលទ្ធផលដែលរកឃើញ ស្ថិតក្នុងស្ថានភាពល្អបង្គួរ ប៉ុន្តែមធ្យមពិន្ទុ នៅក្នុងកម្រិតទាបនៅឡើយ ($M < 4.0$) ដែលមានន័យថាសាលារៀនអនុវត្តមិនទាន់បានស្តង់ដានោះទេ។ លើសពីនេះ យើងក៏សម្គាល់ឃើញ តម្លៃនៃគម្លាតស្តង់ដា (SD) ធំជាង 1 ដែលយើងអាចសន្និដ្ឋានថា សាលារៀន អនុវត្តមិនទាន់មានភាពជាប់លាប់ ទៀងទាត់ និងមានប្រសិទ្ធភាពនោះទេ។

## ៤.២ លទ្ធផលគុណវិស័យ

**កម្រិតស្ថានភាពនៃការអនុវត្តកម្មវិធីលើសមាសភាគទាំង ៦** នៅក្នុងតារាងខាងក្រោមនេះ នឹងបង្ហាញពីស្ថានភាពអនុវត្តក្របខ័ណ្ឌកម្មវិធីតាមសមាសភាគនីមួយៗ ដែលអ្នកស្រាវជ្រាវបានចងក្រង និងកត់ត្រាធ្វើការសំយោគគំនិត ដែលបានមកពីការសម្ភាសជាមួយគណៈគ្រប់គ្រងសាលា និងថ្នាក់ដឹកនាំ មន្ត្រីនៃការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត។

តារាង១១ លទ្ធផលគុណវិស័យ

| សូចនាករវាស់វែង | ស្ថានភាពនៃការអនុវត្ត |
|---|---|
| ១.អំពីការអនុវត្តសមាសភាគទី១៖ កុមារទាំងអស់បានចូលរៀន | -បានធ្វើផែនការជំរឿនស្ថិតិកុមារតាមភូមិ<br>-គូសផែនទីខ្នងផ្ទះ<br>-ទំនាក់ទំនងជាមួយអាជ្ញាធរ<br>-ស្រង់ទិន្នន័យកុមារគ្រប់អាយុចូលរៀន<br>-យុទ្ធនាការប្រមូលកុមារ<br>-ផ្សព្វផ្សាយលើបណ្តាញសង្គមពីការចុះឈ្មោះចូលរៀន |
| ២.អំពីការអនុវត្តសមាសភាគទី២៖ ការសិក្សាប្រកបដោយប្រសិទ្ធភាព | -ពង្រឹងវិន័យរបស់គ្រូបង្រៀន<br>-អធិការកិច្ចតាមថ្នាក់<br>-តាមដានវត្តមានសិស្ស<br>-ប្រើប្រាស់ឧបករណ៍តេស្តរបស់ក្រសួង<br>-ប្រឡងប្រចាំខែជម្មតា(រៀបចំវិញ្ញាសាតាមថ្នាក់រៀងខ្លួន)<br>-មិនមានការប្រឡងតេស្តស្តង់ដារទេ |
| ៣.អំពីការអនុវត្តសមាសភាគទី៣៖ សុខភាព សុវត្ថិភាព និងការការពារកុមារ | -បានណែនាំ និងទប់ស្កាត់ប្រភេទចំណីអាហារហាមឃាត់ ដល់គ្រូ សិស្ស និងអ្នកលក់<br>-អប់រំណែនាំសិស្សពីសុវត្ថិភាពចំណីអាហារ<br>-រាយការណ៍ទៅភូមិ ឃុំ និងសមត្ថកិច្ចក្នុងករណីមានបាតុភាពកើតឡើង រួមមានការឈ្លោះទាស់ទែងគ្នារវាងសិស្សនិងសិស្ស ការប្រើអំពើហិង្សា ការកេងប្រវ័ញ្ច និងរំលោភសិទ្ធិកុមារ<br>-មានក្រុមបណ្តាយជួយមើលសន្តិសុខសុវត្ថិភាពសាលារៀន |
| ៤.អំពីការអនុវត្តសមាសភាគទី៤៖ ការឆ្លើយតបទៅនឹងយេនឌ័រ | -បានរៀបចំក្រុមប្រឹក្សាកុមារដែលមានកុមារី ចូលរួម និងលើកទឹកចិត្ត<br>-ផ្តល់តួនាទីឱ្យស្ត្រីចូលរួមក្នុងការដឹកនាំសកម្មភាពនៅសាលារៀន<br>-សកម្មភាពក្រុមត្រូវតែមានកុមារីចូលរួម |

| | |
|---|---|
| ៥.អំពីការអនុវត្តសមាសភាគទី៥៖ ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ | -ចូលរួមដាំកូនឈើ<br>-ជួយជាថវិកា និងសម្ភារមួយចំនួន<br>-ជួយការពារទ្រព្យសាលារៀន<br>-បញ្ជូនកូនមកសាលារៀន<br>-ផ្តល់ព័ត៌មានឱ្យសាលាទៅវិញទៅមក<br>-រៀបចំឱ្យអាណាព្យាបាលបានចូលរួមអង្កេតលើការសិក្សារៀនសូត្រកូនៗរបស់គាត់ (ធ្វើបានតិចតួចបំផុត) |
| ៦.អំពីការអនុវត្តសមាសភាគទី៦៖ ការគ្រប់គ្រង និងដឹកនាំ | -មិនសូវមានការផ្តល់ឱកាសឱ្យសហគន៍ចូលរួមជាមួយសាលាបានច្រើន និងទៀងទាត់<br>-ប្រជុំបច្ចេកទេសតាមខែនីមួយ (អនុវត្តបានមួយចំនួន)<br>-ការប្រជុំធ្វើផែនការនានាធ្វើបានតិចតួច និងមិនមានការចូលរួមពីលោកគ្រូ អ្នកគ្រូ គ្រប់គ្នានោះទេ<br>-របាយការណ៍ហិរញ្ញវត្ថុនៅសាលារៀនមិនមានបិទជាសាធារណៈ<br>-មិនទាន់មានការវាយតម្លៃសិស្សត្រឹមត្រូវតាមស្តង់ដានោះទេ<br>-ខ្វះការពិនិត្យតាមដាន និងវាយតម្លៃលើការងាររដ្ឋបាល និងបច្ចេកទេសគ្រូបង្រៀន |

**ការយល់ដឹងចំពោក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី**

អំពីការយល់ដឹងចំពោះក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី ឃើញថា នាយក/នាយិកា បានយល់ដឹង និងអនុវត្តស្របតាមក្របខ័ណ្ឌកម្មវិធី និងតាមការណែនាំពីក្រសួងអប់រំ តាមរយៈការប្រជុំ និងកម្មវិធីសិក្ខាសាលានានា។សាលាដែលមានបរិស្ថានសិក្សាល្អ ជាទីស្រឡាញ់ចូលចិត្តរបស់កុមារ មានបរិស្ថានសិក្សាស្អាត មានសោភ័ណភាព ទាក់ទាញ និងបានជាប្រយោជន៍ដល់ដំណើរការសិក្សារៀនសូត្រ។ ជាសាលាដែលផ្តល់សុវត្ថិភាព និងភាពកក់ក្តៅដល់កុមារគ្រប់រូប ប្រកបដោយសមធម៌ និងបរិយាបន្ន....។

តាមកិច្ចសម្ភាសជាមួយមន្ត្រីគ្រប់គ្រងកម្មវិធីសាលាកុមារមេត្រី មានមន្ត្រីមួយនាក់មន្ទីរអប់រំខេត្តត្បូងឃ្មុំបានមានប្រសាសន៍ថា «...ការអនុវត្តកម្មវិធីសាលកុមារមេត្រី មានការធ្លាក់ចុះដោយសារបង្វះការពិនិត្យតាមដាន ឱ្យបានជិតដល់ ប្រព័ន្ធតាមដានមិនដំណើរការ (ខូច) ហើយសាលារៀនមួយចំនួនធំហាក់មិនសូវយកចិត្តទុកដាក់ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព...» (#Stuff02)។ លោកក៏បានលើកឡើយបន្ថែមដោយផ្សារភ្ជាប់អំពីលក្ខខណ្ឌកម្មវិធីសាលាកុមារមេត្រី មានស្តង់ដាខ្ពស់ដែលសាលារៀន ភាគច្រើនមិនអាចអនុវត្ត

បានតាមនិយាម មួយវិញទៀតកម្មវិធីនេះអនុវត្តរយៈពេលយូរមកហើយ តែហាក់មិនមានប្រសិទ្ធភាព ទើបក្រសួងបានទម្លាក់នូវកម្មវិធីថ្មីៗជាច្រើនទៀត ដែលមានទម្រង់ប្រហាក់ប្រហែលគ្នាសម្រាប់អនុវត្តបន្ត។ ជាមួយគ្នានេះ លោកប្រធានការិយាល័យមួយរូបបានលើកឡើងថា «...ការអនុវត្តកម្មវិធីសាលាកុមារមេត្រី នៅទូទាំងស្រុក ស្ថិតក្នុងស្ថានភាពមធ្យម ដោយសារការចុះពិនិត្យតាមដានឃើញថា មានសាលាភាគតិចដែលអាចអនុវត្តបាន លើ ៧០% នៃស្តង់ដារកម្មវិធី និងមានសាលាភាគច្រើនដែលអនុវត្តបានត្រឹមតែ ៥០ ទៅក្រោម ៧០% នៃកម្មវិធីតម្រូវ...» (#stuff02)។

តាមកិច្ចសម្ភាសជាមួយមន្ត្រីពាក់ព័ន្ធផ្សេងទៀតក៏បានឱ្យដឹង អំពីលទ្ធផលដែលទទួលបានរវាងការចុះវាយតម្លៃផ្ទាល់ និងតាមរយៈធ្វើស្វ័យវាយតម្លៃពីសាលារៀន។ «....លទ្ធផលបានបង្ហាញថា ការចុះពិនិត្យតាមដាន និងវាយតម្លៃផ្ទាល់ ទទួលបានលទ្ធផលទាបជាងការឱ្យសាលារៀនធ្វើស្វ័យវាយតម្លៃ...» (stuff05)។ សរុបមកអ្នកស្រាវជ្រាវកត់សម្គាល់ឃើញថា ការអនុវត្តកម្មវិធីសាលាកុមារមេត្រី នៅក្នុងខេត្តត្បូងឃ្មុំ ស្ថិតក្នុងស្ថានភាពមធ្យម ដែលសាលារៀនមួយចំនួនអាចបំពេញតាមលក្ខខណ្ឌកម្មវិធីបាន និងសាលាមួយចំនួនទៀតធ្វើមិនបានដោយកត្តាប្រឈមផ្សេងៗ ដែលនឹងលើកឡើងនៅចំណុចបន្ទាប់។

## ៤.៣ បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រី

ផ្អែកតាមការប្រមូលកម្រងសំណួររបស់គ្រូបង្រៀនអំពីបញ្ហាប្រឈមដែលជួបប្រទះ សម្រាប់កម្មវិធីសាលាកុមារមេត្រី និងយោងលើលទ្ធផលបានមកពីការសម្ភាស ដែលអ្នកស្រាវជ្រាវបានយកមកធ្វើការវិភាគ (Coding) ឃើញមានបញ្ហាប្រឈមជាច្រើនលើការអនុវត្តតាមសូចនាករគោលសំខាន់ៗ ដូចខាងក្រោម៖

### ៤.៣.១ ទស្សនៈប្រឈមរបស់មន្ត្រីគ្រប់គ្រងលើការអនុវត្តកម្មវិធីសាលាកុមារមេត្រី

**ការពិនិត្យតាមដានមិនបានជាប់លាប់**

យោងតាមកិច្ចសម្ភាសន៍ជាមួយមន្ត្រីនៃការិយាល័យ អប់រំ យុវជន និងកីឡាស្រុក បានលើកឡើងថា

«...សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ លើការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅតាមសាលារៀន ថ្នាក់ការិយាល័យអប់រំស្រុក និងក្រុមពិនិត្យតាមដាន និងវាយតម្លៃថ្នាក់ស្រុក (DTMT) បានលើកឡើងថា

ការវាយតម្លៃសាលាកន្លងមកគឺសាលារៀនជាអ្នកធ្វើស្វ័យវាយតម្លៃដោយខ្លួនឯង ដោយមិនបានចុះវាយតម្លៃពីក្រុម DTMT ផ្ទាល់នោះទេ ព្រោះមិនមានខ្ទង់ថវិកាសម្រាប់ចំណាយលើការចុះវាយតម្លៃ។ តាមការលើកឡើងរបស់ប្រធានការិយាល័យមួយរូប ក្នុងចំណោមសាលារៀនទាំង ៨៦ សាលានៅក្នុងស្រុករបស់លោក មន្ត្រីត្រួតពិនិត្យបានចុះវាយតម្លៃផ្ទាល់បានតែប្រមាណ ១០ សាលាប៉ុណ្ណោះក្នុងឆ្នាំ ២០២២ កន្លងទៅ ហើយជាង ៧០ សាលាផ្សេងទៀត នាយកសាលាជាអ្នកធ្វើដោយខ្លួនឯង...»(stuff04)។ អនុប្រធានការិយាល័យអធិការកិច្ចមួយរូបក៏បានលើកឡើងផងដែរថា «....សម្រាប់កន្លងមកមន្ទីរចុះវាយតម្លៃក្នុងចំណោម ៤០៦ គ្រឹះស្ថានបឋមសិក្សាក្នុងខេត្ត មានប្រមាណ ៥០%ប៉ុណ្ណោះដែលអនុវត្តកម្មវិធីកុមារមេត្រី...» (stuff02)។

**កម្មវិធីមានលក្ខខណ្ឌតម្រូវខ្ពស់ពិបាកក្នុងការអនុវត្ត**

ទស្សនៈមន្ត្រីថ្នាក់ការិយាល័យ អប់រំ យុវជន និងកីឡាស្រុក បានលើកឡើងបន្ថែមទៀត ពាក់ព័ន្ធនឹងលក្ខខណ្ឌរបស់កម្មវិធីហាក់មានកម្រិតខ្ពស់ដែលធ្វើឱ្យសាលារៀនពិបាកក្នុងការអនុវត្ត តួយ៉ាងដូចជា ការរៀបចំបន្ទប់មុខវិជ្ជា គឺសាលារៀនមិនអាចធ្វើបាន គ្រូបង្រៀនមិនបានធ្វើកិច្ចតែងការបង្រៀន គុណវុឌ្ឍិគ្រូនៅមានកម្រិតទាប ការប្រឡងមិនទាន់មានស្តង់ដារួម សមស្របតាមកម្មវិធីសិក្សាប្រចាំឆ្នាំ ដែលធ្វើឱ្យលទ្ធផលរបស់សិស្សស្ថិតក្នុងកម្រិតទាប។ ដូចមានខ្លឹមសារដកស្រង់ខាងក្រោម៖

> «....ការវាយតម្លៃធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក តែក្រោយមកប្រព័ន្ធត្រូវបានខូចមិនដំណើរការធ្វើឱ្យខកខានមិនបានពិនិត្យតាមដានតទៅទៀត។ ក្រោយមកចូលដល់វិបត្តិកូវីដ-១៩ សាលារៀនក៏បានបិទទ្វា ពេលនោះសាលាកុមារមេត្រី ក៏លែងបានផ្តោលលើទៀតហើយ ដោយផ្តោតតែធ្វើយ៉ាងណាឱ្យសិស្សបានរៀនតិចតួចតាមលទ្ធភាពដែលអាចធ្វើបាន ព្រោះកម្មវិធីកុមារមេត្រី អនុវត្តពេលដែលសាលារៀនបើកទ្វាតែប៉ុណ្ណោះ។ បន្ទាប់ពីវិបត្តិកូវីដ-១៩ ត្រូវបានបញ្ចប់ ការពិនិត្យតាមដានលើការអនុវត្តកម្មវិធីសាលាកុមារមេត្រីក៏មិនទាន់បានយកមកអនុវត្តជាថ្មីទៀតដែរ...» (stuff02)។

«...ការធ្វើតេស្តវាស់វែងសមត្ថភាពសិស្សចុងឆ្នាំ សាលាមិនបានធ្វើ ដោយមូលហេតុផ្សេងៗ ដូចជាមិនមានវិញ្ញាសាច្បាស់លាស់ ដែលអាចយកមកវាស់វែងសមត្ថភាពសិស្សបាន ពេលខ្លះអាចច្រើនពេក ឬតិចពេក ងាយពេក និងស្រួលពេក ដោយសារតែ**មិនមានគណៈកម្មការរៀបចំតេស្ត**ឱ្យបានត្រឹមត្រូវ។ ស្របជាមួយគ្នានេះ មន្ត្រីការិយាល័យ បឋមសិក្សា មួយរូបក៏លើកឡើងស្រដៀងគ្នាផងដែរ អំពីការបង្រៀនរបស់គ្រូ គឺមិនទាន់បានស្របតាមកម្មវិធីកុមារមេត្រីនោះទេ គ្រូបង្រៀនភាគច្រើនលើសលប់មិនបានធ្វើកិច្ចតែងការបង្រៀននិងមិនបានប្រើសម្ភារឧបទ្ទេសក្នុងការបង្រៀនឡើយ....»(stuff01)។

«...ចំណុចសំខាន់មួយទៀតដែលជាបញ្ហាចោទសម្រាប់កម្មវិធីសាលាកុមារមេត្រី គឺ**កង្វះការចូលរួមរបស់សហគមន៍** ជុំវិញសាលារៀន ដោយសារតែកត្តាផ្សេងៗដូចជា កត្តាទីមួយផ្នត់គំនិតរបស់ប្រជាពលរដ្ឋក្នុងការចូលរួមសកម្មភាពអប់រំ ដែលគាត់យល់ថាវាជាកាតព្វកិច្ចរបស់សាលារៀនម្ខាង។ កត្តាទីពីរជីវភាពរបស់ពួកគាត់នៅមិនធូធារ ពិបាកក្នុងការចែករំលែក និងផ្តល់ធនធានសម្រាប់សាលារៀន។ កត្តាទីបីពេលវេលារបស់ពួកគាត់មានភាពចង្អៀតសម្រាប់កោះហៅមកចូលរួមកិច្ចប្រជុំនានាដែលសាលារៀនអញ្ជើញ ដោយសារគាត់រវល់ប្រកបរបរចិញ្ចឹមជីវិត និងចំណាកស្រុកជាដើម...»(stuff03)។

### សាលារៀនមិនបានរៀបចំគណៈកម្មការនានាឱ្យបានត្រឹមត្រូវ

គណៈកម្មការនានានៅសាលារៀន ដើរតួនាទីសំខាន់ក្នុងការអនុវត្តការងារប្រតិបត្តិការសាលារៀន ដូចជាការរៀបចំកិច្ចដំណើរការសិក្សារៀនសូត្រ ការរៀបចំថវិកា ការរៀបចំការប្រឡង និងកម្មវិធីផ្សេងៗ។ ការមិនមានគណៈកម្មការទាំងនេះ ធ្វើឱ្យការគ្រប់គ្រងមានភាពលំបាក និងមិនមានសកម្មភាពច្បាស់លាស់ ដូចជាការមិនបានរៀបចំកម្មវិធីប្រឡងកម្រិតវិញ្ញាសាស្តង់ដា ឬការធ្វើតេស្តថ្នាក់ជាតិជាដើម។

### កង្វះការចូលរួមរបស់សហគមន៍

ការចូលរួមរបស់សហគមន៍ ជាកត្តាចម្បងក្នុងការកែប្រែមុខមាត់សាលារៀន ឱ្យមានសោភ័ណភាព គុណភាព និងកសាងទំនុកចិត្តដល់សហគមន៍ទាំងមូល។ ទោះបីយ៉ាងណា សហគមន៍ដែលនៅជុំវិញសាលា

រៀនមួយចំនួន នៅមិនទាន់យល់ដឹងពីសារៈសំខាន់នៃការចូលរួមជាមួយសាលារៀននៅឡើយ។ កត្តាដែលពួកគាត់មិនចូលរួមបណ្ដាលមកពី ជីវភាពពួកគាត់នៅមានការខ្វះខាត មិនមានធនធានថវិកាសម្រាប់ជួយផ្ដត់ផ្គង់សាលារៀននោះទេ។ គ្រួសារមួយចំនួនទៀត ក៏បានធ្វើការចំណាកស្រុកទៅធ្វើការរកស៊ីនៅស្រុកផ្សេង ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ កត្តាទាំងនេះហើយ ដែលធ្វើឱ្យការអនុវត្តកម្មវិធីសាលាកុមារមេត្រី មិនសូវមានប្រសិទ្ធភាព។

### ៤.៣.២ ទស្សនៈប្រឈមរបស់គណៈគ្រប់សាលារៀនលើកម្មវិធីសាលាកុមារមេត្រី

តារាងខាងក្រោមនេះ បង្ហាញពីទស្សនៈរបស់នាយក/នាយិកា លើការអនុវត្តកម្មវិធីសាលាកុមារមេត្រី ដែលអ្នកស្រាវជ្រាវបានទៅធ្វើសម្ភាសន៍ផ្ទាល់ជាមួយពួកគាត់ និងបានធ្វើការកត់ត្រា ហើយយកមកធ្វើការសំយោគរកមតិរួមដាក់ចូលក្នុងតារាងខាងក្រោម។

តារាង១២ ទស្សនៈប្រឈមលើការអនុវត្តកម្មវិធីសាលាកុមារមេត្រី

| **សូចនាករវាស់វែង** | **ទស្សនៈប្រឈម** |
|---|---|
| ១).ការឆ្លើយតបសមាសភាគទី១ កុមារទាំងអស់បានចូលរៀន | - សាលានៅក្បែរក្រុង ដូច្នេះប្រឈមទៅនឹងការផ្លាស់ប្ដូរទៅរៀននៅទីប្រជុំជន និងទៅរៀននៅឯកជន<br>- គ្រួសារចំណាកស្រុក នាំកូនចៅទៅជាមួយធ្វើឱ្យអត្រាចូលរៀនថយចុះនៅឆ្នាំសិក្សាណាមួយ<br>- មិនបានបង្កើតក្រុមបណ្ដាញតាមភូមិសម្រាប់តាមដានកុមារនោះទេ |
| ២). ការឆ្លើយតបនៅនឹងសមាសភាគទី២ ការសិក្សាប្រកបដោយប្រសិទ្ធភាព ជានាប្រសិទ្ធភាពផ្ទៃក្នុងរបស់សាលារៀន (អត្រាជាប់ អត្រាធ្លាក់ អត្រាបោះបង់) | - ការរៀបចំវិញ្ញាសាប្រឡងមិនទាន់ត្រូវតាមស្ដង់ដាកំណត់<br>- មិនបានធ្វើតេស្តឡើងថ្នាក់នៅចុងឆ្នាំគ្រប់ថ្នាក់ទេ ដោយយកលទ្ធផលតាមការប្រឡងឆមាសទាំងពីរលើក<br>- ការរៀបចំបន្ទប់មុខវិជ្ជា បន្ទប់ពិសោធន៍ រោងជាង មិនទាន់មានលទ្ធភាពធ្វើបាន<br>- តេស្តស្តង់ដាថ្នាក់ទី៣ និងទី៦ មិនអាចអនុវត្តបានរៀងរាល់ឆ្នាំទេ ដោយសារមិនមានបច្ចេកទេស និងលទ្ធភាពធ្វើ<br>សម្ភារបង្រៀន និងរៀន មិនទាន់សមស្របតាមកម្រិតថ្នាក់ និងមេរៀន |
| ៣). ការឆ្លើយតបសមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារ | - ពិបាកគ្រប់គ្រងដោយសាលាមួយចំនួននៅក្នុងវត្តអារាម ដូច្នេះមានអ្នកលក់ចូលលក់ដូរចូល ធ្វើឱ្យពិបាកគ្រប់គ្រង |

| | |
|---|---|
| | - សាលាមិនទាន់មានរបង ធ្វើឱ្យពិបាកក្នុងការថែរក្សាទ្រព្យសម្បត្តិសាលារៀន<br>- មានភាពលំបាកក្នុងការកសាងរចនាសម្ព័ន្ធសាលារៀនឱ្យស្របតាមកម្មវិធីដើម្បីធានាសុវត្ថិភាពដល់កុមារ ដូចជាប្រព័ន្ធទឹកស្អាត កន្លែងលាងសម្អាតដៃ និងបង្គន់អនាម័យ ដែលសាលារៀនមានហើយ តែមិនគ្រប់គ្រាន់សមាមាត្រនឹងចំនួនសិស្ស |
| ៤). ការឆ្លើយតបទៅនឹងសមាសភាគទី ៤ សកម្មភាពយេនឌ័រនៅសាលារៀន | - មិនដែលបានធ្វើវេទិកាយេនឌ័រនៅសាលារៀន និងសហគមន៍ ដោយសារមិនមានកិច្ចសហការ និងលើកជាផែនការសកម្មភាព |
| ៥). ការឆ្លើយតបសមាសភាគទី៥ ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ | - គ្រួសារភាគច្រើនគាត់មិនសូវមានលទ្ធភាពក្នុងការជួយជ្រោមជ្រែងសាលាដោយកត្តាជីវភាពផ្ទាល់របស់ពួកគាត់<br>- មិនមានពេលវេលាចូលរួមសកម្មភាពនានាជាមួយសាលារៀន |
| ៦). ការឆ្លើយតបសមាសភាគទី៦ ការគ្រប់គ្រងដឹកនាំ និងការគាំទ្រពីប្រព័ន្ធអប់រំ | - ការអធិការកិច្ចថ្នាក់រៀន ធ្វើមិនសូវបានញឹកញាប់<br>- កង្វះការចូលរួមពីគ្រូក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន |

ចំពោះការយល់ដឹងលើគោលនយោបាយសាលាកុមារមេត្រី និងក្របខ័ណ្ឌកម្មវិធី រួមមានសូចនាករសម្រាប់អនុវត្ត លទ្ធផលបង្ហាញថាគណៈគ្រប់គ្រងនៅមិនទាន់ចងចាំ និងយល់ច្បាស់ឱ្យបានល្អិតល្អន់នោះទេ ដោយសារតែសូចនាករមានចំនួនច្រើន។ ដោយឡែកក្នុងសមាសភាគនីមួយៗ មានសកម្មភាពមួយចំនួនពិបាកបំពេញដោយពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីរៀបចំ និងអនុវត្តឱ្យមានប្រសិទ្ធភាព (#D05)។

បន្ថែមលើតារាងទិន្នន័យដែលបានបង្ហាញខាងលើ អ្នកស្រាវជ្រាវក៏បានរកឃើញនូវបញ្ហាជារួមដែលសាលារៀនជួបប្រទះក្នុងការអនុវត្តកម្មវិធីកុមារមេត្រី និងមិនបានធ្វើមានដូចជា ការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនរយៈពេល ៥ ឆ្នាំ និងផែនការថវិការយៈពេល ៣ ឆ្នាំ សាលារៀនភាគច្រើនមិនបានធ្វើនោះទេ ដោយសារពួកគាត់មិនទាន់យល់ច្បាស់អំពីទម្រង់នៃផែនការនីមួយៗ និងកង្វះការចូលរួមពីលោកគ្រូ អ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលាក្នុងការប្រជុំធ្វើផែនការ។ បញ្ហានេះយើងអាចវាយតម្លៃបានថា មកពីកត្តាគណៈគ្រប់គ្រងសាលារៀនដែលពួកគាត់មិនមានផែនកាក្នុងការប្រជុំធ្វើផែនការ និងមិនមានកិច្ចសហការផ្ទៃក្នុងអង្គភាព ក្នុងការចាយវាយថវិកាប្រកបដោយតម្លាភាព និងគណនេយ្យភាព។

បញ្ហាប្រឈមធំមួយទៀតដែល យើងកត់សម្គាល់ឃើញគឺបរិស្ថានសាលារៀន បរិស្ថានសិក្សាទាំងក្នុងថ្នាក់ និងក្រៅថ្នាក់ មិនទាន់សមស្រប ដោយសាលាមួយចំនួនលិចទឹកនៅរដូវវស្សាពេលមានភ្លៀងធ្លាក់ម្តងៗ ធ្វើឱ្យសិស្សមិនអាចមករៀនបាន ហើយសាលាត្រូវបិទទ្វារជាបណ្តោះអាសន្ន រយៈពេល ៣ ទៅ ៥ថ្ងៃក៏មាន នោះបើតាមការលើកឡើងរបស់នាយកសាលា។ បញ្ហាធំចុងក្រោយគឺការងារបច្ចេកទេស ពាក់ព័ន្ធនឹងការបង្រៀន និងរៀន ដែលជាចំណុចសំខាន់។ តាមការលើកឡើងរបស់នាយក ភាគច្រើនពួកគាត់ហាក់មិនសូវផ្តោតខ្លាំលើការងារបច្ចេកទេសប៉ុន្មានទេ ដោយផ្តោតលើការងារបរិស្ថានជាអាទិភាព ជាមូលហេតុធ្វើឱ្យប្រសិទ្ធភាពផ្ទៃក្នុងសាលារបស់គាត់មានការធ្លាក់ចុះ។

សរុបមកយើងអាចសន្និដ្ឋានបានអំពីបញ្ហាប្រឈមដែលកើតមាននៅសាលារៀន ក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅបឋមសិក្សា មានផ្នែកធំៗពីរ គឺការងារបរិស្ថាន និងការងារបច្ចេកទេស ដែលសាលារៀនមិនអាចអនុវត្តបាន ដោយសារលក្ខខណ្ឌកម្មវិធីតម្រូវមានភាពតឹងតែង (លក្ខណៈវិនិច្ឆ័យខ្ពស់) និងការអនុវត្តរបស់គណៈគ្រប់គ្រងនៅតាមសាលារៀននៅមានកម្រិត។

## ៤.៤ ការពិភាក្សា

ប្រសិទ្ធភាពនៃការចូលរៀន សំដៅលើការចូលរៀនប្រកដោយសមធម បរិយាបន្ន និងផ្តល់ឱកាសសម្រាប់ការសិក្សាពេញមួយជីវិត (ក្រសួងអយក ២០១៩)។ ផ្អែកលើលទ្ធផលស្រាវជ្រាវតាមចំណុច ៤.១.២ សិក្សាលើសមាសភាគទី១ ការធានាកុមារទាំងអស់បានចូលរៀន ឃើញថាទទួលបានមធ្យមពិន្ទុរួម M= 3.69 មានន័យថាស្ថានភាពនៃការអនុវត្តលើសមាសភាគទី១នេះ ទទួលបានលទ្ធផលកម្រិតល្អបង្គួរ។

**ការប្រមូលកុមារចូលរៀនមានការកើនឡើង**

ថ្វីត្បិតសាលារៀនមិនអាចអនុវត្តបានទាំងស្រុងតាមសូចនាករដែលបានពោល ប៉ុន្តែការអនុវត្តតាមសាលារៀនកន្លងមកឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់នាយក នាយិកា និងលោកគ្រូ អ្នកគ្រូផ្ទាល់ និងមានកិច្ចសហការជាមួយអ្នកពាក់ព័ន្ធផ្សេងទៀតមាន អាជ្ញាធរ កុមារា កុមារី និងមាតាបិតាសិស្ស។ ចំពោះសូចនាករមួយចំនួនដែលសាលារៀនបានអនុវត្តតិចតួច យើងសង្កេតឃើញថា វាពុំជះឥទ្ធិពលអវិជ្ជមានដល់ការ

ប្រមូលកុមារចូលរៀននោះទេ។ កត្តាបរិបទសង្គមសម័យទំនើប វាបានជួយឱ្យការអនុវត្តការប្រមូលកុមារចូលរៀនកាន់តែមានប្រសិទ្ធភាពជាងមុនទៀតផង តាមរយៈផ្សព្វផ្សាយសេចក្តីជូនដំណឹង ក្នុងបណ្តាញសង្គមនានា មានដូចជា Facebook, Telegram និង Messenger ជាដើម។

**ប្រសិទ្ធភាពនៃការបង្រៀន និងរៀន**

លទ្ធផលលើសមាសភាគទី២ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន មានមធ្យមពិន្ទុ M= 3.63 ស្ថិតក្នុងស្ថានភាពអនុវត្តកម្រិតល្អបង្គួរ។ បើយើងមើលលើចំណុចបរិយាយ ពីលេខរៀង ១៦ ដល់ ៤៩ សម្គាល់ឃើញថាមានតម្លៃមធ្យមពិន្ទុខុសៗគ្នាច្រើន ដែលបញ្ជាក់ថា សូចនាករមួយចំនួននៅតែមិនទាន់អាចអនុវត្តបានតាមស្តង់ដា ហើយមួយចំនួនទៀតហាក់អនុវត្តមិនមានប្រសិទ្ធភាព។ ពាក់ព័ន្ធនឹងប្រសិទ្ធភាពផ្ទៃក្នុង នៅតាមសាលាសំណាកដែលបានជ្រើសរើស អត្រាជាប់មធ្យមភាគ មានភាគរកខ្ពស់ក្នុងរង្វង់ ៨២ ទៅ ៩២% ដែលជាលទ្ធផលមួយខ្ពស់ ចំណែកអត្រាធ្លាក់មធ្យមភាគ ក្នុងរង្វង់ពី ៧ ទៅ ១៤%ប៉ុណ្ណោះ និងមានសិស្សបោះបង់តិចតួចទៅតាមសិក្សានីមួយៗ។

**ការងាររដ្ឋបាល**

ទោះជាយ៉ាងណា បើមើលលើបរិយាយនីមួយៗវិញ ចំពោះការងាររដ្ឋបាលថ្នាក់ រដ្ឋបាលគ្រូ បច្ចេកទេសបង្រៀន វិធីសាស្ត្របង្រៀន ការផលិតសម្ភារឧបទ្ទេស និងការងារបំណិនជីវិត សុទ្ធតែមានតម្លៃមធ្យមទាប។ លទ្ធផលបែបនេះ វាបានគូសបញ្ជាក់ថា ការអនុវត្តនៅក្នុងសមាសភាគទី២នេះ មានមធ្យមពិន្ទុរួម M> 3.50 ពិតមែន ប៉ុន្តែការអនុវត្តនៅមិនទាន់មានប្រសិទ្ធភាពនោះទេ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ការអនុវត្តលើសមាសភាគទី២ ស្ថិតក្នុងស្ថានភាពមធ្យម។

**បញ្ហាសុខភាព និងសុវត្ថិភាពចំណីអាហារ**

ការអនុវត្តលើសមាសភាគទី៣ អំពីសុខភាព សុវត្ថិភាព និងការការពារកុមារ ស្ថិតក្នុងកម្រិតល្អបង្គួរដែលមានកម្រិតវាស់វែងតម្លៃមធ្យម M= 3.74។ ការធានាសុខវិត្តិភាពរបស់កុមារ នៅតាមសាលារៀននីមួយៗមិនមានបញ្ហាចោទនោះទេ លើការកេងប្រវ័ញ្ច និងអំពើហិង្សាលើកុមារ មានការគ្រប់គ្រងបានល្អ និងមាន

ប្រសិទ្ធភាព។ ដោយឡែកចំពោះការថែរក្សាសុខភាព និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន ទើបជាបញ្ហាប្រឈមដែលពិបាកក្នុងការទប់ស្កាត់ ទោះបីជាមានការជុំជាមួយអ្នកលក់ដូរជាមួយអាជ្ញាធរ ក្រសួងអប់រំ មន្ទីរអប់រំ និងរដ្ឋបាលខេត្ត បានចេញលិខិតណែនាំក៏ពិតមែន ប៉ុន្តែការអនុវត្តនៅមិនទាន់បានជាប់លាប់ និងមានប្រសិទ្ធភាពនោះទេ។

វាពាក់ព័ន្ធនឹងកត្តាសេដ្ឋកិច្ចគ្រួសាររបស់កុមារផងដែរ តាមការស្រាវជ្រាវបង្ហាញថា ការចំណាចរបស់សិស្សដែលមកពីគ្រួសារក្រីក្រលើចំណីអាហារល្អៗ ទាបជាងការចំណាចរបស់សិស្សមកពីគ្រួសារមានជីវភាពធូធារ (សំរេច, ២០២៣)។ យោងតាមសៀវភៅអប់រំសុខភាពបឋមសិក្សា របស់នាយកដ្ឋានសុខភាពសិក្សា ក៏បានលើកឡើងពីសារៈប្រយោជន៍នៃការទទួលទានចំណីអាហារគ្រប់គ្រាន់ និងមានសារជាតុចិញ្ចឹមគ្រប់មុខ ទើបកុមារមានសុខភាពល្អ ទាំងរាងកាយ បញ្ញា និងស្មារតី (នាយកដ្ឋានសុខភាពសិក្សា ២០២៣)។

**បញ្ហាយេនឌ័រ**

សមាសភាគទី៤ និយាយអំពីការឆ្លើយតបទៅនឹងយេនឌ័រ ទទួលបានលទ្ធផលការអនុវត្តស្ថិតក្នុងកម្រិតមធ្យមកម្រិតខ្ពស់ ដែលមានតម្លៃមធ្យមរួម M= 3.91 ខ្ពស់ជាងសមាសភាគទី១ ទី២ និងទី៣។ ចំណុចនេះឃើញថាសាលារៀន បានយកចិត្តទុកដាក់លើសមភាពយេនឌ័របានល្អប្រសើរ ដោយទាំងគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ បានយល់ដឹងពីអត្ថប្រយោជន៍នៃការធ្វើការជាមួយគ្នាទាំងស្រី ទាំងប្រុស។ ចំពោះការៀបចំសមាសភាពគណៈកម្មការនានាដើម្បីគ្រប់គ្រង និងដឹកនាំសាលារៀន អ្នកស្រាវជ្រាវកត់សម្គាល់បានលើគោលការណ៍ សមត្ថភាពជាចម្បង និងសមភាពយេនឌ័រ ជាអាទិភាពបន្ទាប់។

**ការចូលរួមរបស់សហគមន៍**

ចំពោះសមាសភាគទី៥ ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ មានមធ្យមពិន្ទុរួម M= 3.68 ស្ថិតក្នុងកម្រិតល្អបង្គួរ។ សាលារៀនរៀនរីកចម្រើនទៅបានអាស្រ័យសហគមន៍ចូលរួម ព្រះសហគមន៍ជាធនធានរបស់សាលារៀន ទាំងផ្នែកសម្ភារ ថវិកា និងធនធានមនុស្ស។ នៅក្នុងសមាសភាគនេះ សាលារៀនភាគច្រើនមិនសូវមានទំនាក់ទំនង់ជាមួយសហគមន៍នោះទេ ព្រោះយល់ថាសហគមន៍សូវយកចិត្តទុកដាក់

និងចូលរួមជាមួយសាលា។ កត្តានេះ តាមការលទ្ធផលនៃកម្រងសំណួរខាងលើ បង្ហាញថា សាលារៀនមិនបានធ្វើផែនការ និងបង្កើតកម្មវិធីនានា រាប់ទាំងការប្រជុំដោយអញ្ជើញសហគមន៍ឱ្យមកចូលរួមនោះទេ។ ការមិនបានប្រជុំជជែកគ្នា មិនបានជួបគ្នា ជាចំណុចនៃការឃ្លាតឆ្ងាយសម្រាប់ទំនាក់ទំនង ដូច្នេះសាលារៀនគួររៀបចំផ្តល់ឱកាសឱ្យសហគមន៍ចូលរួមឱ្យបានញឹកញាប់ និងជិតស្និតជាមួយសាលាទើបប្រសើរ។

**ការងារដឹកនាំគ្រប់គ្រង**

យោងតាមតាងរាង ៤.១.៧ សមាសភាគទី៦ ការគ្រប់គ្រង ដឹកនាំសាលារៀន ទទួលបានមធ្យមពិន្ទុសរុបរួម M= 4.11 ជាតម្លៃមធ្យមខ្ពស់ជាងគេក្នុងចំណោមសមាសភាគទាំង ៦ របស់កម្មវិធី CFS។ ការដឹកនាំនិងគ្រប់គ្រងសាលារៀនលុះត្រាមានប្រសិទ្ធភាពខ្ពស់ ទើបអាចសម្រេចបាននូវសូចនាករដទៃទៀតបាន។ ក្នុងនោះយើងសង្កេតឃើញសូចនាករមួយចំនួន នៅមិនទាន់អនុវត្តបានល្អ លើការងារគ្រប់គ្រងហិរញ្ញវត្ថុ ការងារបច្ចេកទេស និងការធ្វើផែនការនានារបស់សាលារៀន ដែលនៅទទួលបានលទ្ធផលកម្រិតទាប។

បើធៀបទៅនឹងស្តងដាកម្មវិធីសាលាកុមារមេត្រី ដែលមាន ៦ សមាសភាគ និងមានចំណុចបរិយាយជាច្រើនដែលគាំទ្រដល់សមាសភាគពី ១ ដល់ ៦ ឃើញថា សាលារៀនអនុវត្តបានក្នុងស្ថានភាពល្អបង្គួរ ប៉ុន្តែមិនទាន់អាចអនុវត្តបានតាមក្របខ័ណ្ឌកម្មវិធីក្នុងកម្រិតស្តង់ដាឡើយ។

តាមការកឃើញសាលារៀនភាគច្រើនមិនអាចបំពេញតាមលក្ខខណ្ឌកម្មវិធីលើផ្នែកទាំងពីរសំខាន់ៗ មាន ១) ការអនុវត្តលើកការងារបរិស្ថានសាលារៀន និងសម្ភាររូបវន្តជារួម និង ២) ការអនុវត្តលើការងារគ្រប់គ្រង និងបច្ចេកទេស។ ការងារបរិស្ថានជារួមដូចជា សាលារៀនត្រូវមានរចនាសម្ព័ន្ធអាគារសមស្របតាមអាយុ កម្រិតថ្នាក់ និងមានជម្រាល ទីធ្លារាបស្មើ និងមានផាសុកភាព សម្រាប់ការបង្រៀន និងរៀន មានសម្ភារសម្រាប់ដំណើរការគ្រប់គ្រាន់ ដូចជាការពិសោធន៍ ការប្រើសម្ភារឧបទ្ទេសជាដើម។

ការងារបច្ចេកទេសពាក់ព័ន្ធនឹង ប្រសិទ្ធភាពនៃការសិក្សារៀនសូត្ររបស់សិស្ស មានការវាយតម្លៃជាលក្ខណៈស្តង់ដា មានការធ្វើតេស្តដើមឆ្នាំ ចុងឆ្នាំ និងអធិការកិច្ចផ្ទៃក្នុងជាញឹកញាប់។ បញ្ហាទាំងនេះនៅតែកើតមាន ថ្វីត្បិតកម្មវិធីសាលាកុមារមេត្រីត្រូវបានយកមកអនុវត្តអស់រយៈពេល ជាង ១០ ឆ្នាំហើយក៏ដោយ

ព្រោះថា សាលារៀនមិនមានលទ្ធភាព គ្រប់គ្រាន់លើផែនថវិកាក្នុងខ្ទង់ចំណាច និងមិនអាចរកបានពីដៃគូ ឬសប្បុរសជនបាននោះទេ ជាហេតុធ្វើឱ្យសាលារៀនគ្មានអគារសិក្សាគ្រប់គ្រាន់តាមនិយាមសិស្ស-ថ្នាក់ ហើយមិនមានបន្ទប់ពិសោធន៍ ឬបន្ទប់មុខវិជ្ជាដែលដំណើរការឡើយ។ មួយវិញទៀត សាលាមួយចំនួនធំ ជួបបញ្ហាខ្វះគ្រូបង្រៀន ដែលនាំឱ្យសាលាប្រើគ្រូបង្រៀនកិច្ចសន្យាជំនួសគ្រូក្របខ័ណ្ឌ ធ្វើឱ្យប្រសិទ្ធភាពនៃការបង្រៀន និងរៀន មានការធ្លាក់ចុះ។

តាមរបាយការណ៍ដែលលើកឡើងដោយសន្និបាតអប់រំ បានពោលថាភាគរយសាលារៀនបានអនុវត្តកម្មវិធីសាលាកុមារមេត្រី ក្នុងកម្រិតមធ្យម និងកម្រិតអភិវឌ្ឍន៍មានការកើនឡើង ស្របនឹងលទ្ធផលដែលបានរកឃើញ ព្រោះបើតាមលទ្ធផលបង្ហាញថា ស្ថានភាពអនុវត្តនៅក្នុងសូចនាករបរិយាយតាមសមាសភាគនីមួយៗ ទទួលបានពិន្ទុមធ្យមកម្រិតល្អបង្គួរមានចំនួនច្រើន រីឯកម្រិតមធ្យម និងខ្សោយ មានចំនួនតិច។ តាមរយៈការចុះសម្ភាសមន្ត្រីពាក់ព័ន្ធ ក៏បានបង្ហាញពីបញ្ហាប្រឈមជាច្រើនដែលសាលារៀនមិនអាចយកមកអនុវត្តបាន និងអនុវត្តហើយតែពុំមានប្រសិទ្ធភាព ដូចរបាយការណ៍ដែលបានលើកឡើងផងដែរ។

ភាគរយសាលាកុមារមេត្រីកម្រិតមធ្យម និងអភិវឌ្ឍន៍នៅបឋមសិក្សា

ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣




*ប្រភពក្រសួងអប់រំ*

## ៤.៥ យោបល់របស់អ្នកឆ្លើយតប នៅលើបញ្ហាប្រឈម

គណៈគ្រប់គ្រងសាលារៀន និងមន្ត្រីគ្រប់គ្រងកម្មវិធីសាលាកុមារមេត្រី ថ្នាក់ខេត្ត បានឆ្លើយតបទៅនឹងបញ្ហាប្រឈម ដែលកើតមានក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រី ដែលបានជួបប្រទះកន្លងមក និងបានលើកជាដំណោះស្រាយ យុទ្ធសាស្ត្រ និងធាតុចូលមួយចំនួនសម្រាប់យកទៅអនុវត្ត។ ក្នុងនោះយើងកត់សម្គាល់ឃើញថាមានចំណុចបីដែលជាចំណុចគន្លឹះសម្រាប់អនុវត្ត។

ទីមួយ ត្រូវពង្រឹងលើកិច្ចសហការជាមួយអាជ្ញាធរ និងសហគមន៍ដោយឱ្យសាលារៀនបង្កើតសមាគមមាតាបិតាសិស្ស និងដំណើរការប្រជុំឱ្យបានទៀងទាត់ ដោយមានការចូលរួមពីគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងអាជ្ញាធរភូមិ ឃុំ។ អញ្ជើញគណៈកម្មការគ្រប់គ្រងសាលា (គណៈកម្មការទ្រទ្រង់) និងតំណាងសមាគមមាតាបិតាសិស្ស ឱ្យចូលរួមធ្វើផែនការនានារបស់សាលារៀន និងជជែកគ្នារកដំណោះស្រាយដោយឈរលើគោលការណ៍រួមមួយ។

ទីពីរ ពង្រឹងធនធានមនុស្សក្នុងអង្គភាព។ ចំណុចនេះមានន័យថា គ្រូបង្រៀនត្រូវតែមានគរុកោសល្យពង្រឹងគុណវុឌ្ឍិ ប្រកាន់ក្រមសីលធម៌វិជ្ជាជីវៈ និងបណ្ដុះមនសិការក្នុងអាជីពរបស់ខ្លួន។កាជួយគ្រូបង្រៀនលើវិធីសាស្ត្រ ការចែករំលែកគ្នាទៅវិញទៅមកនូវវិធីបង្រៀនថ្មី តាមរយៈការដំណើរការថ្នាក់និទ្ទស្សន៍ឱ្យបានទៀងទាត់ និងអធិការកិច្ចថ្នាក់រៀនឱ្យបានជាញឹកញាប់។ ការពង្រឹងលើធនធានមនុស្សបាន ជាចំណុចចាប់ផ្ដើមនៃការរីកចម្រើនលើលទ្ធផលសិក្សារបស់សិស្ស លើសម្បទាទាំងបី (វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា) និងជានាបាននូវប្រសិទ្ធភាពផ្ទៃក្នុងប្រកបដោយបរិមាណ និងគុណភាព។

ទីបី ផ្ដោតលើការយកចិត្តទុកដាក់ចំពោះបរិស្ថានសាលារៀន ទាំងក្នុងថ្នាក់រៀន ក្រៅថ្នាក់រៀន និងបរិវេណសាលាទាំងមូល។ បរិស្ថានសាលារៀនត្រូវរៀបចំឱ្យមានលក្ខណៈពីរយ៉ាង មួយសោភ័ណភាព និងពីរជាប្រយោជន៍ដល់ការសិក្សារៀនសូត្រ។ ត្រូវបង្កើតឱ្យមានសួនជីវៈចម្រុះសម្រាប់សិស្សានុសិស្សសិក្សារៀនសូត្រ និងស្រាវជ្រាវក្នុងម៉ោងជីវៈវិទ្យា និងផែនដីវិទ្យាជាដើម ដែលធ្វើឱ្យសិស្សទទួលបានបំណិនមួយជាក់

លាក់ និងងាយចងចាំ។ លើសពីនេះ ត្រូវរៀបចំបន្ទប់មុខវិជ្ជា ឬបន្ទប់ពិសោធន៍តាមដែលអាចធ្វើបាន សម្រាប់ជម្រុញ និងពង្រឹងលើប្រសិទ្ធភាពនៃការរៀនមុខវិជ្ជាវិទ្យាសាស្ត្រឱ្យកាន់តែរីកចម្រើន។

ទីបួន បង្កើនការត្រួតពិនិត្យតាមដាន និងវាយតម្លៃរៀងរាល់ដើមឆ្នាំ ឬចុងឆ្នាំ ឱ្យបានទៀងទាត់ និងផ្តល់មតិយោបល់កែលម្អចំណុចខ្វះខាត សម្រាប់សាលារៀនដើម្បីឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាព។

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ការស្រាវជ្រាវនេះបានផ្តល់របកគំហើញមួយ ស្តីពីស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី នៅកម្រិតបឋមសិក្សាក្នុងខេត្តត្បូងឃ្មុំ និងបញ្ហាប្រឈមដែលនាំឱ្យសាលារៀនមិនអាចអនុវត្តកម្មវិធីបាន ព្រមទាំងលើកពីដំណោះស្រាយមួយចំនួនលើបញ្ហាដែលសាលារៀនជួបប្រទះក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព។ អ្នកស្រាវជ្រាវកឃើញថា ការអនុវត្តតាមសមាសភាគនីមួយៗ មានស្ថានភាពអនុវត្តខុសៗគ្នាដោយសមាសភាគខ្លះទទួលបានលទ្ធផលល្អ មធ្យម និងខ្លះទៀតអនុវត្តបានក្នុងកម្រិតខ្សោយ។

សកម្មភាពមួយចំនួនដែលអនុវត្តបានកម្រិតមធ្យមដូចជានៅក្នុងសមាសភាគទី១ អំពីការចូលរៀនរបស់កុមារ ដែលសាលារៀនភាគច្រើនអនុវត្តបាន និងមានប្រសិទ្ធភាព ទោះបីជាសូចនាករមួយចំនួនតូចសាលារៀនមិនបានអនុលោមតាម ប៉ុន្តែមានកម្រិតលទ្ធផលល្អលើការចូលរៀនរបស់កុមារ។ សូចនាករគោលសំខាន់ៗ មួយចំនួននៅក្នុងសមាសភាគទី៤ អំពីការឆ្លើយតបទៅនឹងយេនឌ័រ សាលារៀនភាគច្រើនបានអនុវត្តក្នុងកម្រិតមធ្យម ទៅល្អបង្គួរ តាមតារាងលទ្ធផលបរិមាណវិស័យ ហើយក៏មានការលើកឡើងស្រដៀងគ្នានៅក្នុងលទ្ធផលបែបគុណវិស័យផងដែរ។ ទន្ទឹមនឹងនេះក៏ឃើញមានសមាសភាគមួយចំនួនទៀត ដែលសទទួលបានលទ្ធផលអនុវត្តកម្រិតល្អបង្គួរ និងកម្រិតល្អ ដែលសាលរៀនមួយចំនួនអាចធ្វើបាន ដោយមានការសហការ និងការចូលរួមរវាងនាយក/នាយិកា ជាមួយគ្រូបង្រៀន និងសហគមន៍ ដូចមានក្នុងសមាសភាគទី៥ និយាយពីការចូលរួមពី គ្រួសារ និងសហគមន៍។

ដោយឡែកចំពោះសមាសភាគទី២ និងសមាសភាគទី៣ ឃើញថាមានការច្រើនសូចនាករច្រើនជាងគេ ហើយភាគច្រើនផ្តោតលើការងាររដ្ឋបាល បច្ចេកទេសរបស់គ្រូបង្រៀន បរិស្ថានសិក្សា និងសុវត្ថិភាពចំណីអាហារ ដែលមានភាពស្មុគស្មាញដែលសាលារៀនពិបាកក្នុងការយកពិន្ទុល្អ (M>3.5) និងអនុវត្តឱ្យមានប្រសិទ្ធភាពណាស់ ព្រោះមានសូចនាករខ្លះសាលាមិនមានលទ្ធភាពធ្វើតែម្តង។ ចំណែកសមាសភាគទី៦

វិញ អំពីការដឹកនាំ និងគ្រប់គ្រងសាលារៀន (ការគាំទ្រពីប្រព័ន្ធអប់រំ) បង្ហាញថា សាលារៀនមានការអនុវត្តបានកម្រិតមធ្យម ទៅល្អបង្គួរ ប៉ុន្តែសម្រាប់លទ្ធផលដែលយើងទទួលបានពីគុណវិស័យ ហាក់មានភាពលម្អៀងបន្តិចលើសកម្មភាពអនុវត្តរបស់សាលារៀន។ ចំណុចនេះ យើងអាចវាយតម្លៃបានថា កម្រិតអនុវត្តស្ថិតក្នុងស្ថានភាពល្អបង្គួរ ឬមធ្យម ពុំទាន់អាចដឹងអំពីប្រសិទ្ធភាពនៃការអនុវត្តទៅបានលទ្ធផលកម្រិតណាមួយនោះទេ។

ទន្ទឹមនឹងលទ្ធផលដែលបានរកឃើញ ការស្រាវជ្រាវក៏បានលាតត្រដាងនូវបញ្ហាប្រឈមមួយចំនួនទៀតផងដែរ ដែលសាលារៀន និងមន្ត្រីគ្រប់គ្រងកម្មវិធីធ្លាប់បានជួបប្រទះក្នុងការកិច្ចដំណើរការ។ អំពីបញ្ហាប្រឈមនេះ ជារួមប្រឈមលើផ្នែកបី ទីមួយផ្នែកធនធានថវិកា ទីពីរធនធានមនុស្ស និងទីបី ធនធានសម្ភារគាំទ្រកិច្ចដំណើរការ។ ការខ្វះខាតធនធានមនុស្ស មិនអាចឆ្លើយតបទៅនឹងសមាសភាគទី២ ដែលនិយាយពីប្រសិទ្ធភាពនៃកាបង្រៀន និងរៀនបានឡើយ។ ធនធានមនុស្សជាកត្តាគន្លឹះ និងជាចំណុចសំខាន់ក្នុងការទាញឱ្យកម្មវិធីមានការធ្លាក់ចុះលើប្រសិទ្ធភាពនៃការអនុវត្ត។ កង្វះធនធានសម្ភារ ជាចំណុចសកម្មដូចគ្នាទៅនឹងសមាសភាគទី២ ដោយមិនអាចបំពេញតម្រូវការនៃការងាររៀន បង្រៀននោះទេ។ ចុងក្រោយគឺការខ្វះខាតធនធានថវិកា ជាចំណុចស្នូលមួយដែរ ដោយសារខ្វង់ថវិកាមួយចំនួន មិនមានថវិកាត្រូវចំណាយ ទើបសកម្មភាពខ្លះមិនអាចអនុវត្តបាន និងមួយចំនួនទៀតជាការចំណាយខ្ទង់ថវិកាធំ ដែលសាលារៀនភាគច្រើនស្ទើតែទាំងអស់មិនមានលទ្ធភាពធ្វើបាន។

### ៥.២ សំណូមពរ

ការរកឃើញនេះបង្ហាញអ្នកពាក់ព័ន្ធទាំងអស់ឱ្យដឹងថា ថ្វីត្បិតការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ ស្ថិតក្នុងស្ថានល្អបង្គួរ ប៉ុន្តែស្តង់ដាកម្មវិធីមួយចំនួនមានលក្ខខណ្ឌខ្ពស់ធ្វើឱ្យសាលារៀនមិនអាចអនុវត្តបាន។ ទន្ទឹមនឹងនេះ ការអនុវត្តកន្លងមកបានប្រឈមមុខនឹងបញ្ហាមួយចំនួនដែលធ្វើឱ្យការអនុវត្តមិនមានប្រសិទ្ធភាព ដូច្នេះហើយទើបពួកគាត់មានសំណូមពរដល់អ្នកពាក់ព័ន្ធ ដើម្បីចូលរួមដោះស្រាយ ក្នុងគោលដៅរួមមួយសម្រាប់ការប្រែក្លាយសាលារៀនទាំងអស់នៅក្នុងខេត្ត

ត្បូងឃ្មុំ ក៏ដូចជានៅទូទាំងប្រទេសកម្ពុជា ជាសាលារៀនកុមារមេត្រីពេញលេញ។ ក្នុងនោះយើងក៏បានលើកយកសំណូមពរដែលទទួលបានពីគ្រូបង្រៀនមួយចំនួន តាមរយៈផ្នែកទី៣ នៃកម្រងសំណួរ និងទទួលបានពីគណៈគ្រប់គ្រងសាលារៀន តាមរយៈកិច្ចសម្ភាសន៍។

**៥.២.១ ក្រសួងអប់រំ យុវជន និងកីឡា**

- កិច្ចការចំពោះមុខ ពង្រឹងក្រុមការងារដើម្បីធ្វើការពិនិត្យតាមដានការអនុវត្តកម្មវិធីកុមារមេត្រីឱ្យមានប្រសិទ្ធភាព ក្នុងរូបភាពជាការពិនិត្យផ្ទាល់ ឬតាមរយៈប្រព័ន្ធវាយតម្លៃ
- បើកវគ្គបំប៉នបន្ថែមលើការងាររដ្ឋបាល និងបច្ចេកទេសរបស់នាយក និងគ្រូបង្រៀន
- ពិនិត្យ និងកែលម្អឡើងវិញនូវសូចនាករណាដែលសាលារៀន មិនអាចអនុវត្តបាន
- ផ្តល់សម្ភារណាដែលចាំបាច់ សម្រាប់ស្តង់ដាកម្មវិធីតម្រូវឱ្យមាន
- អនុវត្តយន្តការពង្រាយគ្រូទៅតំបន់ដាច់ស្រយាល ឱ្យមានប្រសិទ្ធភាព ទើបការអប់រំនៅមូលដ្ឋានមានសមភាព និងសមធម៌
- ពិនិត្យឡើងវិញលើការកំណត់ពេលវេលាសិក្សារៀនសូត្រ (ប្រតិទិនសិក្សា) ពេលចូលរៀន និងពេលឈប់សម្រាកវិស្សមកាល (វ៉ាកង) ដោយសាលារៀនភាគច្រើននៅតំបន់ជួរមាត់ទន្លេ និងតំបន់ទំនាបពិបាកក្នុងការដំណើរការសិក្សារៀនសូត្រ ដោយសាលារៀនលិចទឹក ផ្លូវពិបាកធ្វើដំណើរ និងប្រឈមមុខនឹងគ្រោះថ្នាក់ផ្សេងៗទាំងគ្រូ និងសិស្សានុសិស្ស។

**៥.២.២ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំក្រុងស្រុក**

- បន្ត និងពង្រឹងការចុះពិនិត្យតាមដានសាលារៀនឱ្យបានច្រើនសាលា និងទៀងទាត់
- ផ្តល់យោបល់កែលម្អ និងជួយរកមធ្យោបាយដោះស្រាយរួមមួយដែលសមស្រប និងអាចធ្វើបាន
- ពង្រាយគ្រូឱ្យដល់សាលារៀនដែលខ្វះគ្រូបង្រៀន
- ទទួលយករាល់ការស្នើសុំពីសាលារៀន និងផ្តល់ព័ត៌មានត្រឡប់ឱ្យបានទាន់ពេលវេលា
- លើកទឹកចិត្តដល់សាលារៀនណាដែលអនុវត្តបានល្អ

### ៥.២.៣ គណៈគ្រប់គ្រងសាលារៀន

- ធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនរយៈពេល ៥ ឆ្នាំឱ្យបានជាក់លាក់
- សហការជាមួយអ្នកពាក់ព័ន្ធ មានអាជ្ញាធរមូលដ្ឋានភូមិឃុំ មាតាបិតាសិស្ស អង្គការ សមាគមនានា សប្បុរសជន ដើម្បីចូលរួមចំណែកលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលារៀន
- ប្រជុំរវាងគ្រូបង្រៀន និងសហគមន៍ដើម្បីឱ្យពួកគាត់ស្វែងយល់ពីគ្នា និងបង្កើនទំនាក់ទំនងល្អ
- អនុវត្តការងារដឹកនាំ និងគ្រប់គ្រងសាលារៀនឱ្យមានគណនេយ្យភាព
- បង្កើតឱ្យមានបទបញ្ជាផ្ទៃក្នុងសម្រាប់សាលារៀន និងអនុវត្តតាមឱ្យបានទៀងទាត់
- រៀបចំថ្នាក់បំប៉នគ្រូបង្រៀនណាដែលខ្សោយវិធីសាស្ត្រ តាមរយៈការប្រជុំបច្ចេកទេស និងបំប៉នថ្នាក់និទ្ទស្សន៍ជាដើម
- យកចិត្តទុកដាក់លើការកែលម្អបរិស្ថានជាចំណុចអាទិភាព
- បង្កើតឱ្យមានបន្ទប់មុខវិជ្ជា និងសួនជីវៈចម្រុះ សម្រាប់បង្រៀនម៉ោងបំណិនជីវិត
- ត្រួតពិនិត្យដំណើរការរៀនសូត្ររបស់សិស្ស និងការបង្រៀនរបស់គ្រូ
- លើកទឹកចិត្តបុគ្គលិកណាដែលបំពេញការងារបានល្អ

### ៥.២.៤ គ្រូបង្រៀន

- ត្រូវប្រកាន់មនសិការវិជ្ជាជីវៈជាគ្រូបង្រៀនឱ្យបានខ្ជាប់ខ្ជួន
- ស្រាវជ្រាវរកតិចនិក (Techniques) បង្រៀនថ្មីៗដែលមានប្រសិទ្ធភាពសម្រាប់ ដាក់បញ្ចូល (Apply) ក្នុងវិធីសាស្ត្របង្រៀន (Teaching Method)
- ពង្រឹងបន្ថែមលើម៉ោងបំណិនជីវិត និងដឹកនាំសិស្សបង្កើតសកម្មភាពផ្សេងៗទាក់ទងបំណិនចាំបាច់ដែលមាននៅមូលដ្ឋាន ដូចជាការដាំបន្លែ ដំណាំផ្សេងៗ ចិញ្ចឹមសត្វជាដើម...
- បង្កើនទំនាក់ទំនងជាមួយមាតាបិតា អាណាព្យាបាលសិស្សឱ្យបានជិតដល់ និងស្និតស្នាលជាងមុន ដើម្បីជានាថាអ្វីដែលគាត់ចង់បាន និងអ្វីដែលយើងត្រូវការបានបំពេញឱ្យគ្នាទៅវិញទៅមក

- ចូលរួមកិច្ចប្រជុំជាមួយអង្គភាព និងចូលរួមកសាងផែនការនានា ដែលសាលារៀនត្រូវធ្វើ
- ចូលរួមទទួលខុសត្រូវ លើការអនុវត្តភារកិច្ចជាគ្រូបង្រៀន
- បន្តពង្រឹងគុណវុឌ្ឍិខ្លួនឯង តាមរយៈការបន្តការសិក្សា ឬការស្រាវជ្រាវស្នាដៃថ្មីៗជាដើម ក្នុងគោលដៅបង្កើនចំណេះ និងចែករំលែកបន្តដល់សិស្សានុសិស្ស។

## ៥.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះ ស្ដីពីស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រី នៅកម្រិតបឋមសិក្សាក្នុងខេត្តត្បូងឃ្មុំ ដែលផ្ដោតលើគោលបំណងបីគឺ ស្ថានភាពអនុវត្តកម្មវិធីបានក្នុងកម្រិតណា មានបញ្ហាប្រឈមអ្វីខ្លះដែលសាលារៀនបានជួបប្រទះ និងដំណោះស្រាយក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ជាងមុន។ អ្នកសិក្សាស្រាវជ្រាវបន្ត គួរសិក្សាស្រាវជ្រាវទាក់ទងទៅនឹង៖

- សិក្សាអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា
- ពង្រីកវិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវក្នុងតំបន់ផ្សេងៗទៀតក្នុងប្រទេសកម្ពុជា
- សិក្សាប្រៀបធៀប អំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅតាមសាលារៀនឯកជន និងគ្រឹះស្ថានសិក្សាសាធារណៈ។

# ឯកសារយោង

1. ជួន ណាត (១៩៦៧) *វចនានុក្រមខ្មែរ*។

2. លោកស្រី ត្រឹង ងា (១៩៧៣) *សៀវភៅប្រវត្តិសាស្ត្រខ្មែរ ភាគ២*

3. ស៊ន សំណាង (១៩៩៩) *ប្រវត្តិនៃការអប់រំ*

4. ក្រសួងអប់រំ យុវជន និងកីឡា (២០០៧) កម្មវិធីសាលាកុមារមេត្រី។

5. រាជរដ្ឋាភិបាល (២០០៧) ច្បាប់ស្តីពីការអប់រំ។

6. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ (២០០៨) សៀវភៅណែនាំការអនុវត្តកម្មវិធីសាលាកុមារមេត្រី។

7. ក្រសួងអប់រំ យុវជន និងកីឡា (២០០៩) គោលការណ៍ប្រតិបត្តិសាលាកុមារមេត្រី សម្រាប់គណៈគ្រប់គ្រងសាលា។

8. ក្រសួងអប់រំ យុវជន និងកីឡា (២០១០) គោលនយោបាយស្តីពីការអភិវឌ្ឍកម្រងសាលារៀន។

9. UNICEF-(២០១១a) ស្តង់ដាប្រតិបត្តិរបស់កម្មវិធីសាលាកុមារមេត្រី។

10. ក្រសួងអប់រំ យុវជន និងកីឡា (២០១១b) គោលនយោបាយស្តីពី សាលាកុមារមេត្រី។

11. ក្រសួងអប់រំ យុវជន និងកីឡា (២០១៣) គម្រោងកែលម្អសាលារៀន សម្រាប់គាំទ្រវិស័យអប់រំ។

12. KAPE (២០១៥) របាយការណ៍ស្តីពីកម្មវិធីសាលាកុមារមេត្រី។

13. រាជរដ្ឋាភិបាល (២០១៦) ផែនការសកម្មភាពជាតិ ស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារនៅកម្ពុជា។

14. ក្រសួងអប់រំ យុវជន និងកីឡា (២០១៧a) ស្តង់ដារនាយកសាលារៀន។

15. ក្រសួងអប់រំ យុវជន និងកីឡា (២០១៧b) ឯកសារស្តីពីការអប់រំបរិយាបន្ន។

16. ក្រសួងអប់រំ យុវជន និងកីឡា (២០១៨a) ឯកសារគណនេយ្យភាពសាលារៀន។

17. ក្រសួងអប់រំ យុវជន និងកីឡា (២០១៨b) សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងនៅតាមសាលារៀន។

18. ក្រសួងអប់រំ យុវជន និងកីឡា (២០១៩a) ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០។

19. ក្រសួងអប់រំ យុវជន និងកីឡា (២០១៩b) ផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ២០១៩-២០២៣។

20. ក្រសួងអប់រំ យុវជន និងកីឡា (២០១៩c) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០១៩-២០២៣។

21. ក្រសួងអប់រំ យុវជន និងកីឡា (២០១៩d) *របាយការណ៍សន្និបាទអប់រំឆ្នាំ ២០១៨-២០១៩*។

22. ក្រសួងអប់រំ យុវជន និងកីឡា (២០១៩e) ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ២០១៨-២០១៩។

23. រាជរដ្ឋាភិបាល (២០១៩a) គោលនយោបាយជាតិស្តីពីសុខភាពសិក្សា។

24. រាជរដ្ឋាភិបាល (២០១៩b) គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារកម្ពុជា (NCP) ២០១៩- ២០២៩។

25. ហង់ ជួនណារ៉ុន (២០២០) កំណែទម្រងសាលារៀននៅកម្ពុជា។

26. រាជរដ្ឋាភិបាល (២០២០) គោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារកម្ពុជា។

27. ក្រសួងអប់រំ យុវជន និងកីឡា (២០២១) ការអប់រំថ្នាក់បឋមសិក្សា។

28. ក្រសួងសង្គមកិច្ច (២០២១) ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា។

29. ហង់ ជួនណារ៉ុន (២០២១) គោលនយោបាយកំណែទម្រង់សាលារៀននៅកម្ពុជា។

30. ក្រសួងអប់រំ យុវជន និងកីឡា (២០២២a) ស្តង់ដាប្រតិបត្តិសុខភាពសិក្សា។

31. ក្រសួងអប់រំ យុវជន និងកីឡា (២០២២b) របាយការណ៍សន្និបាតអប់រំឆ្នាំ ២០២១-២០២២។

32. ក្រសួងអប់រំ យុវជន និងកីឡា (២០២២c) យុទ្ធសាស្ត្រអនុវិស័យ ការអប់រំបឋមសិក្សា ២០២១-២០៣០។

33. មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ (២០២២) របាយការណ៍សន្និបាតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត។

34. នាយកដ្ឋានសុខភាពសិក្សា (២០២៣) សៀវភៅការអប់រំសុខភាព នៅបឋមសិក្សា។

35. ក្រសួងអប់រំ យុវជន និងកីឡា(២០២៣) របាយការណ៍វាយតម្លៃការសិក្សារបស់សិស្ស ថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦។
36. ប្រសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៥ ក្នុងពិធីប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តសាលាកុមារមេត្រី និងការងារសហគមន៍ចូលរួមអភិវឌ្ឍវិស័យអប់រំ នៅខេត្តស្វាយរៀង។
37. UNICEF (2021), A Research Report prepared for …Malawi By Dorothy Nampota, Catherine Jere, Lizzie Chiwaula, Elizabeth Meke and Esme Kadzamira Centre for Educational Research and Training.
38. Al-Ishlah, (2022) , The implementation of child- friendly school to fulfill children's right and prevent violence against children, *Jurnal Pendidikan* 14 (2), 2465-2478.
39. David, O., Dana L.Kelly, Nitika T., Luke S., Chen-Su, (2009), Unicef child friendly schools programming, Washington, DC: *American Institutes for Research*.
40. Deborah J. (2021), Statistics Workbook For Dummies, Statistics Education Specialist at The Ohio State University.
41. George, D., & Mallery, P. (2003). SPSS for Windows Step by Step: A Simple Guide and Reference. 11.0 Update (4th ed.). Boston: Allyn & Bacon.
42. Indra, P., Emilda S., Susana S. Randwick, (2021) The child friendly school program for Developing a Character school in Primary Schools of Binjai City, Indonesia, *International of Social Science Journal* 2 (4), 575-582.
43. Ita Pa., Dwi, Y, Puji, S, Noor, H, (2021), The implementation of child friendly school innovation in Elementary school, *Educational Management* 10 (3), 485-491.
44. Aldridge, J. M. and B. J. Fraser, (2011), "Effects and determinants of outcomes-focused learning environments," Curric. Teach., vol. 26, no. 1, pp. 5–31.
45. Joseph Kitheka, (2015) School factors influencing implementation of CFS in pubic primary school in Kangundo sub-county, Kenya, *University of Nairobi*.
46. Creswell, (2012), Educational research: Planning, conducting and evaluating quantitative and qualitative research, 4th ed. Boston: Pearson Education.
47. Likert, R. (1932). A Technique for the Measurement of Attitudes, Archives of Psychology, 140, 1-55.

48. Mpho, M., Mahlapahlapana,, T., (2014), Lessons learnt in the implementation of a child-friendly schools programme, *South African Journal of Education* 34 (4).

49. Muhammad Nadeem Anwar, Mushtaq Ahmad Malik, Asma Khizar, (2016), A story of child friendly school program, *Gomal University Journal of Research* 32 (2), 65-76.

50. Mami, H., Lusila, A. Purwastuti, Riana N., (2021), Development of the evaluation instrument of the child-friendly school policy, *International Journal of Instruction* 14 (3), 327-340.

51. Barrow and Woods, (2006), An Introduction to philosophy of education, 4th Edition. London and New York: Routledge.

52. Fitriani, (2021), A child-friendly school: How the school implements the model, *International Journal of Evaluation and Research in Education*, Vol. 10, No. 1, pp. 273~284

53. Suharsiwi, S., Rusydy S. Arifin, Anis S., Muhammah A. (2023), "Implementing Child-Friendly Schools Program at Muhammadiyah Elementary School in South Tangerang." *Indonesian Journal of Islamic Education Studies* (IJIES) 6 (1), 109-122. https://doi.org/10.33367/ijies.v6i1.3619.

54. UNICEF, "Characteristics of a rights-based, child-friendly school," UNICEF, 2012.

55. UNICEF, "Child friendly School Program assessment", Available: https://www.unicef.org/lifeskills/index_7260.html. (accessed Nov. 05, 2018). (UNICEF, 2018)

56. Wannatawee, K.: Worakham, P.: & Panya,P. (2017). Developmeent of an Assessment Model on Parallel Educational Management in the Academy Schools under Office of the Basic Education Commission. *European Journal of Education Studies, (3)2, 313. doi:10.5281/zenodo.260133*

# ឧបសម្ព័ន្ធទី១

# លិខិតបង្គាប់ការរបស់គណៈកម្មការ

# ការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :** ២៨០.......**វជអ.** លក

# លិខិតបង្គាប់ការ

យោង៖ - លិខិតឧទ្ទេសនាមលេខ៨៤៧៣ អយក.ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការមេប្រយោគ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

- លិខិតឧទ្ទេសនាមលេខ៨៥០១ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
